# ថ្ងៃទី០៣ ខែ មករា ឆ្នាំ២០២៣

## សម្តេចតេជោ ហ៊ុន សែន អំពាវនាវឱ្យរួមគ្នាប្រយុទ្ធប្រឆាំងការរំលោភបំពាន និងការជួញដូរផ្លូវភេទលើស្ត្រី និងក្មេងស្រី ពិសេសបុរសៗខិលខូច ត្រូវបញ្ឈប់សកម្មភាពអសីលធម៌

https://freshnewsasia.com/index.php/en/localnews/272302-2023-01-01-03-11-25.html 2023-01-01 10:11am

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅព្រឹកថ្ងៃទី១ ខែមករា ឆ្នាំ២០២៣នេះ បានអំពាវនាវដល់ប្រជាពលរដ្ឋ សូមរួមគ្នាប្រយុទ្ធប្រឆាំងការលោភបំពាន និងការជួញដូរផ្លូវភេទសម្រាប់ស្ត្រី និងកុមារី ជាពិសេសអំពាវនាវដល់បុរសៗខិលខូច ត្រូវបញ្ឈប់នូវសកម្មភាពអសីលធម៌។

ការថ្លែងអំពាវនាវរបស់សម្តេចតេជោ ហ៊ុន សែន ធ្វើឡើងក្នុងឱកាសសម្តេច និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន អញ្ជើញសាកសួរសុខទុក្ខកុមាររងគ្រោះដោយការរំលោភបំពាន និងជួញដូរផ្លូវភេទ និងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវអគារមួយខ្នង កម្ពស់៣ជាន់ ស្មើនឹង៤០បន្ទប់ ដែលជាជំនួយរបស់សម្តេចទាំងទ្វេ នៅអង្គការអាហ្វេស៊ីបកម្ពុជា ដែលមានទីតាំងនៅស្ថិតនៅសង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ជាមួយគ្នានេះ សម្តេចតេជោ ហ៊ុន សែន រំពឹងថា អង្គការអាហ្វេស៊ីប នឹងមិនទទួលបានកុមារី និងយុវតី ដែលរងគ្រោះដោយការរំលោភបំពាន ឬជួញដូរផ្លូវភេទកាន់តែច្រើននោះទេ ដោយសម្តេចបញ្ជាក់ថា ការសាងសង់អាគារថ្មីនេះ មិនមែនសំដៅបន្ថែមចំនួនមនុស្សឡើយ ប៉ុន្តែដើម្បីឲ្យកុមារីដែលកំពុងស្នាក់ មានភាពងាយស្រួលជាងមុនប៉ុណ្ណោះ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងយ៉ាងដូច្នេះថា «**មិនមែនធ្វើកន្លែងនេះ [សង់អាគារក្នុងអង្គការអាហ្វេស៊ីប] ដើម្បីត្រៀមទទួលមនុស្សបន្ថែមនោះទេ ដែលសង្ឃឹមថារឿងនេះ នឹងបានឮទៅដល់គ្រប់មនុស្ស ជាពិសេសបុរសៗដែលខិលខូចទាំងឡាយ មិនត្រូវធ្វើសកម្មភាពអ្វី ដែលផ្ទុយជាមួយនឹងសីលធម៌របស់មនុស្ស។ សង្ឃឹមថាទីកន្លែងនេះ បន្ទាប់ពីចៅៗធំទៅ មានប្តី មានគ្រួសារ ចាកចេញទៅ នឹងមិនមានមនុស្សបន្ថែមថ្មី រហូតទៅដល់កន្លែងនេះអាចទៅជាចំណុច ប្រមូលផ្តុំកុមារីដែលរងគ្រោះទេ ប្រសិនបើទីកន្លែងនេះ ដែលមានចំនួនកើនឡើងនូវចំនួនកុមារីដែលរងគ្រោះដោយការរំលោភបំពាន មានន័យថា នៅទូទាំងប្រទេសរបស់យើង វាក៏នៅសល់បញ្ហាទាំងឡាយ ដែលបានកើតការបំពានទៅលើស្ត្រី និងកុមារីផងដែរ។ យើងធ្វើកន្លែងនេះ មិនមែនសំដៅបង្កើនចំនួនមនុស្សទេ ក៏ប៉ុន្តែសំដៅដោះស្រាយបញ្ហា ចៅៗដែលនៅតូចៗ មានកន្លែងជ្រកកោនឲ្យបានស្រួល**»។ សម្តេចតេជោ ហ៊ុន សែន បានថ្លែងទៀតថា «**ថ្ងៃនេះ លោកជំទាវ ជូ ប៊ុនអេង ដែលទទួលខុសត្រូវទៅលើបញ្ហា ការប្រឆាំងការជួញដូរមនុស្ស ក៏មានវត្តមាននៅទីនេះ យើងត្រូវចាប់ផ្តើមរួមគ្នា ដើម្បីប្រយុទ្ធប្រឆាំងជាមួយនឹងអំពើទាំងឡាយដែលបំពាន ហើយជាពិសេសភាពតិរច្ឆានដែលបានកើនឡើង ដោយសារមនុស្សប្រុសមួយចំនួនដែលបានបង្កើត**»។

សូមបញ្ជាក់ថា អង្គការអាហ្វេស៊ីបកម្ពុជា បានបង្កើតឡើងនៅឆ្នាំ១៩៩៦ ដោយលោកស្រី ម៉ម សុម៉ាលី។ អង្គការនេះបង្កើតឡើង ក្នុងគោលបំណងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ លើស្ត្រី និងកុមារី។ អង្គការអាហ្វេស៊ីបកម្ពុជា មានបុគ្គលិកបម្រើការងារសរុបចំនួន៣២នាក់ (ស្រី១៨នាក់) និងមានយុវនារី និងកុមារីសរុបចំនួន ១៤៨នាក់ ដែលកំពុងទទួលការឧបត្ថម្ភពីអង្គការអាហ្វេស៊ីបកម្ពុជា រួមមានការថែទាំសុខភាព និងអាហារូបករណ៍សិក្សា និងបណ្តុះបណ្តាលជំនាញ។ ចាប់តាំងពីឆ្នាំ១៩៩៦មក អង្គការបានជួយដល់កុមារី និងយុវតីរងការរំលោភបំពាន និងជួញដូរផ្លូវភេទសរុបប្រមាណជា ១ម៉ឺននាក់ហើយ៕

## សម្តេចតេជោ ទទួលសំណើរពីប្រធានអង្គការអាហ្វេស៊ីប ដោយមិនអនុញ្ញាតិឲ្យកុមាររងគ្រោះ ពីការរំលោភបំពានឡើងតុលាការ

https://www.kampucheathmey.com/local-news/440322 ថ្ងៃអាទិត្យ ១ មករា ២០២៣ដោយ Sokhom Khon

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានទទួលយកសំណើររបស់ប្រធានអង្គារអាហ្វេស៊ីប (AFESIP) ដែលស្នើសុំកុំឲ្យយកកុមាររងគ្រោះដែលមានអាយុ៥ឆ្នាំ រងគ្រោះដោយការរំលោភបំពានទៅតុលាការទៀតឡើយ ដោយឲ្យមេធាវីការពារក្តីជាអ្នកជំនួស។

មានប្រសាសន៍ក្នុងពីធីសំណេះសំណាលសួរសុខទុក្ខដល់កុមារី យុវតី កំព្រា និងរងគ្រោះនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្តារនីតិសម្បទាយុវនារី អាហ្វេស៊ីប (AFESIP) ទុំឱ ស្ថិតនៅសង្កាត់ព្រៃស ខណ្ឌដង្កោ នៅព្រឹកថ្ងៃអាទិត្យ ទី០១ ខែមករា ឆ្នាំ២០២៣ នេះ សម្តេចតេជោ ហ៊ុន សែន ក៏បានអំពាវនាវដល់ស្ថាប័នតុលាការសូមមានការយោគយល់។ សម្តេចតេជោ បានលើកឡើងថា ការយកក្មេងរងគ្រោះឡើងតុលាការ គឺស្មើនឹងបំបាក់ស្មារតីបន្ថែម ការភ័យក្លាចកាន់តែធ្ងន់ អញ្ចឹងតុលាការគួរតែយល់ពីបញ្ហានេះ។ សម្តេចតេជោ មានប្រសាសន៍បន្ថែមថា តុលាការគឺជាកន្លែងដែលក្មេងរងគ្រោះភ័យក្លាច។ សម្តេចតេជោ ក៏បានអំពាវនាវដល់ក្រសួងយុត្តិធម៌ និងស្ថាប័នពាក់ព័ន្ធ ដើម្បីសុំឲ្យតុលាការមានការយោគយល់ ហើយសម្តេចក៏បានបញ្ជូនមេធាវីការពារក្តីរបស់សម្តេចដើម្បីតតាំងក្តីជូនជនរងគ្រោះ។

សូមបញ្ជាក់ថា ក្នុងពីធីអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខដល់កុមារី យុវតី កំព្រា និងរងគ្រោះនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្តារនីតិសម្បទាយុវនារី អាហ្វេស៊ីប (AFESIP) ទុំឱ លោកស្រីប្រធានមជ្ឈមណ្ឌល បានស្នើសុំសម្តេចតេជា ហ៊ុន សែន កុំឲ្យយកកុមាររងគ្រោះដោយការរំលោភបំពានដែលមានអាយុ៥ឆ្នាំឡើងតុលាការ ព្រោះក្រោយពីកុមាររងគ្រោះត្រឡប់មកពីតុលាការវិញ គឺពួកគេមានការភ័យក្លាចខ្លាំង៕ សុខុម

## ប្រសាសន៍សំខាន់ៗ
## របស់សម្តេចតេជោ ហ៊ុន សែន ឱកាសអញ្ជើញសាកសួរសុខទុក្ខកុមារី និងយុវតី ដែលរងគ្រោះដោយការរំលោភបំពាន និងជួញដូរផ្លូវភេទ នៅអង្គការអាហ្វេស៊ីបកម្ពុជា

http://freshnewsasia.com/index.php/en/localnews/272300-2023-01-01-02-46-09.html 2023-01-01 09:46am

**(ភ្នំពេញ)៖** ជាមួយការបើកទំព័រឆ្នាំថ្មី ២០២៣ នាព្រឹកថ្ងៃអាទិត្យ ទី០១ ខែមករា ឆ្នាំ២០២៣នេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា បានអញ្ជើញសាកសួរសុខទុក្ខកុមារី និងយុវតី ដែលរងគ្រោះដោយការរំលោភបំពាន និងជួញដូរផ្លូវភេទ នៅអង្គការអាហ្វេស៊ីបកម្ពុជា ស្ថិតនៅសង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ក្រៅតែពីសាកសួរសុខទុក្ខសម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ក៏បានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារមួយខ្នង កម្ពស់៣ជាន់ ស្មើនឹង៤០បន្ទប់ ដែលជាជំនួយរបស់សម្តេចទាំងទ្វេនៅក្នុងអង្គការនេះផងដែរ។

**ខាងក្រោមជាខ្លឹមសារនៃប្រសាសន៍សំខាន់ៗរបស់សម្តេចតេជោ ហ៊ុន សែន៖**

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា សម្តេចរីករាយដែលបានអញ្ជើញមកជួបជាមួយកុមារី និងយុវតីប្រកបដោយក្តីក្តុកក្តួល ចំពោះបញ្ហាដែលពួកគេជួបប្រទះ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា សម្តេច និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត មានមោទនភាពចំពោះការជួយជ្រោមជ្រែង ដើម្បីជាប្រយោជន៍សម្រាប់កុមារី និងយុវតីរងគ្រោះនៅអង្គការអាហ្វេស៊ីប។

* សម្តេចតេជោ ហ៊ុន សែន បានអំពាវនាវដល់បុរសៗទាំងឡាយ បញ្ឈប់ធ្វើសកម្មភាពមិនមែនជាសីលធម៌របស់មនុស្ស។

* សម្តេចតេជោ ហ៊ុន សែន រំពឹងថា អង្គការអាហ្វេស៊ីប នឹងមិនទទួលបានកុមារី និងយុវតី ដែលរងគ្រោះដោយការរំលោភបំពាន ឬជួញដូរផ្លូវភេទកាន់តែច្រើននោះទេ។

* សម្តេចតេជោ ហ៊ុន សែន មានប្រសាសន៍ថា ការសាងសង់អគារកន្លែងស្នាក់នៅ នៅអង្គការអាហ្វេស៊ីបឡើង មិនមែនដើម្បីទទួលកុមារី និងយុវតីរងគ្រោះកាន់តែច្រើននោះទេ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងអំពាវនាវឱ្យរួមគ្នាប្រយុទ្ធប្រឆាំងការរំលោភបំពាន និងការជួញដូរផ្លូវភេទសម្រាប់ក្មេងស្រី។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងអំណរគុណដល់សប្បុរសជននានា ដែលបានផ្តល់ការឧបត្ថម្ភនៅអង្គការអាហ្វេស៊ីប។ សម្តេចតេជោ បានចាត់ទុកការឧបត្ថម្ភនេះ គឺជាការឧបត្ថម្ភចំកន្លែងដែលគួរឧបត្ថម្ភ។

* សម្តេចតេជោ ហ៊ុន សែន បានបង្ហាញមោទនភាព និងក្តីរីករាយ ដែលកុមារី និងក្មេងស្រីរងគ្រោះនៅអង្គការអាហ្វេស៊ីក្រោកឈរជម្នះបញ្ហារបស់ខ្លួន ទទួលការអប់រំបានខ្ពស់។

* សម្តេចតេជោ ហ៊ុន សែន បានណែនាំឱ្យផ្តល់អាទិភាពអាហារូបករណ៍សម្រាប់ក្មេងស្រីនៅអង្គការអាហ្វេស៊ីប។

* សម្តេចតេជោ ហ៊ុន សែន ប្រកាសដាក់ចេញគោលការណ៍ឱ្យកុមារីនៅអង្គការអាហ្វេស៊ីប ត្រូវតែបានបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា។ សម្តេចតេជោ ហ៊ុន សែន បានប្រកាសធានាដល់ការសិក្សារបស់ក្មេងស្រីរងគ្រោះនៅអង្គការអាហ្វេស៊ីប។

* សម្តេចតេជោ ហ៊ុន សែន មានមោទនភាពចំពោះកុមារីរងគ្រោះនៅអាហ្វេស៊ីប ដែលបានប្រលងជាប់ចូលក្របខណ្ឌនគរបាល និងយោធា។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា គ្មានសង្គមណាដែលស្តង់ខ្ចីមចំពោះក្មេងស្រីរងគ្រោះការរំលោភបំបៀននោះទេ គឺមានតែការលើកទឹកចិត្ត និងក្តីអាណិតអាសូរ។

* សម្តេចតេជោ ហ៊ុន សែន បានសម្រេចបង្កើនការឧបត្ថម្ភថវិកាដល់អង្គការអាហ្វេស៊ីបពី ១០លានរៀល ទៅ ២០លានរៀល (សម្រាប់ការហូបចុក)។ ការដំឡើងនេះចាប់ផ្តើមពីខែមករា ឆ្នាំ២០២៣តទៅ និងបន្តផ្តល់ប្រាក់១០ម៉ឺនរៀលដល់ក្មេងស្រីនៅអង្គការអាហ្វេស៊ីប។

* សម្តេចតេជោ ហ៊ុន សែន ក៏បានសម្រេចឧបត្ថម្ភដល់អង្គការអាហ្វេស៊ីប ចំនួន៥ម៉ឺនដុល្លារក្នុងមួយឆ្នាំ ដើម្បីដោះស្រាយបញ្ហាផ្សេងៗក្នុងអង្គការ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ការឧបត្ថម្ភនេះ នឹងធ្វើឡើងក្នុងរយៈពេលវែង។ ប៉ុន្តែការធ្វើនេះមិនមែនដើម្បីគាំទ្រ ឱ្យមានការរំលោភបំពានលើក្មេងស្រីនោះឡើយ។

* សម្តេចតេជោ ហ៊ុន សែន រំពឹងថា ការសម្រេចឧបត្ថម្ភនាពេលនេះ នឹងធ្វើឱ្យការទ្រទ្រង់ដំណើរការអង្គការ និងការហូបចុកនៅអង្គការអាហ្វេស៊ីប បានល្អប្រសើរ។

* សម្តេចតេជោ ហ៊ុន សែន ទទួលសំណើរ កុំឱ្យនាំយកុមារីរងគ្រោះដោយការរំលោភបំពានអាយុក្រោម៥ឆ្នាំឡើងតុលាការ។ សំណើនេះ ធ្វើឡើងតាមការស្នើរបស់លោកស្រី ម៉ម សុម៉ាលី នាយកអង្គការអាហ្វេស៊ីប។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ប្រជាពលរដ្ឋកម្ពុជានាំគ្នាឆ្លងឆ្នាំ ដោយក្តីរីករាយ និងគ្មានការភ័យខ្លាច។ សម្តេចតេជោ បានថ្លែងថា នេះហើយជាសមិទ្ធផលសន្តិភាព ដែលរកមកបានដោយលំបាក។

* សម្តេចតេជោ ហ៊ុន សែន បានបញ្ចប់ការថ្លែងសំណេះសំណាលនៅវេលាម៉ោង ៩៖២០នាទីនាព្រឹកថ្ងៃដដែល, សូមអរគុណចំពោះការទស្សនាការផ្សាយផ្ទាល់ តាមរយៈបណ្តាញទូរទស្សន៍ព័ត៌មាន Fresh News៕

### ថៃ និងកម្ពុជា សហការរួមគ្នាបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីលុបបំបាត់ជនឆបោក

https://www.khmertimeskh.com/501211790//?p=1211790 Khmer Times January 1, 2023

កិច្ចសហប្រតិបត្តិការកម្ពុជា-ថៃ ប្រយុទ្ធប្រឆាំងនឹងជនឆបោកត្រូវបានលើកឡើងនៅក្នុងជំនួបរវាងលោកនាយករដ្ឋមន្ត្រី ប្រាយុទ្ធ ចាន់អូចា និងឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ លោក អ៊ុក សោភ័ណ រួមជាមួយនឹងប្រធានបទផ្សេងទៀតទាក់ទងនឹងសេដ្ឋកិច្ច និងសន្តិសុខជាតិ។

លោកនាយករដ្ឋមន្ត្រីថៃ បានថ្លែងអំណរគុណដល់ភាគីកម្ពុជា ដែលបានជួយសង្គ្រោះជនជាតិថៃ ពីមជ្ឈមណ្ឌលហៅទូរស័ព្ទឆបោក និងបានស្នើឱ្យរដ្ឋាភិបាលកម្ពុជា ពន្លឿនដំណើរការបញ្ជូនអ្នកដែលត្រូវបានជួយសង្គ្រោះទាំងអស់ ត្រឡប់មកប្រទេសវិញ។

ឯកអគ្គរាជទូតកម្ពុជាក៏បានជួបជាមួយឧបនាយករដ្ឋមន្ត្រី នាយឧត្តមសេនីយ៍ ប្រាវីត វ៉ង់ស៊ូវ៉ាន់ (Prawit Wongsuwan) ដើម្បីពិភាក្សាអំពីបញ្ហាស្រដៀងគ្នានេះផងដែរ។ ចាប់តាំងពីឆ្នាំ២០២១ មក អាជ្ញាធរកម្ពុជាបានជួយសង្គ្រោះជនជាតិថៃចំនួន៨៥០ នាក់ ដែលត្រូវបានគេល្បួងអោយមកធ្វើការនៅមជ្ឈមណ្ឌលហៅទូរស័ព្ទឆបោកនៅកម្ពុជា។

ចំពោះប្រធានបទពិភាក្សាផ្សេងទៀត នាយឧត្តមសេនីយ៍ ប្រាវីត បានស្នើឱ្យកម្ពុជាពិចារណារៀបចំកិច្ចប្រជុំគណៈកម្មាធិការព្រំដែនចម្រុះថៃ-កម្ពុជា លើកទី៦ បន្ទាប់ពីបានផ្អាករយៈពេល១០ឆ្នាំ ដើម្បីពិនិត្យមើលឡើងវិញនូវបញ្ហាទាក់ទងនឹងកិច្ចសហប្រតិបត្តិការតាមព្រំដែន។

ប្រទេសថៃ និងកម្ពុជាបានសន្យាបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីលុបបំបាត់ជនឆបោកអន្តរជាតិក្នុងតំបន់។ អាជ្ញាធរថៃបានថ្លែងអំណរគុណដល់កម្ពុជាដែលបានជួយសង្គ្រោះពលករថៃជាច្រើននាក់ដែលត្រូវបានគេបោកបញ្ឆោត និងបង្ខំឱ្យធ្វើការខុសច្បាប់៕ *NNT*

## ថ្ងៃទី០៥ ខែ មករា ឆ្នាំ២០២៣

### សមត្ថកិច្ចកម្ពុជា
### បន្តទទួលបានបណ្តឹង ១ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិហ្វីលីពីន ១នាក់

https://freshnewsasia.com/index.php/en/localnews/272586-2023-01-03-09-58-41.html 2023-01-03 04:58pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០១ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី០២ ខែមករា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិហ្វីលីពីន ០១នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី០២ ខែមករា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៦៩២ករណី មានមនុស្ស ១,៦៨៣នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៣៦សំណើ និងបិទសំណុំរឿង ២២៣សំណើ (រកឃើញមនុស្ស ១,០៦០នាក់, ឃាត់ខ្លួនជនសង្ស័យ ១២០នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៣ករណី។

សូមបញ្ជាក់ថា សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

## អ្នកនាំពាក្យក្រសួងមហាផ្ទៃ ៖ សមត្ថកិច្ចកម្ពុជា ទទួលបានបណ្តឹង ២ថែមទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិវៀតណាម ២នាក់

http://nokorwatnews.com/archives/949483 04/01/2023

ភ្នំពេញ៖ បើតាមនាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានថ្លែងឱ្យដឹងនៅព្រឹកថ្ងៃពុធទី០៤ ខែមករា ឆ្នាំ២០២៣នេះថា៖ កម្លាំងសមត្ថកិច្ចកម្ពុជា បានទទួលសំណើចំនួន ០៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិវៀតណាមចំនួន ០២នាក់, នេះបើគិតចាប់ពីម៉ោង ៣៖០០នាទី នាថ្ងៃទី០២ ដល់វេលាម៉ោង ៣៖០០នាទី ថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣ម្សិលមិញនេះ។ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បានថ្លែងបញ្ជាក់ថា៖ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣ រួមមាន៖

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៦៩៣ករណី មានមនុស្ស ១,៦៨៤នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៣៨សំណើ និងបិទសំណុំរឿង ២២៣សំណើ (រកឃើញមនុស្ស ១,០៦២នាក់, ឃាត់ខ្លួនជនសង្ស័យ ១២០នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣២ករណី។

សូមជម្រាបថា សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

គួរបញ្ជាក់ដែរថា ជុំវិញបញ្ហានេះដែរ រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជា៕

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចេញសេចក្តីណែនាំ ស្តីពី នីតិវិធីដែលត្រូវអនុវត្តចំពោះជនរងគ្រោះជាអនីតិជន នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ

https://cen.com.kh/archives/599458.html Posted ByPen Srey NeatJanuary 5, 2023

ភ្នំពេញ៖ ឯកឧត្តមកើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានចេញសេចក្តីណែនាំ ស្តីពី នីតិវិធីដែលត្រូវអនុវត្តចំពោះជនរងគ្រោះជាអនីតិជន នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ។ ឯកឧត្តម កើត រិទ្ធ បានឲ្យដឹងថាកន្លងមក ក្រសួងយុត្តិធម៌ បានកត់សម្គាល់ឃើញថា ចៅក្រម និងព្រះរាជអាជ្ញា នៅតាមបានខិតខំបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនដែលច្បាប់ប្រគល់ឲ្យក្នុងការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ ដោយអនុវត្តទៅតាមបទ ប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរ មាន ជាពិសេស ដើម្បីស្រាវជ្រាវស្វែងរកការពិត និងផ្តល់ យុត្តិ ធម៌តាមផ្លូវច្បាប់ជូនភាគីពាក់ព័ន្ធ ក៏ដូចជាដើម្បីធានាប្រសិទ្ធ ភាពនៃការអនុវត្តច្បាប់។

ប៉ុន្តែទោះជាយ៉ាងនេះក្តី ការអនុវត្តនូវកិច្ចនីតិវិធីមួយចំនួនរបស់ស្ថាប័នអយ្យការនិងស្ថាប័នតុលាការនៅមិនទាន់ឆ្លើយតបបាន ល្អប្រសើរទៅនឹងសំណូមពរនៃស្ថានភាពពិសេស ដោយឡែក ដាក់ស្តែងមួយចំនួននៅក្នុងរឿងក្តីព្រហ្មទណ្ឌជាពិសេសចំពោះ ភាគីជនរងគ្រោះជាអនីតិជន ដែលប្រការនេះ មិនត្រឹម តែអាចធ្វើឲ្យប៉ះពាល់ដល់ប្រសិទ្ធភាព នៃដំណើរការស្វែងរកការពិតនៅក្នុងរឿងក្តីប៉ុណ្ណោះទេ ប៉ុន្តែក៏អាចធ្វើឲ្យប៉ះពាល់ដល់ឧត្តមប្រយោជន៍របស់ជនរងគ្រោះជាអនីតិជន ដែលត្រូវបាន ការពារដោយច្បាប់ជាតិផង និងច្បាប់អន្តរជាតិផង៕

ខាងក្រោមនេះ ជាសេចក្តីណែនាំដែលមានខ្លឹមសារទាំង ស្រុង ៖

កន្លងមក ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា ចៅក្រម និងព្រះរាជអាជ្ញា នៅតាម សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តី បានខិតខំបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន ដែលច្បាប់ប្រគល់ឱ្យក្នុងការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ ដោយអនុវត្តទៅតាមបទប្បញ្ញត្តិនៃក្រមនីតិវិធី ព្រហ្មទណ្ឌ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ជាពិសេស ដើម្បីស្រាវជ្រាវស្វែងរកការពិត និងផ្តល់ យុត្តិធម៌តាមផ្លូវច្បាប់ជូនភាគីពាក់ព័ន្ធ ក៏ដូចជាដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តច្បាប់។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ការអនុវត្តនូវកិច្ចនីតិវិធីមួយចំនួនរបស់ស្ថាប័នអយ្យការ និងស្ថាប័នតុលាការ នៅ មិនទាន់ឆ្លើយតបបានល្អប្រសើរទៅនឹងសំណូមពរនៃស្ថានភាពពិសេសដោយឡែកដាក់ស្តែងមួយចំនួន នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ជាពិសេស ចំពោះភាគីជនរងគ្រោះជាអនីតិជន ដែលប្រការនេះ មិនត្រឹមតែ អាចធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃដំណើរការស្វែងរកការពិតនៅក្នុងរឿងក្តីប៉ុណ្ណោះទេ ប៉ុន្តែ ក៏អាចធ្វើឱ្យប៉ះពាល់ដល់ឧត្តមប្រយោជន៍របស់ជនរងគ្រោះជាអនីតិជន ដែលត្រូវបានការពារដោយច្បាប់ ជាតិផង និងច្បាប់អន្តរជាតិផង។

ក្នុងន័យនេះ ដើម្បីធានាដំណើរការល្អប្រសើរនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ទាំងលើប្រសិទ្ធភាពនៃ ការស្រាវជ្រាវស្វែងរកការពិតស្របតាមបទប្បញ្ញត្តិផ្នែកនីតិវិធីព្រហ្មទណ្ឌផង ទាំងលើការការពារឧត្តម ប្រយោជន៍របស់ជនរងគ្រោះជាអនីតិជននៅក្នុងសំណុំរឿងផង, ក្រសួងយុត្តិធម៌សូមធ្វើការណែនាំអំពី នីតិវិធីចាំបាច់មួយចំនួន ដែលត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានល្អសម្រាប់ជនរងគ្រោះជាអនីតិជន នៅក្នុងសំណុំរឿងក្តីព្រហ្មទណ្ឌ ដូចខាងក្រោម៖

១-ក្នុងដំណាក់កាលស៊ើបអង្កេត

-ព្រះរាជអាជ្ញា ត្រូវយកចិត្តទុកដាក់ក្នុងការអនុវត្តនីតិវិធីតាមច្បាប់ ដោយត្រូវបង្កលក្ខណៈ ទាំងលើទិដ្ឋភាពផ្នែកសត្យានុម័ត ទាំងលើទិដ្ឋភាពផ្នែកចិត្តសាស្ត្រ ដើម្បីអនុញ្ញាតឱ្យជនរងគ្រោះជា អនីតិជនអាចធ្វើការបំភ្លឺ និងផ្តល់ចម្លើយឱ្យបានច្បាស់លាស់ទាក់ទងនឹងអង្គហេតុនៃបទល្មើសដែលបានកើតឡើង សំដៅរកឱ្យឃើញការពិតនៅក្នុងរឿងក្តីដោយចៀសវាងឱ្យបាននូវការផ្តល់ចម្លើយស្ថិតក្នុងស្ថានភាពតក់ស្លតឬភ័យខ្លាចដោយប្រការណាមួយ។

-ក្នុងករណីចាំបាច់ ចំពោះជនរងគ្រោះជាអនីតិជនដែលស្ថិតក្នុងស្ថានភាពមិនអាចធ្វើដំណើរបាន ជាពិសេស សម្រាប់អនីតិជនដែលមានអាយុក្រោម ១០ (ដប់)ឆ្នាំយ៉ាងតិច, ព្រះរាជអាជ្ញា អាចចុះទៅ កាន់លំនៅឋានឬទីកន្លែងដែលជនរងគ្រោះជាអនីតិជននោះស្ថិតនៅដោយផ្ទាល់ ដើម្បីស្តាប់ចម្លើយ ក៏ដូចជាអនុវត្តកិច្ចនីតិវិធីចាំបាច់ផ្សេងទៀត។

-ក្នុងការស្តាប់ចម្លើយរបស់ជនរងគ្រោះជាអនីតិជន, ព្រះរាជអាជ្ញា ត្រូវយកចិត្តទុកដាក់ធ្វើ ការណែនាំឱ្យមានការធ្វើកំណត់ហេតុមួយ ដែលមានលក្ខណៈច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ទាំងលើ សំណួរ ទាំងលើចម្លើយ ក៏ដូចជាការកត់សម្គាល់នានានៅពេលស្តាប់ចម្លើយ ដើម្បីអាចយកធ្វើជា មូលដ្ឋានសម្រាប់ការប្រើប្រាស់នៅគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ នាពេលក្រោយមកទៀត។

-ដើម្បីធានាដល់ការអនុវត្តគោលការណ៍ខាងលើនៅក្នុងដំណាក់កាលស៊ើបអង្កេត, ព្រះរាជអាជ្ញា ត្រូវធ្វើការណែនាំដល់នគរបាលយុត្តិធម៌ទាំងអស់ដែលស្ថិតក្រោមសមត្ថកិច្ចដែនដីរបស់ខ្លួន ឱ្យអនុវត្តតាមការណែនាំខាងលើនេះទាំងការស្តាប់ចម្លើយទាំងការធ្វើកំណត់ហេតុនៃការស្តាប់ចម្លើយរបស់អនីតិជនដែលជាជនរងគ្រោះនៃបទល្មើស។

២-ក្នុងដំណាក់កាលស៊ើបសួរ

ចៅក្រមស៊ើបសួរ ត្រូវបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ថាមានប្រយោជន៍សម្រាប់ បង្ហាញឱ្យឃើញការពិតដោយអនុលោមតាមច្បាប់ ស្របតាមមាត្រា១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងស្មារតីនេះ, ចៅក្រមស៊ើបសួរ ត្រូវយកចិត្តទុកដាក់ក្នុងការអនុវត្តនីតិវិធីតាមច្បាប់ ដោយត្រូវបង្ក លក្ខណៈសមស្រប ទាំងលើទិដ្ឋភាពផ្នែកសត្យានុម័ត ទាំងលើទិដ្ឋភាពផ្នែកចិត្តសាស្ត្រ ដើម្បីអនុញ្ញាត ឱ្យជនរងគ្រោះជាអនីតិជនធ្វើការបំភ្លឺ និងផ្តល់ចម្លើយឱ្យបានច្បាស់លាស់ទាក់ទងនឹងអង្គហេតុនៃ បទល្មើសដែលបានកើតឡើង សំដៅរកឱ្យឃើញការពិតនៅក្នុងរឿងក្តី ដោយចៀសវាងឱ្យបាននូវ ការផ្តល់ចម្លើយស្ថិតក្នុងស្ថានភាពតក់ស្លុត ឬភ័យខ្លាចដោយប្រការណាមួយ។ ជាមួយគ្នានេះ, ចំពោះ ជនរងគ្រោះជាអនីតិជនដែលស្ថិតក្នុងស្ថានភាពមិនអាចធ្វើដំណើរបាន ជាពិសេស សម្រាប់អនីតិជន ដែលមានអាយុក្រោម ១០ (ដប់)ឆ្នាំយ៉ាងតិច ចៅក្រមស៊ើបសួរ អាចចុះទៅកាន់លំនៅឋាន ឬទីកន្លែងដែលជនរងគ្រោះជាអនីតិជននោះស្ថិតនៅដោយផ្ទាល់ ដើម្បីស្តាប់ចម្លើយ ឬបំពេញកិច្ចនីតិវិធីចាំបាច់ ផ្សេងទៀតដោយអនុលោមតាមច្បាប់។

៣-ក្នុងដំណាក់កាលជំនុំជម្រះ

–ជនរងគ្រោះជាអនីតិជន អាចត្រូវបានអមដោយមេធាវី ឬអាចត្រូវបានតំណាងដោយមេធាវី ឬអ្នកតំណាងស្របច្បាប់របស់ខ្លួន ក្នុងពេលសវនាការ ស្របតាមមាត្រា៣១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងស្មារតីនេះ, បន្ថែមលើកិច្ចនីតិវិធីផ្សេងទៀតដែលបានអនុវត្តដោយតុលាការតាមក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមជំនុំជម្រះ ត្រូវជូនដំណឹងដល់មេធាវី ឬតំណាងស្របច្បាប់អំពីសិទ្ធិនេះ ដើម្បីជនរងគ្រោះ ចូលរួមក្នុងសវនាការដោយផ្ទាល់អមដោយវត្តមានរបស់មេធាវី ឬអាចឱ្យមេធាវីឬតំណាងស្របច្បាប់ របស់ខ្លួនផ្សេងទៀតចូលរួមជំនួសក្នុងសវនាការ ដោយអនុលោមតាមមាត្រា៣១៣ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ។

–ក្នុងករណីមានភាពចាំបាច់បំផុតក្នុងការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនល្មើស ក៏ដូចជាការបំភ្លឺ លើចំណុចលម្អិតមួយចំនួន ដែលជាមូលដ្ឋានចាំបាច់ក្នុងការសម្តែងឱ្យឃើញការពិតក្នុងរឿងក្តី, ចៅក្រមជំនុំជម្រះ ត្រូវរៀបចំដំណើរការនីតិវិធី ដោយប្រើប្រាស់វិធីសាស្ត្រប្រយោល តាមរយៈ ការប្រើប្រាស់របាំង ឬរូបថត ឬប្រើប្រាស់វិធីសមស្របផ្សេងទៀត ដោយធ្វើយ៉ាងណាចៀសវាងឱ្យ បានជាអតិបរមានូវការជួបតទល់ដោយផ្ទាល់រវាងជនល្មើស និងជនរងគ្រោះជាអនីតិជន ដែលអាចបង្ក ឱ្យជនរងគ្រោះមានការភ័យខ្លាច ឬតក់ស្លុត ដែលអាចប៉ះពាល់ដល់ការស្វែងរកការពិតផង និងប៉ះពាល់ ដល់ជនរងគ្រោះខាងផ្នែកសតិអារម្មណ៍ផង។

-ដើម្បីធានាដល់ការការពារកិត្តិយស ឯកជនភាព និងចៀសវាងការបង្កនូវភាពភ័យខ្លាចដល់ ជនរងគ្រោះជាអនីតិជន, ចៅក្រមជំនុំជម្រះ ត្រូវយកចិត្តទុកដាក់ពិចារណាអំពីការរៀបចំដំណើរការ សវនាការជាអសាធារណៈ ស្របតាមមាត្រា៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ទទួលបានការណែនាំនេះ សូម ឯកឧត្តម លោកជំទាវ ដែលជាប្រធានសាលាដំបូង និងជាព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ត្រូវចាត់ចែងអនុវត្តសេចក្តីណែនាំនេះឱ្យមាន ប្រសិទ្ធភាពស្របតាមគោលបំណង និងស្មារតីនៃច្បាប់ សំដៅបង្កើនប្រសិទ្ធភាពនៃយុត្តិធម៌ព្រហ្មទណ្ឌ និងពង្រឹងនីតិរដ្ឋនៅកម្ពុជា៕រក្សាសិទ្ធិដោយ ៖ សុទ្ធលី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ :០១៣យ.សណន/១៣

# សេចក្តីណែនាំ

# ស្តីពី

# នីតិវិធីដែលត្រូវអនុវត្តចំពោះជនរងគ្រោះជាអនីតិជន នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ

កន្លងមក ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា ចៅក្រម និងព្រះរាជអាជ្ញា នៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តី បានខិតខំបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន ដែលច្បាប់ប្រគល់ឱ្យក្នុងការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ ដោយអនុវត្តទៅតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ជាពិសេស ដើម្បីស្រាវជ្រាវស្វែងរកការពិត និងផ្តល់យុត្តិធម៌តាមផ្លូវច្បាប់ជូនភាគីពាក់ព័ន្ធ ក៏ដូចជាដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តច្បាប់។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ការអនុវត្តនូវកិច្ចនីតិវិធីមួយចំនួនរបស់ស្ថាប័នអយ្យការ និងស្ថាប័នតុលាការ នៅមិនទាន់ឆ្លើយតបបានល្អប្រសើរទៅនឹងសំណូមពរនៃស្ថានភាពពិសេសដោយឡែកជាក់ស្តែងមួយចំនួននៅក្នុងរឿងក្តីព្រហ្មទណ្ឌ ជាពិសេស ចំពោះភាគីជនរងគ្រោះជាអនីតិជន ដែលប្រការនេះ មិនត្រឹមតែអាចធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃដំណើរការស្វែងរកការពិតនៅក្នុងរឿងក្តីប៉ុណ្ណោះទេ ប៉ុន្តែ ក៏អាចធ្វើឱ្យប៉ះពាល់ដល់ឧត្តមប្រយោជន៍របស់ជនរងគ្រោះជាអនីតិជន ដែលត្រូវបានការពារដោយច្បាប់ជាតិផង និងច្បាប់អន្តរជាតិផង។

ក្នុងន័យនេះ ដើម្បីធានាដំណើរការល្អប្រសើរនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ទាំងលើប្រសិទ្ធភាពនៃការស្រាវជ្រាវស្វែងរកការពិតស្របតាមបទប្បញ្ញត្តិផ្នែកនីតិវិធីព្រហ្មទណ្ឌផង ទាំងលើការការពារឧត្តមប្រយោជន៍របស់ជនរងគ្រោះជាអនីតិជននៅក្នុងសំណុំរឿងផង, ក្រសួងយុត្តិធម៌សូមធ្វើការណែនាំអំពីនីតិវិធីចាំបាច់មួយចំនួន ដែលត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានល្អសម្រាប់ជនរងគ្រោះជាអនីតិជននៅក្នុងសំណុំរឿងក្តីព្រហ្មទណ្ឌ ដូចខាងក្រោម៖

## ១-ក្នុងដំណាក់កាលស៊ើបអង្កេត

- ព្រះរាជអាជ្ញា ត្រូវយកចិត្តទុកដាក់ក្នុងការអនុវត្តនីតិវិធីតាមច្បាប់ ដោយត្រូវបង្កលក្ខណៈទាំងលើទិដ្ឋភាពផ្នែកសត្យានុម័ត ទាំងលើទិដ្ឋភាពផ្នែកចិត្តសាស្ត្រ ដើម្បីអនុញ្ញាតឱ្យជនរងគ្រោះជាអនីតិជនអាចធ្វើការបំភ្លឺ និងផ្តល់ចម្លើយឱ្យបានច្បាស់លាស់ទាក់ទងនឹងអង្គហេតុនៃបទល្មើសដែលបានកើតឡើង សំដៅរកឱ្យឃើញការពិតនៅក្នុងរឿងក្តី ដោយចៀសវាងឱ្យបាននូវការផ្តល់ចម្លើយស្ថិតក្នុងស្ថានភាពតក់ស្លុត ឬភ័យខ្លាចដោយប្រការណាមួយ។



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

- ក្នុងករណីចាំបាច់ ចំពោះជនរងគ្រោះជាអនីតិជនដែលស្ថិតក្នុងស្ថានភាពមិនអាចធ្វើដំណើរបាន ជាពិសេស សម្រាប់អនីតិជនដែលមានអាយុក្រោម ១០ (ដប់)ឆ្នាំយ៉ាងតិច, ព្រះរាជអាជ្ញា អាចចុះទៅកាន់លំនៅឋាន ឬទីកន្លែងដែលជនរងគ្រោះជាអនីតិជននោះស្ថិតនៅដោយផ្ទាល់ ដើម្បីស្តាប់ចម្លើយ ក៏ដូចជាអនុវត្តកិច្ចនីតិវិធីចាំបាច់ផ្សេងទៀត។

- ក្នុងការស្តាប់ចម្លើយរបស់ជនរងគ្រោះជាអនីតិជន, ព្រះរាជអាជ្ញា ត្រូវយកចិត្តទុកដាក់ធ្វើការណែនាំឱ្យមានការធ្វើកំណត់ហេតុមួយ ដែលមានលក្ខណៈច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ទាំងលើសំណួរ ទាំងលើចម្លើយ ក៏ដូចជាការកត់សម្គាល់នានានៅពេលស្តាប់ចម្លើយ ដើម្បីអាចយកធ្វើជាមូលដ្ឋានសម្រាប់ការប្រើប្រាស់នៅគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ នាពេលក្រោយមកទៀត។

- ដើម្បីធានាដល់ការអនុវត្តគោលការណ៍ខាងលើនៅក្នុងដំណាក់កាលស៊ើបអង្កេត, ព្រះរាជអាជ្ញាត្រូវធ្វើការណែនាំដល់នគរបាលយុត្តិធម៌ទាំងអស់ដែលស្ថិតក្រោមសមត្ថកិច្ចដែនដីរបស់ខ្លួន ឱ្យអនុវត្តតាមការណែនាំខាងលើនេះ ទាំងការស្តាប់ចម្លើយ ទាំងការធ្វើកំណត់ហេតុនៃការស្តាប់ចម្លើយរបស់អនីតិជនដែលជាជនរងគ្រោះនៃបទល្មើស។

## ២-ក្នុងដំណាក់កាលស៊ើបសួរ

ចៅក្រមស៊ើបសួរ ត្រូវបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ថាមានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិតដោយអនុលោមតាមច្បាប់ ស្របតាមមាត្រា១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងស្មារតីនេះ, ចៅក្រមស៊ើបសួរ ត្រូវយកចិត្តទុកដាក់ក្នុងការអនុវត្តនីតិវិធីតាមច្បាប់ ដោយត្រូវបង្កលក្ខណៈសមស្រប ទាំងលើទិដ្ឋភាពផ្នែកសត្យានុម័ត ទាំងលើទិដ្ឋភាពផ្នែកចិត្តសាស្ត្រ ដើម្បីអនុញ្ញាតឱ្យជនរងគ្រោះជាអនីតិជនធ្វើការបំភ្លឺ និងផ្តល់ចម្លើយឱ្យបានច្បាស់លាស់ទាក់ទងនឹងអង្គហេតុនៃបទល្មើសដែលបានកើតឡើង សំដៅរកឱ្យឃើញការពិតនៅក្នុងរឿងក្តី ដោយចៀសវាងឱ្យបាននូវការផ្តល់ចម្លើយស្ថិតក្នុងស្ថានភាពតក់ស្លុត ឬភ័យខ្លាចដោយប្រការណាមួយ។ ជាមួយគ្នានេះ, ចំពោះជនរងគ្រោះជាអនីតិជនដែលស្ថិតក្នុងស្ថានភាពមិនអាចធ្វើដំណើរបាន ជាពិសេស សម្រាប់អនីតិជនដែលមានអាយុក្រោម ១០ (ដប់)ឆ្នាំយ៉ាងតិច ចៅក្រមស៊ើបសួរ អាចចុះទៅកាន់លំនៅឋាន ឬទីកន្លែងដែលជនរងគ្រោះជាអនីតិជននោះស្ថិតនៅដោយផ្ទាល់ ដើម្បីស្តាប់ចម្លើយ ឬបំពេញកិច្ចនីតិវិធីចាំបាច់ផ្សេងទៀតដោយអនុលោមតាមច្បាប់។

## ៣-ក្នុងដំណាក់កាលជំនុំជម្រះ

- ជនរងគ្រោះជាអនីតិជន អាចត្រូវបានអមដោយមេធាវី ឬអាចត្រូវបានតំណាងដោយមេធាវី ឬអ្នកតំណាងស្របច្បាប់របស់ខ្លួន ក្នុងពេលសវនាការ ស្របតាមមាត្រា៣១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងស្មារតីនេះ, បន្ថែមលើកិច្ចនីតិវិធីផ្សេងទៀតដែលបានអនុវត្តដោយតុលាការតាមក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមជំនុំជម្រះ ត្រូវជូនដំណឹងដល់មេធាវី ឬតំណាងស្របច្បាប់អំពីសិទ្ធិនេះ ដើម្បីជនរងគ្រោះចូលរួមក្នុងសវនាការដោយផ្ទាល់អមដោយវត្តមានរបស់មេធាវី ឬអាចឱ្យមេធាវីឬតំណាងស្របច្បាប់របស់ខ្លួនផ្សេងទៀតចូលរួមជំនួសក្នុងសវនាការ ដោយអនុលោមតាមមាត្រា៣១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

- ក្នុងករណីមានភាពចាំបាច់បំផុតក្នុងការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនល្មើស ក៏ដូចជាការបំភ្លឺលើចំណុចលម្អិតមួយចំនួន ដែលជាមូលដ្ឋានចាំបាច់ក្នុងការសម្តែងឱ្យឃើញការពិតក្នុងរឿងក្តី, ចៅក្រមជំនុំជម្រះ ត្រូវរៀបចំដំណើរការនីតិវិធី ដោយប្រើប្រាស់វិធីសាស្ត្រប្រយោល តាមរយៈការប្រើប្រាស់របាំង ឬរូបថត ឬប្រើប្រាស់វិធីសមស្របផ្សេងទៀត ដោយធ្វើយ៉ាងណាចៀសវាងឱ្យបានជាអតិបរមានូវការជួបតទល់ដោយផ្ទាល់រវាងជនល្មើស និងជនរងគ្រោះជាអនីតិជន ដែលអាចបង្កឱ្យជនរងគ្រោះមានការភ័យខ្លាច ឬតក់ស្លុត ដែលអាចប៉ះពាល់ដល់ការស្វែងរកការពិតផង និងប៉ះពាល់ដល់ជនរងគ្រោះខាងផ្នែកសតិអារម្មណ៍ផង។

- ដើម្បីធានាដល់ការការពារកិត្តិយស ឯកជនភាព និងចៀសវាងការបង្កនូវភាពភ័យខ្លាចដល់ជនរងគ្រោះជាអនីតិជន, ចៅក្រមជំនុំជម្រះ ត្រូវយកចិត្តទុកដាក់ពិចារណាអំពីការរៀបចំដំណើរការសវនាការជាអសាធារណៈ ស្របតាមមាត្រា៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ទទួលបានការណែនាំនេះ សូម **ឯកឧត្តម លោកជំទាវ** ដែលជា**ប្រធានសាលាដំបូង និងជាព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត** ត្រូវចាត់ចែងអនុវត្តសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាពស្របតាមគោលបំណង និងស្មារតីនៃច្បាប់ សំដៅបង្កើនប្រសិទ្ធភាពនៃយុត្តិធម៌ព្រហ្មទណ្ឌ និងពង្រឹងនីតិរដ្ឋនៅកម្ពុជា។

ថ្ងៃ ពុធ ១៣កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មករា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**ចម្លងជូន៖**

-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

-តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល

-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ទាំងអស់

-ឯកសារ កាលប្បវត្តិ

# ថ្ងៃទី០៦ ខែ មករា ឆ្នាំ២០២៣

## សម្តេចក្រឡាហោម ស ខេង ប្រាប់សមត្ថកិច្ចថា ក្រុមឧក្រិដ្ឋជន មិនទាន់បោះបង់ចោល ផែនការទុច្ចរិតរបស់ខ្លួនឡើយ

https://www.information.gov.kh/articles/94957 ចេញផ្សាយ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២៣

AKP ភ្នំពេញ ថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣៖ ទោះបីជារដ្ឋាភិបាលដាក់វិធានការទប់ស្កាត់ឧក្រិដ្ឋជនយ៉ាងណាក្តី សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងប្រាប់សមត្ថកិច្ចថា សភាពការណ៍ សន្តិសុខនៅកម្ពុជានាពេលបច្ចុប្បន្ននេះ រក្សាបានល្អប្រសើរក៏ដោយ ប៉ុន្តែពួកឧក្រិដ្ឋជន និងអ្នកប្រព្រឹត្តបទល្មើសពួកគេមិនទាន់បោះបង់ចោលនៅឡើយ ចំពោះផែនការទុច្ចរិត របស់ខ្លួនគេនោះទេ។

ថ្លែងក្នុងនាឱកាសអញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ ប្រតិភូ ប្រតិភូរង គ្រូបង្វឹក និងកីឡាករ-កីឡាការិនី នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ នាថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣ សម្តេចក្រឡាហោម ស ខេង បានរំលឹកថា កាលពីឆ្នាំ២០២២ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា បានធ្វើឱ្យប្រទេសកម្ពុជាបន្តថែរក្សាបាននូវ ពង្រឹង សន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សាធារណៈបានយ៉ាងល្អប្រសើរផងដែរ។

សម្តេចក្រឡាហោមបានបន្ថែមថា ជាពិសេសកម្ពុជារក្សាបាន និងពង្រឹងអធិប តេយ្យភាព បូរណភាពទឹកដីបានយ៉ាងល្អប្រសើរ ទាំងនេះគឺជាកត្តាគន្លឹះដ៏សំខាន់មិនអាច ខ្វះបាន ដើម្បីបង្កលក្ខណៈសម្បត្តិដល់ការអភិវឌ្ឍ និងកិច្ចដំណើរការនានាទាំងអស់របស់ កម្ពុជា។ សម្តេចបានបន្តថា កម្ពុជា ក៏នៅមានបញ្ហាប្រឈមជាច្រើនទៀតដោយសារសភាព ការណ៍អន្តរជាតិ ឬក្នុងតំបន់ កំពុងមានការវិវត្តន៍ដ៏ស្មុគស្មាញ ដោយមិនអាចប៉ានស្មានដឹង តើជះឥទ្ធិពលមកកម្ពុជាឬយ៉ាងណា? ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ នៅឆ្នាំ២០២៣នេះ ត្រូវបន្តតាមដានបន្ថែមទៀតដើម្បីការពារសន្តិភាព និងសេចក្តីសុខជូនប្រជាពលរដ្ឋ។

សម្តេច ស ខេង បញ្ជាក់ថា «សភាពការណ៍សន្តិសុខ និងបទល្មើសនានា ទោះបីមក ដល់ពេលនេះ យើងរក្សាបានល្អប្រសើរ ដូចបានបញ្ជាក់ខាងលើ ប៉ុន្តែពួកឧក្រិដ្ឋជន និងអ្នក ប្រព្រឹត្តបទល្មើស គេមិនទាន់បោះបង់ចោលនូវផែនការទុច្ចរិតរបស់ពួកគេនោះទេ។ បទល្មើស ជួញដូរមនុស្សគ្រប់ទម្រង់ ដែលជាបទល្មើសមិនប្រព្រៃណី ហើយដោយមានបែបផែនស្មុគ ស្មាញ ដែលត្រូវយើងបន្តរួមគ្នាដើម្បីធ្វើកិច្ចការងារនេះ»។ លើសពីនេះ សម្តេច ស ខេង ក៏បានណែនាំដល់សមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ត្រូវបន្ត ផ្សព្វផ្សាយជូនប្រជាពលរដ្ឋអំពីបទល្មើសនានា ឱ្យពួកគាត់បានយល់ដឹងកាន់តែច្បាស់ថែម ទៀតដូចជា៖ អំពើជួញដូរមនុស្ស ដែលជាបទល្មើសថ្មី និងស្មុគស្មាញ ព្រមទាំងកាចសាហាវផងដែរ៕ ដោយ៖ប៊ុនរិទ្ធ

## តៃប៉ិធ្វើការចោទប្រកាន់អ្នកជួញដូរមនុស្សជាថ្មី បន្ទាប់ពីជនរងគ្រោះជាច្រើននាក់ត្រូវបានជួយសង្គ្រោះពីប្រទេសកម្ពុជា

https://www.khmertimeskh.com/501214557// Khmer Times January 5, 2023

មេដឹកនាំនៃក្រុមចំនួនពីរដែលត្រូវបានចោទប្រកាន់ថា បានល្បួងជនជាតិតៃវ៉ាន់ចំនួន៨៨នាក់មកប្រទេសកម្ពុជា និងបង្ខំពួកគេឱ្យចូលរួមក្នុងការបោកប្រាស់ត្រូវបានចោទប្រកាន់ជាលើកទីពីរដោយព្រះរាជអាជ្ញាទីក្រុងតៃប៉ិ បន្ទាប់ពីជនរងគ្រោះចំនួន៣០ នាក់ទៀតត្រូវបានជួយសង្គ្រោះ និងត្រឡប់ទៅតៃវ៉ាន់វិញ។

មេដឹកនាំនៃក្រុមទាំងពីរដែលមាននាមត្រកូល Lin និង Lee ស្ថិតក្នុងចំណោមសមាជិកក្រុមចំនួនប្រាំបួនដែលត្រូវបានចោទប្រកាន់ជាលើកដំបូងនៅក្នុងខែកញ្ញា ឆ្នាំ២០២២ បន្ទាប់ពីជនរងគ្រោះ ២២ នាក់ដំបូងរបស់ពួកគេបានត្រលប់ទៅតៃវ៉ាន់វិញ។ ពួកគេត្រូវបានចោទប្រកាន់ពីបទជួញដូរមនុស្ស ប៉ុនប៉ងក្លែងបន្លំ រារាំងសិទ្ធិសេរីភាព រំលោភច្បាប់ប្រឆាំងឧក្រិដ្ឋកម្មដែលរៀបចំ និងបោកបញ្ឆោតមនុស្សឱ្យទៅបរទេសដើម្បីរកប្រាក់ចំណេញ។

ព្រះរាជអាជ្ញាក្រុងតៃប៉ិបានចោទប្រកាន់ស្រដៀងគ្នានេះប្រឆាំងនឹង Lin និង Lee កាលពីថ្ងៃពុធបន្ទាប់ពីជនរងគ្រោះចំនួន ៣០ នាក់ផ្សេងទៀតនៃក្រុមនោះ បានវិលត្រលប់មកផ្ទះវិញកាលពីពេលថ្មីៗនេះដោយមិនបានបញ្ជាក់ពីពេលវេលាណាទេ។ ទាំងព្រះរាជអាជ្ញា និងអាជ្ញាធរអនុវត្តច្បាប់ មិនបានផ្តល់នូវព័ត៌មានលម្អិតណាមួយអំពីជនរងគ្រោះទាំងបីនាក់ ដែលនៅតែមិនទាន់រាប់បញ្ចូលនៅឡើយ។

យោងតាមព្រះរាជអាជ្ញាទីក្រុងតៃប៉ិបានឱ្យដឹងថា ដោយចាប់ផ្តើមនៅចុងឆ្នាំ២០២១ ក្រុមជួញដូរមនុស្សទាំងពីរក្រុម បានធ្វើការផ្សាយពាណិជ្ជកម្មជ្រើសរើសបុគ្គលិកនៅលើ Facebook ដែលផ្តល់ការងារសេវាកម្មអតិថិជនដែលមានប្រាក់ខែខ្ពស់ក្នុងវិស័យល្បែងក្នុងប្រទេសកម្ពុជា ដើម្បីទាក់ទាញយុវជនដែលគ្មានការងារធ្វើឱ្យមកធ្វើការនៅក្នុងប្រទេសកម្ពុជា។ បន្ទាប់មកពួកគេបានលក់អ្នកដែលគេជ្រើសរើសក្នុងម្នាក់តម្លៃ ១៧,០០០ ទៅ ១៨,០០០ ដុល្លារក្នុងមនុស្សម្នាក់ទៅឱ្យក្រុមបោកប្រាស់ទូរគមនាគមន៍នៅកម្ពុជា ហើយបានបង្វែរអ្នកដែលគេជ្រើសរើសទៅក្រុមនានានៅក្នុងសួនឧស្សាហកម្មក្នុងរាជធានីភ្នំពេញ ខេត្តព្រះសីហនុ និងផ្នែកផ្សេងទៀតនៃប្រទេសកម្ពុជា។

ក្រុមបោកប្រាស់ទាំងនោះ បានឃុំខ្លួនជនរងគ្រោះប្រឆាំងនឹងឆន្ទៈរបស់ពួកគេ ហើយបង្ខំពួកគេឱ្យចូលរួមក្នុងការងារបោកប្រាស់ទូរគមនាគមន៍ នេះបើតាមរដ្ឋអាជ្ញាតៃប៉ិ។ ព្រះរាជអាជ្ញាបានឱ្យដឹងថា អ្នកដែលមិនគោរពតាម ឬអនុវត្តមិនបានល្អ ត្រូវបានគេវាយដំ ឆក់ខ្សែភ្លើង ចាក់សោរក្នុងកន្លែងបង្ខាំង ឬទារប្រាក់លោះខ្លួនខ្ពស់។ ព្រះរាជអាជ្ញាបានបង្ហាញថា ពួកគេក៏ត្រូវបានគេគំរាមកំហែងជាមួយនឹងរឿងកាត់យកសរីរាង្គរបស់គេ យកទៅកប់ទាំងរស់ ឬត្រូវគេដឹកទៅកន្លែងផ្សេងដើម្បីប្រឈមមុខនឹងស្ថានភាពកាន់តែអាក្រក់ជាងនេះ។ *Focus Taiwan*

## ពលករខ្មែរ៤នាក់ ត្រូវរថភ្លើងបុកអូសរាប់សិបម៉ែត្រ ខណៈកំពុងជិះរថយន្តទៅធ្វើការ

https://www.kampucheathmey.com/global-news/442539 ថ្ងៃព្រហស្បតិ៍ ៥ មករា ២០២៣ Sokhom Khon

ពលករខ្មែរចំនួន៤នាក់ មានសំណាងបំផុត ខណៈកំពុងជិះរថយន្តទៅធ្វើការងារត្រូវរថភ្លើងបុកពេញទំហឹង និងអូសរាប់សិបម៉ែត្រ ពេលរថយន្តឆ្លងចូលចំណុចប្រសព្វ។ ហេតុការណ៍ដ៏រន្ធត់នេះ បានកើតឡើងកាលពីព្រឹកថ្ងៃទី ៤ ខែមករា ឆ្នាំ២០២៣ ត្រង់ចំណុចផ្លូវឆ្លងកាត់មួយកន្លែង ខាងមុខវត្តលុងផាណារ៉ាម ក្នុងស្រុកមឿង ខេត្តសមុទ្រសាខន ប្រទេសថៃ។

យោងតាមការផ្សាយរបស់គេហទំព័រក្នុងស្រុកមួយចំនួនបានបញ្ជាក់ថា នៅមុនពេលកើតហេតុ គឺមានរថយន្តម៉ាកតូយូតា មួយគ្រឿង បានបើកបរឆ្លងកាត់កំណាត់ផ្លូវខ្វែងជាមួយផ្លូវរថភ្លើង ដើម្បីដឹកពលករខ្មែរទៅធ្វើការកសាងនៅវត្តលុងផាណារ៉ាម ស្របពេលដែលរថភ្លើង ខ្សែមហាឆៃ លេខ៤៣៤១ បានមកដល់ល្មម ហើយក៏បានបុកចំពាក់កណ្តាលតួរថយន្ត និងបានអូសទៅមុខរាប់សិបម៉ែត្រទើបឈប់។ ភ្លាមៗនោះដែរក្រោយពីសមត្ថកិច្ចចុះពិនិត្យគឺពុំមាននរណាម្នាក់រងរបួសឡើយ នេះជាសំណាងមួយ ក្នុងមួយពាន់គ្រោះថ្នាក់ ។ ដោយអ្នកបើកបររថយន្តឈ្មោះ សារ៉ាត់ សាគុណ ភេទប្រុស អាយុ៣៧ឆ្នាំ បាននិយាយថា ផ្លូវនេះកន្លងមកគេក៏ធ្លាប់បើកឆ្លងកាត់ដែរ តែនៅពេលនោះមានភ្នាក់ងារអោយស្ញ័យយាន ឈរអោយសញ្ញាពេលរថភ្លើងមកដល់ តែពេលនេះមិនឃើញមានអ្នកណាអោយសញ្ញាទើបគេគិតថា គ្មានរថភ្លើងឆ្លងកាត់ឡើយក៏បានបើកឆ្លងជាធម្មតា ក៏ត្រូវរថភ្លើងបុកតែម្តង គឺពេលនោះលោកហាក់គ្មានព្រលឹងក្នុងខ្លួនឡើយ។

ក្រោយការពិនិត្យគឺនៅកន្លែងឆ្លងកាត់ មានការដាក់ស្លាកសញ្ញាបញ្ជាក់ថា ត្រូវប្រុងប្រយ័ត្នរថភ្លើងឆ្លងកាត់ និងមានប៉ាយបញ្ជាក់ថា អយស្ម័យយានប្រទេសថៃ ផ្អាកការដាក់ភ្នាក់ងារពីថ្ងៃទី១ ខែកញ្ញា តទៅ ដូច្នេះសូមអ្នកធ្វើដំណើរមេត្តាប្រុងប្រយ័ត្ន ពេលរថភ្លើងឆ្លងកាត់។ ដោយការផ្អាកនេះ ត្រូវបានធ្វើឡើងនៅតាមបណ្តាខេត្ត និងតាមទីជនបទ ដោយឡែកតំបន់ឆ្លងកាត់ធំៗ គឺមានភ្លើងសញ្ញា និងរនាំងស្វ័យប្រវត្តិជដែល ដែលនេះជាបញ្ហាយ៉ាងខ្លាំងដល់អ្នកធ្វើដំណើរ នៅតាមតំបន់ដាច់ស្រយ៉ាល និងតាមទីជនបទ ៕ អត្ថបទ៖ សោ និយមវត្ថ

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ២ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិវៀតណាម ២នាក់

http://freshnewsasia.com/index.php/en/localnews/272882-2023-01-05-09-02-20.html 2023-01-05 04:02pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០៣ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន០២ករណីទៀតដែលស្នើឱ្យជួយសង្គ្រោះជនជាតិវៀតណាមចំនួន០២នាក់ ។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៦៩៤ករណី មានមនុស្ស ១,៦៨៥នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៣៩សំណើ និងបិទសំណុំរឿង ២២៣សំណើ (រកឃើញមនុស្ស ១,០៦៣នាក់, ឃាត់ខ្លួនជនសង្ស័យ ១២០នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣២ករណី។

សូមបញ្ជាក់ថា សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាត

ប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

## កម្ពុជានិងថៃ ជួបពិភាក្សាការងារ និងប្តេជ្ញារួមគ្នាទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ

https://kohsantepheapdaily.com.kh/article/1663631.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ០៥ ខែ មករា ឆ្នាំ ២០២៣ ម៉ោង ២០:៣២

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងនគរបាលវរសេនាតូច ការពារព្រំដែនគោក លេខ៨០៧ និងកម្លាំងយោធាសិករងស្រុកថ្មពួក របស់កម្ពុជា និងកម្លាំងយោធាឈុតខ្មៅថៃ កាលពីថ្ងៃទី៤ ខែមករា ឆ្នាំ២០២៣ បានពិភាក្សាការងាររវាងភាគីកម្ពុជា-ថៃ និងប្តេជ្ញារួមគ្នា ទប់ស្កាត់រាល់បទល្មើសឆ្លងដែន គ្រប់ប្រភេទ ។

លោកវរសេនីយ៍ឯក ឡុង សំណាង មេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៨០៧ បានឲ្យដឹងថា យោងតាមការណែនាំ និងការដាក់ចេញបទបញ្ជា ពីលោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ កម្លាំងនគរបាលការពារព្រំដែនគោកទាំងអស់ ត្រូវទប់ស្កាត់រាល់បទល្មើសឆ្លងដែនខុសច្បាប់គ្រប់ប្រភេទ ពង្រឹងកិច្ចសហការល្អជាមួយស្ថាប័នពាក់ព័ន្ធ និងសមត្ថកិច្ចថៃ តាមព្រំដែន ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការបំពេញការងារប្រចាំថ្ងៃ។

លោកវរសេនីយ៍ឯក ឡុង សំណាង បន្តថា លោកបានចាត់តាំងលោកអនុសេនីយ៍ត្រី អ៊ិន ធៃយ៉ា នាយរងប៉ុស្តិ៍អូរសាយ ដឹកនាំកម្លាំង ចំនួន ០៤នាក់ សហការជាមួយកម្លាំងយោធា សឹករងថ្មពួក ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ចែម ភាព មេបញ្ជាការរងកងអនុសេនាធំទី១ បានជួបពិភាក្សាការងារជាមួយ ភាគីថៃនៅគោលដៅប៉ុស្តិ៍លេខ១៤ ក្នុងទឹកដីខាងព្រំដែនថៃ ចំនួន០៥នាក់ ដឹកនាំដោយលោកអនុសេនីយ៍ទោ សាឡូត យោថា មេបញ្ជាការរង (យោធាឈុតខ្មៅថៃ) លេខ១២០៦ ដើម្បីពង្រឹងសហប្រតិបត្តិការ រួមគ្នាលុបបំបាត់ និងទប់ស្កាត់បទល្មើសគ្រប់ប្រភេទតាមព្រំដែន ។ លោកវរសេនីយ៍ឯក ឡុង សំណាង បានបញ្ជាក់ថា ជំនួបពិភាក្សានោះភាគីកម្ពុជា-ថៃ បានផ្តោតលើការងារសំខាន់ៗ រួមមាន ៖

១-ទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់គ្រប់ប្រភេទនៅតាមខ្សែបន្ទាត់ព្រំដែន ។

២-គ្រប់គ្រងទប់ស្កាត់គ្រឿងញៀនខុសច្បាប់ និងការរត់ពន្ធអាវុធ-គ្រាប់ ។

៣-រាល់ការចុះត្រួតពិនិត្យបង្គោលសីមា និងចុះគោលដៅផ្សេងៗ តាមបន្ទាត់ព្រំដែនក្នុងភូមិសាស្រ្តស្នើឲ្យមានការជូនដំណឹងជាមុន៕

## រយៈពេល៥ខែ ក្រសួងទទួលសំណើសុំអន្តរាគមន៍ជិត ៧០០ករណី

https://www.khmertimeskh.com/501215093// ហង្ស ពណ្ណរាយ January 6, 2023

គិតចាប់ពីខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២ ខែមករា ឆ្នាំ២០២៣ ក្រសួងមហាផ្ទៃ ទទួលបានសំណើសរុប ៦៩២ករណី ដែលមានមនុស្សសរុបចំនួន ១,៦៨៣នាក់ ដើម្បីសុំឱ្យរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង និងសមិត្តកិច្ចពាក់ព័ន្ធជួយអន្តរាគមន៍។

លោក ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ ប្រាប់កាសែតខ្មែរថាមស៍ កាលពីម្សិលមិញថា ចាប់តាំងពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង ប្រកាសជាសាធារណៈដល់មហាជនទូទៅអាចដាក់ពាក្យ

បណ្តឹងនានាតាមរយៈបណ្តាញសង្គមរបស់ក្រសួង ក៏ដូចជាអង្គភាពដែលជាសេនាធិការរបស់ក្រសួង។ លោក បញ្ជាក់ថា៖ «យើងចាប់ផ្តើមយុទ្ធនាការឡើងកាលពីខែសីហា ឆ្នាំ២០២២ គឺក្រសួងបានប្រកាសជាសាធារណៈ ដើម្បីទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ ហើយរហូតមកទល់ពេលនេះ យើងទទួលពាក្យបណ្តឹងពីទំព័រហ្វេសប៊ុន របស់សម្តេចក្រឡាហោមផង ទំព័រហ្វេសប៊ុកអគ្គស្នងការនគរបាលជាតិផង និងចូលតាមទំព័រហ្វេសប៊ុកអគ្គនាយក ដ្ឋានអន្តោប្រវេសន៍ផង គឺមានប្រមាណ ៦៩២ករណី»។

លោកបន្ថែមថា ថ្មីៗនេះ សមត្ថកិច្ចបានទទួលសំណើចំនួន ១ករណីបន្ថែមទៀត ដែលស្នើឱ្យជួយសង្គ្រោះ ជនជាតិហ្វីលីពីន ចំនួន ១នាក់។ លោកបន្តថា ចាប់ពីខែសីហា ២០២២ រហូតដល់ថ្ងៃទី២ ខែមករា ឆ្នាំ២០២៣ ក្រសួងមហាផ្ទៃ ទទួលពាក្យបណ្តឹងជាបន្តបន្ទាប់ ហើយការផ្តល់ឱកាសដល់មហាជនដាក់ពាក្យបណ្តឹងមកក្រសួង តាមអនឡាញនេះ គឺមានការសាទរពីប្រជាពលរដ្ឋច្រើន ជាពិសេស ជនដែលងាយរងគ្រោះ។ លោកនិយាយថា សម្រាប់សំណើក្នុងបញ្ជីតាមដានរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង គិតត្រឹមថ្ងៃទី២មករា មានអ្នកដាក់ សំណើសុំឱ្យអន្តរាគមន៍ គឺមាន ៦៩២ករណី ដែលមានជនរងគ្រោះចំនួន ១ ៦៨៣នាក់។

លោកថ្លែងថា ក្នុងចំណោមសំណើទាំង ៦៩២ករណី គឺសមត្ថកិច្ចជំនាញបានចុះស្រាវជ្រាវ និងស៊ើបអង្កេត បឋមបានចំនួន ៤៣៦សំណើ និងបានបិទសំណុំរឿង ២២៣សំណើ។ លោកបញ្ជាក់ថា ក្នុងចំណោមបិទសំណុំ រឿងនោះ គឺរកឃើញមនុស្ស ១ ០៦០នាក់ ឃាត់ខ្លួនជនសង្ស័យ ១២០នាក់ បិទក្រុមហ៊ុន ៥ទីតាំង និងផ្អាកអាជីវ កម្ម ៤ទីតាំង។ លោក ខៀវ សុភ័គ បន្ថែមថា បច្ចុប្បន្ន អាជ្ញាធរដែលជាសេនាធិការរបស់ក្រសួង គឺកំពុងបន្តបើក ប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេតចំនួន ៣៣ករណី ហើយទទួលលទ្ធផលបែបណានោះ ក្រសួងនឹងផ្សព្វផ្សាយ ជាបន្តបន្ទាប់បន្ថែមទៀត។

មន្ត្រីជាន់ខ្ពស់ស៊ើបអង្កេតនៃសមាគមសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា ហៅកាត់អាដហុក លោក ស៊ឹង សែនករុណា បានលើកឡើងថា ទិន្នន័យនៃការរាយការណ៍នេះ គឺជាទិន្នន័យដែលទទួលបានតែប៉ុណ្ណោះ ប៉ុន្តែហាក់មានជនរង គ្រោះជាច្រើនទៀត ដែលគ្មានឱកាសរាយការណ៍ គឺស្ថិតនៅក្នុងកម្រិតណាមួយដែលជួបការលំបាកក្នុងការផ្តល់ ព័ត៌មានមកដល់ក្រសួង។ លោកបន្ថែមថា បន្ទាប់ពីទទួលបានព័ត៌មានទាំងនេះ ក្រសួងគួរមានសមត្ថភាពពិសេស ណាមួយអាចចុះអន្តរាគមន៍បានទាន់សភាពការណ៍ ដើម្បីជួយដល់ជនរងគ្រោះបន្ទាប់ពីទទួលបានព័ត៌មាន ព្រោះ ធ្វើបែបនេះ គឺជៀសវាងអូសបន្លាយយូរស្រោប់តែជនរងគ្រោះ បែរជារងគ្រោះថ្នាក់បន្ថែមទៀតពីជនល្មើស៕

# ថ្ងៃទី០៩ ខែ មករា ឆ្នាំ២០២៣

## ថៃ និងកម្ពុជាសហការគ្នាប្រយុទ្ធប្រឆាំងនឹងការឆបោកតាមអ៊ីនធឺណិត

https://www.khmertimeskh.com/501215510//?p=1215510 January 7, 2023

យោងតាមលោក Chaiwut Thanakamanusorn រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងសង្គមឌីជីថល បានឱ្យដឹង ថា ក្រសួងមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការលុបបំបាត់មជ្ឈមណ្ឌលហៅទូរស័ព្ទបោកប្រាស់ទាំងនេះក្នុងរយៈ ពេលមួយឆ្នាំកន្លងមក ដោយមានជំនួយពីអាជ្ញាធរកម្ពុជា។ ប្រទេសថៃបាននឹងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយ ប្រទេសកម្ពុជា ដើម្បីបង្ក្រាបក្រុមឧក្រិដ្ឋជនតាមប្រព័ន្ធអ៊ីនធឺណែតដែលកំពុងប្រតិបត្តិការនៅកម្ពុជា ដែលបាននិង កំពុងផ្តោតគោលដៅជនរងគ្រោះនៅក្នុងប្រទេសថៃ។ ក្រុមការងារដែលមានភ្នាក់ងារមកពីប្រទេសទាំងពីរបានប្រើ ប្រាស់ព័ត៌មានពីជនរងគ្រោះដើម្បីកំណត់ទីតាំងក្រុមឧក្រិដ្ឋជន និងធ្វើការចាប់ខ្លួន ដោយបច្ចេកវិទ្យាត្រូវបានប្រើ ដើម្បីកំណត់អត្តសញ្ញាណជនសង្ស័យ និងបិទការភ្ជាប់អ៊ីនធឺណិតរបស់ពួកគេមុនពេលចាប់ខ្លួន។

លោក Chaiwut បានកត់សម្គាល់ថា កិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងប្រទេសទាំងពីរបានធ្វើឱ្យការបង្ក្រាបកាន់តែមានប្រសិទ្ធភាព ហើយត្រូវបានគេរំពឹងថានឹងកម្ចាត់ក្រុមបោកប្រាស់ទាំងនេះចេញពីកម្ពុជា ដោយថាហេតុ។ ក្រោយពីត្រូវបានចាប់ខ្លួន ជនឆបោកត្រូវបានបញ្ជូនទៅប្រទេសថៃ ដើម្បីកាត់ទោស។ ការក្លែងបន្លំដែលក្រសួងហៅថាជា "ការបោកប្រាស់កូនកាត់" ជារឿយៗពាក់ព័ន្ធនឹងការបង្កើតគណនីប្រព័ន្ធផ្សព្វផ្សាយសង្គមក្លែងក្លាយ និងគេហទំព័រដែលត្រូវបានប្រើដើម្បីបញ្ឆោតជនរងគ្រោះឱ្យផ្ទេរប្រាក់ទៅកាន់វេទិកាវិនិយោគក្លែងក្លាយ។ *Pattaya Mail /NNT*

## សមត្ថកិច្ចកម្ពុជា រកឃើញស្ត្រីជនជាតិហ្វីលីពីន ១នាក់ តាមបណ្តឹង Hotline

http://freshnewsasia.com/index.php/en/localnews/273315-2023-01-08-06-36-40.html 2023-01-08 01:36pm

**(ភ្នំពេញ)៖** សមត្ថកិច្ចជំនាញ បានស្រាវជ្រាវតាមបណ្តឹង Hotline ដោយរកឃើញស្ត្រីជនជាតិហ្វីលីពីន ១នាក់ នៅខេត្តឧត្តរមានជ័យ។ ចំពោះករណីនេះ មិនមែនជាករណីបង្ខាំង ធ្វើទារុណកម្មនោះទេ ប៉ុន្តែ ស្ត្រីជនជាតិហ្វីលីពីនរូបនេះចង់វិលត្រឡប់ទៅស្រុកកំណើតវិញ។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៦៩៤ករណី មានមនុស្ស ១,៦៨៥នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៣៩សំណើ និងបិទសំណុំរឿង ២២៣សំណើ (រកឃើញមនុស្ស ១,០៦៤នាក់, ឃាត់ខ្លួនជនសង្ស័យ ១២០នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៩ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ២៨ករណី។

សូមបញ្ជាក់ថា សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

## អភិបាលខេត្តប៉ៃលិន ប្រកាសផ្តល់ការងារ និងប្រាក់ខែដូចនៅថៃ ព្រមទាំងធានាសុវត្ថិភាពកក់ក្តៅជូនពលរដ្ឋខ្មែរ

https://kohsantepheapdaily.com.kh/article/1664887.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ០៨ ខែ មករា ឆ្នាំ ២០២៣ ម៉ោង ២០:០៧

ខេត្តប៉ៃលិន៖ លោកស្រី បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន នៅព្រលប់ថ្ងៃអាទិត្យ ទី៨ ខែមករា ឆ្នាំ២០២២ បានប្រកាសផ្តល់ការងារ និងប្រាក់ខែដូចនៅប្រទេសថៃ សម្រាប់ពលរដ្ឋខ្មែរ ដែលចង់រកការងារធ្វើ។ ក្រៅពីនោះ អភិបាលខេត្តជាប់ព្រំដែនថៃ ក៏បានធានាសុវត្ថិភាពកក់ក្តៅដល់ពលរដ្ឋខ្មែរ ដែលធ្វើការងារនៅប៉ៃលិន ដោយមិនចាំបាច់ចំណាកស្រុក ឆ្លងដែន ទៅរកការងារធ្វើនៅទឹកដី។

លោកស្រី បាន ស្រីមុំ បានប្រកាសថា «នាងខ្ញុំ សូមជូនដំណឹងចំពោះពុកម៉ែបងប្អូន ដែលមានគោលបំណង ស្វែងរកការងារក្នុងស្រុក ឬក្នុងខេត្តប៉ៃលិន មិនចាំបាច់ធ្វើចំណាកស្រុក ដោយទទួលបានប្រាក់បៀវត្សរ៍ ដូចការងារចំណាកស្រុក ធានាមានសុវត្ថិភាពកក់ក្តៅ ជួបជុំគ្រួសារ: – ក្រុមហ៊ុន ឯកជន ផ្នែករដ្ឋបាល ២នាក់ – ជំនួយការ ២នាក់ (ស្រី-ប្រុស) – ការងារមេផ្ទះ លក្ខណៈ ឯកជន ចុងភៅ អនាម័យ ថែសួន ជាច្រើននាក់។ – កំលាំងប្រមូលផលកសិកម្ម ជាច្រើននាក់ – មន្ត្រីកិច្ចសន្យារដ្ឋបាលខេត្ត ផ្នែកអនាម័យ ២នាក់ ( ស្រី-ប្រុស )។ សូមទំនាក់ទំនងលេខ : 070338337 និង098313344»។

លោកស្រីអភិបាលខេត្ត បន្ថែមថា «ចាប់ពីពេលនេះតទៅ បងប្អូនកូនក្មួយគ្រប់ស្រទាប់វណ្ណៈមានគោលបំណងស្វែងរកការងារ អាចទំនាក់ទំនង តាមលេខដាក់ជូនខាងលើ នាងខ្ញុំ និង សហការី នឹងជួយជ្រុមជ្រែង រកការងារជូនបងប្អូន នៅក្នុងស្រុក ដោយទទួលបានប្រាក់បៀវត្សរ៍សមរម្យ ដោយមិនចាំបាច់លំបាកធ្វើចំណាកស្រុកឡើយ។ សូមបញ្ជាក់ បងប្អូនមិនតំរូវការបង់សេវាអ្វីឡើយ។ ក្រុមយើងខ្ញុំ ជួយសម្របសម្រួលដោយឥតគិតថ្លៃ។ សូមអរគុណ»៕

# ថ្ងៃទី១១ ខែ មករា ឆ្នាំ២០២៣

## សម្តេច ស ខេង នឹងកោះហៅ អភិបាលរាជធានី-ខេត្ត មករាយការណ៍អំពីបទល្មើស

https://dap-news.com/national/2023/01/10/304907/ ByKD102Posted on January 10, 2023

**ភ្នំពេញ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានគម្រោងកោះហៅអភិបាលរាជធានី-ខេត្ត ម្នាក់ម្តងៗ មករាយការណ៍ជូន សម្តេច អំពីបទល្មើសនីមួយៗ ក្នុងមូលដ្ឋានរបស់ខ្លួន ដោយគ្មានការលាក់បាំងនោះឡើយ ។**

នាឱកាសអញ្ជើញបើកវេទិកា ស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល នាថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ សម្តេច ស ខេង បានគូសបញ្ជាក់ថា ពេលនេះរាជរដ្ឋាភិបាល កំពុងតែយកចិត្តទុកដាក់ ក្នុងការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងការប្រយុទ្ធប្រឆាំងនឹង បទល្មើសផ្សេងទៀត ក្នុងនោះ អំពើជួញដូរមនុស្ស គ្រប់ទម្រង់ ត្រូវបន្តធ្វើការងារដោយ មិនត្រូវទំលាក់ដៃនោះទេ។

សម្តេច បន្តថា បទល្មើសជួញដូរមនុស្ស ជាបទល្មើសមួយកើតឡើងដោយ មានភាពស្មុគស្មាញណាស់ ដូចជា៖ ការរំលោភសិទ្ធិមនុស្ស ហើយក៏មានបទល្មើសផ្សេងទៀត ដូចជា ចោរលួច ចោរប្លន់ជាដើម។ សម្តេច រំលឹកថា កាលពេលមុន ក្នុងមួយថ្ងៃជាមធ្យមទទួលបានបណ្តឹងជាង១០ ហើយមកដល់ពេលនេះក្នុងមួយថ្ងៃមាន ១បណ្តឹង

ខណៈថ្ងៃខ្លះក៏គ្មានបណ្ដឹងផងដែរ។ សម្ដេច បញ្ជាក់ថា «នេះជាលទ្ធផលដែលយើងបានដោះស្រាយ ក្នុងការជួយជនរងគ្រោះបានជាបន្តបន្ទាប់ ដែលមានបណ្ដឹងសុំឱ្យជួយ»។

លើសពីនេះ សម្ដេច ស ខេង ក៏បានណែនាំអភិបាលរាជធានី-ខេត្ត ត្រូវតែធ្វើការដោះស្រាយចំពោះពាក្យបណ្ដឹង របស់ជនរងគ្រោះឱ្យបានអស់ និងច្បាស់លាស់ ដោយមិនត្រូវទុកចោល ឬធ្វើលំៗស្រាលៗ និងផ្សំគំនិតនោះទេ។ សម្ដេច បន្ថែមថា បើសិនអភិបាលរាជធានី-ខេត្ត ឬសមត្ថកិច្ច មានការបិទបាំងបទល្មើស នៅពេលទទួលបានបណ្ដឹង ហើយមិនបានដោះស្រាយនោះ នៅថ្ងៃណាមួយ នឹងរកឃើញជាមិនខាន។

សម្ដេច បានបញ្ជាក់ទៀតថា «បើបិទបាំងមានន័យថា យើងគាំទ្រនូវអំពើទុច្ចរិត ក្នុងនោះពេលយើងចុះទៅគឺយើងហ្នឹងឃើញនូវប្រភេទបទល្មើសព្រមគ្នា បើមិនមួយ ក៏ពីរ ឬក៏បីដែរ។ បើនៅកន្លែងមួយបើកការរកស៊ីអនឡាញ សួរថាមានច្បាប់ទេ? អត់មាន នេះជាបទល្មើសមួយ មួយទៀត អ្នកធ្វើការនៅអនឡាញមាន វីសារចូលមកស្រុកចូលកម្ពុជា បើអត់មាន គឺបទល្មើសមួយទៀត។ តែបើមានវីសារទេសចរណ៍ តែមកធ្វើការនោះ ក៏ជាកំហុសមួយដែរ។ បើយើងធ្វើការលំៗ ស្រាលៗ ឱ្យតែរួចពីដៃ នៅថ្ងៃណាមួយ ខ្ញុំនឹងធ្វើគណនេយ្យភាព ត្រួតពិនិត្យ ហៅចៅហ្វាយខេត្តមករាយការណ៍ តាមករណីនីមួយៗ។ បើមន្ត្រីនគបាលធ្វើការមិនច្បាស់លាស់ គឺមិនស្មោះត្រង់ និងវិជ្ជាជីវៈ»។

សម្ដេច ឧបនាយករដ្ឋមន្ត្រី បានលើកឡើងទៀតថា រហូតមកដល់ពេលនេះ ក្រសួងមហាផ្ទៃ បានទទួលពាក្យបណ្ដឹង ៧០០ពាក្យបណ្ដឹង ហើយពាក្យបណ្ដឹងមកពីខេត្តណាចំនួនប៉ុន្មាន គឺមាននៅក្នុងបញ្ជីអស់ហើយ ដូច្នេះ មិនអាចលាក់បាំងបានឡើយ ៕

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្ដឹង ១ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិម៉ាឡេស៊ី ១នាក់

http://freshnewsasia.com/index.php/en/localnews/273430-2023-01-09-08-40-06.html 2023-01-09 03:40pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០៧ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិម៉ាឡេស៊ី ០១នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៣ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ៦៩៧ករណី មានមនុស្ស ១,៦៨៩នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៤០សំណើ និងបិទសំណុំរឿង ២២៦សំណើ (រកឃើញមនុស្ស ១,០៦៤នាក់, ឃាត់ខ្លួនជនសង្ស័យ ១២០នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣១ករណី៕

# សម្ដេចក្រឡាហោម ៖ ក្រសួងមហាផ្ទៃទទួលពាក្យបណ្ដឹង ៧០០ពាក្យបណ្ដឹង នឹងគ្រោងកោះហៅអភិបាលរាជធានី-ខេត្ត ធ្វើរបាយការណ៍បទល្មើសនានា

https://www.information.gov.kh/articles/95198 ចេញផ្សាយ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២៣

សម្ដេចក្រឡាហោម ស ខេង ឧបកនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាក់ថា ក្រសួងមហាផ្ទៃបានទទួលពាក្យបណ្ដឹង ៧០០ពាក្យបណ្ដឹង នឹងគ្រោងកោះហៅអភិបាលរាជធានី-ខេត្ត មកធ្វើរបាយការណ៍ជូនសម្ដេចដោយគ្មានលាក់បាំង។ ការបញ្ជាក់របស់សម្ដេចក្រឡាហោម ស ខេង ធ្វើឡើងក្នុងវេទិកាស្ដីពីភាពជាដៃគូ រវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល នាព្រឹកថ្ងៃអង្គារ ៤រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១០ មករាឆ្នាំ២០២២នេះ នៅសណ្ឋាគារសុខា។

សម្ដេចក្រឡាហោម ស ខេង បានលើកឡើងថា ក្នុងមួយថ្ងៃជាមធ្យមយើងទទួលបាន បណ្ដឹងជាង១០ ចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២មក ហើយមកដល់ពេលនេះក្នុងមួយថ្ងៃ មាន ១បណ្ដឹង ឬក៏គ្មានបណ្ដឹងផងដែរ។ សម្ដេចបញ្ជាក់ថា « នេះជាលទ្ធផលដែលយើងបាន ដោះស្រាយក្នុងការជួយជនរងគ្រោះបានជាក់លាក់ បន្ទាប់ពីមានបណ្ដឹងសុំឱ្យជួយ »។ សម្ដេចក៏បានឱ្យអភិបាលរាជធានី-ខេត្ត ត្រូវតែធ្វើការដោះស្រាយចំពោះពាក្យបណ្ដឹងរបស់ជនរងគ្រោះថា ឱ្យបានអស់និងច្បាស់លាស់ ដោយមិនត្រូវទុកចោល ឬធ្វើលំៗស្រាលៗ និងផ្សំគំនិតនោះទេ។ ជាមួយគ្នានោះដែរសម្ដេចក្រឡាហោម បានព្រមានថា បើសិនអភិបាលរាជធានី-ខេត្ត សមត្ថកិច្ច មានការបិទបាំងបទល្មើស នៅពេលទទួលបានបណ្ដឹងហើយ មិនបានដោះស្រាយ ថ្ងៃណាមួយនឹងរកឃើញជាមិនខាន ហើយការបិទបាំងមានន័យថា យើងគាំទ្រនូវអំពើទុច្ចរិត ក្នុងនោះពេលយើងចុះទៅ គឺយើងហ្នឹងឃើញនូវប្រភេទបទល្មើសព្រមគ្នា បើមិនមួយក៏ពីរឬក៏បីដែរ»។ សម្ដេចបានលើកជាឧទាហរណ៍ថា បើនៅកន្លែងមួយបើកការរកស៊ីអនឡាញសួរថាមានច្បាប់ទេ? បើអត់មាន នេះជាបទល្មើសមួយ។ មួយទៀតអ្នកធ្វើការនៅអនឡាញមានវីសារចូលមកកម្ពុជា បើអត់មានគឺបទល្មើសមួយទៀត ។ តែបើមានវីសារទេសចរណ៍ តែមកធ្វើការនោះក៏ជាកំហុសមួយដែរ។ ជាមួយគ្នានោះដែរសម្ដេច ក៏បានឱ្យដឹងថា បើសិនអភិបាល រាជធានី-ខេត្ត នៅតែធ្វើការលំៗស្រាលៗឱ្យតែរួចពីដៃ នៅថ្ងៃណាមួយសម្ដេចនឹងកោះហៅមកត្រួតពិនិត្យ និងឱ្យធ្វើរបាយការណ៍ជូនសម្ដេច តាមករណីនីមួយៗតែម្ដង។

សម្ដេចក្រឡាហោមលើកឡើងថា រហូតមកដល់ពេលនេះ ក្រសួងមហាផ្ទៃបានទទួលពាក្យបណ្ដឹង ៧០០ពាក្យបណ្ដឹង ហើយពាក្យបណ្ដឹងមកពីខេត្តណាចំនួនប៉ុន្មាន? គឺមាននៅក្នុងបញ្ជីអស់ហើយ ដូច្នេះមិនអាចលាក់បាំងកើតនោះទេ។ សម្ដេចបញ្ជាក់ថា «អីចឹងហើយនឹងធ្វើគណនេយ្យភាព ហៅមកពិនិត្យតាមខេត្តនីមួយៗមកបញ្ជាក់លម្អិត ឱ្យច្បាស់លាស់ ហ្មត់ចត់។ បើមន្ត្រីនគរបាលធ្វើការមិនច្បាស់លាស់ គឺមិនស្មោះត្រង់នឹងវិជ្ជាជីវៈ »។ សម្ដេចឧបកនាយរដ្ឋមន្ត្រី ស ខេង បានគូសបញ្ជាក់ថា ពេលនេះរាជរដ្ឋាភិបាល បាននិងកំពុងតែយកចិត្តទុកដាក់ក្នុងការរក្សាសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងការប្រយុទ្ធ ប្រឆាំងនឹងបទល្មើសផ្សេងទៀត។ ក្នុងនោះអំពើជួញដូរមនុស្សគ្រប់ទម្រង់ ត្រូវបន្តធ្វើការងារហ្នឹងមិនត្រូវទម្លាក់ដៃនោះទេ។ សម្ដេចបន្តថា បទល្មើសជួញដូរមនុស្ស ជាបទល្មើសមួយកើតឡើងមានភាពស្មុគស្មាញណាស់ ហើយជាការរំលោភសិទ្ធិមនុស្សផង ហើយក៏មានបទល្មើសផ្សេងទៀតដូចជា ចោរលួច ចោរប្លន់ ផងដែរ៕ ដោយអ៊ាង ប៊ុនរិទ្ធ សម្រួលផ្សាយដោយ៖ ធូ កុសល

# មន្ត្រីជាន់ខ្ពស់សង្គមកិច្ចៈ មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត នឹងសាងសង់រួចរាល់នៅអំឡុងដើមខែសីហា ឆ្នាំ២០២៣

http://freshnewsasia.com/index.php/en/localnews/273517-2023-01-10-05-16-37.html 2023-01-10 12:16pm

**(បន្ទាយមានជ័យ)៖** លោក ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាតំណាងលោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានឲ្យដឹងថា មជ្ឈមណ្ឌលសំចត ប៉ោយប៉ែតនេះចាប់ផ្តើមសាងសង់នៅថ្ងៃទី១៥ សីហា ឆ្នាំ២០២២ រហូតមកដល់ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ សម្រេចបានលទ្ធផលចំនួន ៣៣.១៨ភាគរយ ហើយគម្រោងទាំងមូល នឹងបញ្ចប់រួចរាល់នៅអំឡុងដើមខែសីហា ឆ្នាំ២០២៣ ដែលចំណាយជាង ២.៣ លានដុល្លារ។ លោកបានបន្ថែមថា ភាគីថៃបានទទួលយកសំណើរបណ្តុះបណ្តាលមន្ត្រីជំនាញកម្ពុជា សម្រាប់បម្រើការងារបណ្តុះបណ្តាល នៅក្នុងមជ្ឈមណ្ឌលនេះរយៈពេល៦ខែ គឺចាប់ពីខែមីនា រហូតដល់ខែសីហា ឆ្នាំ២០២៣។

ការលើកឡើងរបស់លោក ញ៉ឹក វណ្ណារ៉ា បានធ្វើឡើងខណៈលោក និងគណៈប្រតិភូថៃ ចុះពិនិត្យមើលគម្រោងសាងសង់សំណង់អគារមជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នៅព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣។ ដំណើរចុះត្រួតពិនិត្យនេះអមដំណើរដោយអនុរដ្ឋលេខាធិការ ទីប្រឹក្សា ប្រធាននាយកដ្ឋានកាំពារជនរងគ្រោះ លោកស្រីប្រធានមជ្ឈមណ្ឌលសំចតប៉ោយប៉ែត និងលោកអនុប្រធានមន្ទីរសង្គមកិច្ចខេត្ត ហើយមានការចូលរួមពីអភិបាល ក្រុងប៉ោយប៉ែត និងអភិបាលរងខេត្តបន្ទាយមានជ័យផងដែរ។

រីឯគណៈប្រតិភូថៃ ដឹកនាំដោយអគ្គរាជទូតថៃប្រចាំកម្ពុជា អមដំណើរដោយលេខាទូតទី១ មន្ត្រីបច្ចេកទេសពាក់ព័ន្ធ តំណាងក្រុមសាងសង់ថៃ បានសហការរួមគ្នាចុះត្រួតពិនិត្យការដ្ឋានសាងសង់សំណង់មជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីសម្រួលដល់ពលករចំណាកស្រុកស្នាក់នៅប្រកបដោយផាសុខភាពនិងសុវត្ថិភាព បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បន្ថែមទៀតពិសេសបង្កើនកិច្ចការពារទប់ស្កាត់ជំងឺកូវីដ១៩។ ឆ្លៀតក្នុងឱកាសនោះ អគ្គរាជទូតថៃប្រចាំកម្ពុជា បានលើកឡើងថា ការសាងសង់មណ្ឌលនេះរួមចំណែក ជួយដល់ជនរងគ្រោះ មានសង្ឃឹមក្នុងជីវិតសារជាថ្មី ដោយមានការផ្តល់ជំនាញបណ្តុះបណ្តាលផ្សេងៗ។

បន្ថែមពីលើនេះលោក ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច បានថ្លែងអំណរគុណដល់ អគ្គរាជទូតថៃ ដែលបានជំរុញក្នុងការសាងសង់មណ្ឌលនេះ និងបានចូលរួមពិនិត្យលទ្ធផលការងារសាងសង់ ហើយសង្ឃឹមថា នៅពេលដែលមជ្ឈមណ្ឌល សាងសង់រួច និងបានបម្រើផលប្រយោជន៍ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស៕

# ថ្ងៃទី១៣ ខែ មករា ឆ្នាំ២០២៣

## កម្ពុជាប្រគល់ជនសង្ស័យ៩នាក់ក្នុងករណីឆបោកទៅប្រទេសចិន

https://www.khmertimeskh.com/501218545// Khmer Times January 12, 2023

ក្រសួងសន្តិសុខសាធារណៈបាននិយាយកាលពីថ្ងៃពុធថា មនុស្ស៩នាក់ដែលត្រូវបានសង្ស័យថាបានរៀបចំប្រតិបត្តិការទូរគមនាគមន៍ និងក្លែងបន្លំតាមអ៊ីនធឺណិតត្រូវបាននគរបាលកម្ពុជាចាប់ខ្លួននាពេលថ្មីៗនេះ ហើយប្រគល់ទៅឱ្យអាជ្ញាធរចិន។ ប្រភពដដែលបាននិយាយថាអ្នកទាំង៩នាក់ត្រូវបានសង្ស័យនៅក្នុងករណីពាក់ព័ន្ធនឹងទឹកប្រាក់សរុបជាង ១៤.៧ លានដុល្លារ ។ ខណៈដែលកំពុងស៊ើបអង្កេតករណីក្លែងបន្លំតាមប្រព័ន្ធទូរគមនាគមន៍ អង្គភាពសន្តិសុខសាធារណៈបានរកឃើញថាប្រតិបត្តិការក្លែងបន្លំមួយចំនួនមានទីតាំងនៅក្នុងប្រទេសកម្ពុជា។

សួងបានដាក់ជនទាំងនោះនៅក្នុងបញ្ជីកំពុងតាមចាប់ក្នុងយុទ្ធនាការពិសេសមួយ ដែលបានចាប់ផ្តើមកាលពីខែមិថុនា ដែលមានគោលបំណងបង្ក្រាបក្រុមបោកប្រាស់តាមប្រព័ន្ធទូរគមនាគមន៍។ កិច្ចសហប្រតិបត្តិការតាមរយៈ នគរបាលអន្តរជាតិ ចិន និងកម្ពុជាទទួលបានភស្តុតាងមួយចំនួនធំប្រឆាំងនឹងក្រុមឆបោកទាំងនេះ។ ក្រៅពីជនសង្ស័យទាំង ៩នាក់នោះ មានជាង ១០នាក់ផ្សេងទៀតបានបានប្រគល់ខ្លួន និងស្ម័គ្រចិត្តត្រឡប់ទៅប្រទេសចិនវិញ ។ រហូតមកដល់ពេលនេះ ជនសង្ស័យសរុប ២៤នាក់ត្រូវបានចាប់ខ្លួនពីបទពាក់ព័ន្ធនឹងក្រុមនេះ។ ចាប់តាំងពីការចាប់ផ្តើមយុទ្ធនាការនេះ ក្រសួងបានដាក់មនុស្សប្រហែល៤៩០ នាក់នៅក្នុងបញ្ជីតាមចាប់ ហើយប្រហែល ២៤០ នាក់ត្រូវបានចាប់ខ្លួន៕ *China Daily*

# ថ្ងៃទី១៦ ខែ មករា ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្តឹង ១ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិចិន ២នាក់

http://freshnewsasia.com/index.php/en/localnews/274045-2023-01-13-10-17-10.html 2023-01-13 05:17pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១១ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិចិន ចំនួន ០២នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៧០១ករណី មានមនុស្ស ១,៦៩៩នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៤០សំណើ និងបិទសំណុំរឿង ២៣១សំណើ (រកឃើញមនុស្ស ១,០៦៤នាក់, ឃាត់ខ្លួនជនសង្ស័យ ១២០នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣០ករណី៕

# ថ្ងៃទី១៨ ខែ មករា ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ១ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិហ្វីលីពីន ៨នាក់

http://freshnewsasia.com/index.php/en/localnews/274617-2023-01-17-09-46-31.html 2023-01-17 04:46pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៥ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិហ្វីលីពីន ចំនួន ០៨នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៧០៤ករណី មានមនុស្ស ១,៧២០នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៤១សំណើ និងបិទសំណុំរឿង ២៣២សំណើ (រកឃើញមនុស្ស ១,០៦៦នាក់, ឃាត់ខ្លួនជនសង្ស័យ ១២០នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣១ករណី៕

## មន្ត្រី៖ ការសាងសង់មជ្ឈមណ្ឌល
## សំចតសម្រាប់ពលករនៅប៉ោយប៉ែត សម្រេចបានជាង ៣៣ ភាគរយ

https://www.postkhmer.com/national/2023-01-16-1722-245967.html សែម ពិសី | Publication date 16 January 2023 | 17:22 ICT

**បន្ទាយមានជ័យៈ** មន្ត្រីជាន់ខ្ពស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានឱ្យដឹងថា ដំណើរការសាងសង់មជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីទុកបម្រើផលប្រយោជន៍ដល់ពលករចំណាកស្រុកពិសេសជនរងគ្រោះដោយអំពើជួញដូរមនុស្សព្រមទាំងបណ្តុះបណ្តាលជំនាញដល់ពលកររហូតមកទល់ពេលនេះសម្រេចបានជាង ៣៣ភាគរយហើយ។ រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា លោក ញឹក វណ្ណារ៉ា បានថ្លែងប្រាប់អ្នកកាសែតនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ថា រូបលោកនិងមន្ត្រីជំនាញរបស់ក្រសួងព្រមទាំងឯកអគ្គរាជទូតថៃប្រចាំកម្ពុជា និងសហការីបានចុះទៅពិនិត្យការដ្ឋានសាងសង់មជ្ឈមណ្ឌលសំចតស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត កាលពីសប្តាហ៍មុន។ លោកបានថ្លែងថា៖«បច្ចុប្បន្នសម្រេចការសាងសង់បានជាង៣៣ភាគរយហើយ។មជ្ឈមណ្ឌលសំចតប៉ោយប៉ែតនេះ គឺមានអត្ថប្រយោជន៍ដើម្បីសម្រួលដល់ពលករចំណាកស្រុក ជាពិសេសបង្កើនផាសុកភាព និងសុវត្ថិភាពបន្ថែមទៀត។ម្យ៉ាងទៀតក្រុមការងារបានចុះពិនិត្យទីតាំងសាងសង់ និងពិនិត្យកន្លែងផលប៉ះពាល់ ដើម្បីសម្របសម្រួលរកដំណោះស្រាយផងដែរ ធ្វើយ៉ាងណាពន្លឿនគម្រោងនេះឱ្យបញ្ចប់តាមផែនការគ្រោងទុក»។ លោករដ្ឋលេខាធិការបានបញ្ជាក់ថា នៅក្នុងដំណើរចុះពិនិត្យការដ្ឋានសាងសង់នោះភាគីថៃក៏បានទទួលយកសំណើសុំការបណ្តុះបណ្តាលមន្ត្រីជំនាញកម្ពុជាសម្រាប់បម្រើការងារ ដែលនឹងអនុវត្តនៅក្នុងមជ្ឈមណ្ឌលនេះ រយៈពេល៦ខែ ដោយគិតចាប់ពីខែមីនា រហូតដល់ខែសីហា ឆ្នាំ២០២៣។

ពាក់ព័ន្ធនឹងការសាងសង់មជ្ឈមណ្ឌលសំចតប៉ោយប៉ែតនេះ លោក ធីតកៀត អាត់ថាកន (Cherdkiat ATTHAKOR) ឯកអគ្គរាជទូតថៃប្រចាំកម្ពុជាបានលើកឡើងថា ការសាងសង់មណ្ឌលនេះនឹងរួមចំណែកជួយដល់

ជនរងគ្រោះឱ្យមានសង្ឃឹមក្នុងជីវិតសាជាថ្មី ដោយមានការផ្តល់ជំនាញបណ្តុះបណ្តាលផ្សេងៗ។ ទន្ទឹមគ្នានេះ លោកក៏បានគាំទ្រនិងជំរុញការសាងសង់មជ្ឈមណ្ឌលឱ្យសម្រេចជោគជ័យ ដោយលោករំពឹងថា នៅពេលមជ្ឈមណ្ឌលនេះសាងសង់រួចនឹងបម្រើផលប្រយោជន៍ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សទៀតផង។

តាមរបាយការណ៍របស់ក្រសួងសង្គមកិច្ចបានបង្ហាញថា មជ្ឈមណ្ឌលសំចតប៉ោយប៉ែតនេះបានចាប់ផ្តើមបើកការដ្ឋានសាងសង់កាលថ្ងៃទី១៥ សីហា ឆ្នាំ២០២២ ដែលគិតមកទល់ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ សម្រេចបានលទ្ធផលចំនួន៣៣,១៨ភាគរយនៃគម្រោងទាំងមូល។ មជ្ឈមណ្ឌលនេះគ្រោងនឹងបញ្ចប់ការសាងសង់ឱ្យរួចជាស្ថាពរនៅអំឡុងដើមខែសីហា ឆ្នាំ២០២៣ ដោយគ្រោងចំណាយថវិកាសរុបជាង២,៣លានដុល្លារអាមេរិក។

លោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ធ្លាប់បានលើកឡើងដែរថា ការបង្កើតមណ្ឌលសំចត សម្រាប់ជួយជនរងគ្រោះពីការជួញដូរឆ្លងដែននៅតាមច្រកព្រំដែនពិតជាមានសារៈសំខាន់ណាស់និងបានចូលរួមចំណែកការងារសង្គមកិច្ចក្នុងការទទួលមើលការខុសត្រូវលើជនងាយរងគ្រោះ។ ទន្ទឹមគ្នានេះ មជ្ឈមណ្ឌលនេះ ក៏នឹងរួមចំណែកជួយប្រជាពលរដ្ឋ ពិសេសអ្នកឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់មកវិញ ឱ្យមានកន្លែងស្នាក់នៅបានល្អប្រសើរ សមរម្យ និងមានសុខសុវត្ថិភាពជាងមុន៕

## មន្ត្រីជាន់ខ្ពស់កម្ពុជា-ថៃ ប្រជុំរួមគ្នាលើការគ្រប់គ្រងជនរងគ្រោះដែលធ្វើមាតុភូមិនិវត្ត និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស

http://freshnewsasia.com/index.php/en/localnews/274639-2023-01-17-13-38-04.html 2023-01-17 08:38pm

**(សៀមរាប)៖** ភាគីកម្ពុជា-ភាគីថៃ នាថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣នេះ បានរៀបចំកិច្ចប្រជុំទ្វេភាគីស្តីពីបញ្ចប់សេចក្តីព្រាងឧបសម្ពន្ធផែនការសកម្មភាព នៃនីតិវិធីប្រតិបត្តិបទដ្ឋានសម្រាប់ការគ្រប់គ្រងការធ្វើមាតុភូមិនិវត្ត និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

លោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាងលោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច បានឱ្យដឹងថា កិច្ចប្រជុំនេះពិតជាមានសារសំខាន់ក្នុងការទំនាក់ទំនងចំណងមិត្តភាពកម្ពុជា និងថៃ ក្នុងកិច្ចសហប្រតិបត្តិការលុបបំបាត់ កាត់បន្ថយ ផ្តល់សេវាស្តារនីតិសម្បទា ការសម្របសម្រួលធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ពីព្រោះប្រទេសទាំងពីរគឺជាប្រទេសជាប់របងនឹងគ្នា។ លោកបានបន្តថា អំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើមនុស្សបានកើតឡើង និងកំពុងរីកសាយភាយគ្រប់ទីកន្លែង គ្រប់រូបភាពភាគច្រើនជាឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង ហើយឧក្រិដ្ឋកម្មនេះបានធ្វើឲ្យប៉ះពាល់ទាំងថ្នាក់ជាតិ តំបន់ និងលើពិភពលោក។ បញ្ហានេះប្រទេសកម្ពុជាបាននិងកំពុងបង្កើត រៀបចំ ចងក្រងផ្សព្វផ្សាយ អនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងយន្តការនានាសំដៅប្រយុទ្ធប្រឆាំង និងចូលរួមកាត់បន្ថយឲ្យបានជាអតិបរិមានូវអំពើជួញដូរមនុស្សទាំងក្នុងក្របខ័ណ្ឌជាតិ តំបន់ និងលើពិភពលោក ពិសេសជាងនោះទៅទៀត ការសម្របសម្រួលក្នុងការកំណត់អត្តសញ្ញាណបឋម ការផ្តល់សេវាការរៀបចំធ្វើមាតុភូមិនិវត្តន៍ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស គឺជាចំណុចដ៏សំខាន់ដែលប្រទេសជាម្ចាស់ហត្ថលេខីទាំងអស់នៃសន្ធិសញ្ញាស្តីពីការលុបបំបាត់ និងបង្ក្រាបអំពើជួញដូរមនុស្សត្រូវតែអនុវត្តឲ្យបានពេញលេញ និងផ្តល់សេវាដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្សដោយមិនប្រកាន់ និន្នាការជាតិពន្ធុនោះឡើយ។

«ហេតុដូច្នេះហើយទើបថ្ងៃនេះយើងជួបគ្នាដើម្បីប្រជុំបញ្ចប់សេចក្តីព្រាងឧបសម្ពន្ធផែនការសកម្មភាព នៃនីតិវិធីប្រតិបត្តិបទដ្ឋានសម្រាប់ការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្ត និងសមាហរណកម្មជនរងគ្រោះដោយ

អំពើជួញដូរមនុស្សរវាងកម្ពុជា និងថៃ»។ លោក ញ៉ឹក វណ្ណារ៉ា បន្ថែម។ ជាមួយគ្នានេះ លោករដ្ឋលេខាធិការសង្ឃឹមយ៉ាងមុតមាំថា កិច្ចប្រជុំថ្ងៃនេះនឹងក្លាយជាយានមួយដ៏មានសារសំខាន់ ក្នុងការអនុវត្តការងារជាក់ស្តែងប្រកបដោយប្រសិទ្ធភាពខ្ពស់ និងជាជំនួយស្មារតីដល់អ្នកផ្តល់សេវាថៃទាំងជនរងគ្រោះ ពិសេសការកំណត់អត្តសញ្ញាណបឋម ការផ្តល់សេវា និងការសម្របសម្រួលក្នុងការធ្វើមាតុភូមិនិវត្តជនរងគ្រោះនៃជនជាតិទាំងពីរប្រទេស គឺកម្ពុជា និងថៃ៕

## សមត្ថកិច្ចឃាត់ខ្លួនស្ត្រីម្នាក់ម្ចាស់ទីតាំងហាងម៉ាស្សាបង្កប់សេវាផ្លូវភេទ និងនារីរងគ្រោះចំនួន០៨នាក់

http://nokorwatnews.com/archives/954455 17/01/2023

ភ្នំពេញ ៖ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន សហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះបង្ក្រាប ជាក់ស្តែងករណីប្រព្រឹត្តិ អំពើសញ្ញារកម្ម បើកហាងម៉ាស្សាបង្កប់បំរើសេវាផ្លូវភេទ ដោយបានឃាត់ខ្លួនម្ចាស់ទីតាំងម្នាក់ និង នារីរងគ្រោះចំនួន ០៨នាក់ ក្នុងនោះមានអនីតិជនចំនួន០៣នាក់ និងវត្ថុតាងស្រោមអនាម័យប្រើប្រាស់រួចមួយចំនួននិងមិនទាន់ប្រើប្រាស់មួយចំនួន។ ដោយមានការចង្អុលបង្ហាញពីលោក ឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរងនិងជាស្នងការនគរបាលរាជធានីភ្នំពេញ និង លោក ឧត្តមសេនីយ៍ទោ ចាន់ កិត្តិខុម ស្នងការរងទទួលផែនការងារប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ក្រោមការសម្របសម្រួលដោយលោក សិត វណ្ណៈ ព្រះរាជអាជ្ញារង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងលោក វរសេនីយ៍ទោ ហាក់ លី នាយការិយាល័យ បានដឹកបញ្ជាផ្ទាល់ ធ្វើការឃាត់ខ្លួនស្ត្រីម្ចាស់ទីតាំងម្នាក់ និងនារីរងគ្រោះ ក្មេងៗចំនួន០៨នាក់ នៅវេលាម៉ោង០៩និង១០នាទី យប់ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ ចំណុចហាងម៉ាស្សាកោសជប់យីហោ«៩៩៩៩» ស្ថិតនៅផ្ទះគ្មានលេខ ចំណុចចុងស្ពានព្រែកព្នៅខាងលិច ផ្លូវវិមានឈ្នះៗ ភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

ស្ត្រីជាម្ចាស់ទីតាំងមានឈ្មោះ សេក មុំ អាយុ៤០ឆ្នាំ ស្ថិតនៅផ្ទះគ្មានលេខ ផ្លូវវិមានឈ្នះៗ ភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ តាមប្រភពបានឲ្យដឹងថា ទីតាំងហាងម៉ាស្សាកោសជប់យីហោ«៩៩៩៩» មានស្ត្រីម្នាក់ ជាម្ចាស់ទីតាំង នៅក្នុងហាងមានស្រីៗរង់ចាំទទួលភ្ញៀវម៉ាស្សា និងរួមភេទ ចំនួន ០៨នាក់ សង្ស័យអនីតិជន ០៣នាក់និងមានបន្ទប់សម្រាប់រួមភេទចំនួន ០៤បន្ទប់ តម្លៃម៉ាស្សាធម្មតា ២.០០០០រៀល ក្នុងមួយម៉ោង និងតម្លៃនៃការរួមភេទក្នុងមួយដងចាប់ពី ២០$ ទៅ ២៥$ ហើយលុយដែលបានមកពីការ រួមភេទ គឺម្ចាស់ទីតាំងចែកស្មើគ្នាជាមួយស្រីៗម៉ាស្សាទាំងនោះ។ ប្រភពដដែលបានឲ្យដឹងថា ហាងម៉ាស្សានេះ បើក ដំណើរការរកស៊ីទទួលភ្ញៀវចាប់ពីម៉ោង ០៥ល្ងាច រហូតដល់ យប់អធ្រាត្រទើបបិទទ្វារ រីឯនារីដែលសង្ស័យជាអនីតិជនចំនួន ០៣នាក់ គឺចូលមកបម្រើការងារចាប់ពីម៉ោង ០៧យប់ រហូតដល់ម៉ោង ០៩យប់ ។

ក្រោយប្រតិបត្តិការកម្លាំងជំនាញបាននាំខ្លួនស្ត្រីម្ចាស់ទីតាំង ទៅការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន ដើម្បីសួរនាំកសាងសំណុំរឿង ចាត់ការតាមនីតិវិធី។ ចំណែកនារីរងគ្រោះទាំង០៨នាក់ត្រូវបានប្រគល់ជូនមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញធ្វើការអប់រំ ៕

# ម៉ាឡេស៊ីពន្លឿនការជ្រើសរើសពលករបរទេសសម្រាប់ការស្តារសេដ្ឋកិច្ចឡើងវិញ

https://www.information.gov.kh/articles/95735 ចេញផ្សាយ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០២៣

រដ្ឋមន្ត្រីក្រសួងធនធានមនុស្សរបស់ប្រទេសម៉ាឡេស៊ី លោក វី ស៊ីវ៉ាគូម៉ារ បាននិយាយកាលពីថ្ងៃទី១៦ ខែមករាថា ការរំពឹងទុកក្នុងការចូលទៅក្នុងប្រទេសម៉ាឡេស៊ីរបស់ពលករបរទេសចំនួន ៥០០ ០០០នាក់នៅក្នុងឆ្នាំនេះនឹងមិនប៉ះពាល់ដល់ឱកាសការងារសម្រាប់អ្នកក្នុងស្រុកនោះទេ។ ដូចដែលត្រូវបានរាយការណ៍ដោយទីភ្នាក់ងារសារព័ត៌មានក្នុងស្រុក Bernama មន្ត្រីរូបនេះបាននិយាយថា ពលករមកពីប្រទេសចំនួន១៥ នៅអាស៊ី នឹងត្រូវដាក់ឱ្យធ្វើការងារនៅក្នុងវិស័យមួយចំនួនដែលមិនត្រូវការពលករក្នុងស្រុក ដែលរួមមានការងារចម្ការ កសិកម្ម និងសំណង់។

យោងតាមរូបលោកបានឱ្យដឹងថា ការពឹងផ្អែករបស់ប្រទេសម៉ាឡេស៊ីទៅលើពលករបរទេសក្នុងវិស័យទាំងនោះគឺមានកម្រិតខ្ពស់ណាស់ ហើយបើគ្មានការផ្គត់ផ្គង់គ្រប់គ្រាន់សម្រាប់ក្រុមនោះទេ ប្រតិបត្តិការដ៏ល្អប្រសើររបស់ពួកគេនឹងត្រូវរំខានដែលបណ្តាលឱ្យមានការខាតបង់យ៉ាងច្រើន។ លោកបាននិយាយថា ក្រសួងធនធានមនុស្ស និងក្រសួងមហាផ្ទៃរបស់ប្រទេសម៉ាឡេស៊ី បានឈានដល់កិច្ចព្រមព្រៀងមួយដើម្បីសម្រួល និងពន្លឿនដំណើរការជួលពលករបរទេស ដែលពេលនេះមានរយៈពេលត្រឹមតែ ៣ថ្ងៃប៉ុណ្ណោះ។

កាលពីខែតុលាឆ្នាំមុន ប្រទេសម៉ាឡេស៊ីត្រូវការពលករបរទេសសរុបចំនួន ៥០០ ០០០នាក់ ដើម្បីដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្មដែលជួបប្រទះដោយសហគ្រាសមីក្រូ សហគ្រាសធុនតូច និងមធ្យម ដើម្បីគាំទ្រដល់ដំណើរការស្តារសេដ្ឋកិច្ចឡើងវិញរបស់ប្រទេសនេះបន្ទាប់ពីជំងឺរាតត្បាតកូវីដ១៩៕

# ថ្ងៃទី២០ ខែ មករា ឆ្នាំ២០២៣

## សម្តេច ស ខេង

## ប្រាប់UN ថាការជួញដូរមនុស្ស ជាបញ្ហាស្មុគស្មាញ មិនមែនមានតែនៅកម្ពុជានោះទេ

https://dap-news.com/national/2023/01/19/306802/ ByDR103 Posted on January 19, 2023

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងប្រាប់មន្ត្រីអង្គការសហប្រជាជាតិ (UN) ថា បញ្ហាជួញដូរមនុស្ស គឺជាបញ្ហាដែលស្មុគស្មាញ ហើយមិនមែនមានតែនៅកម្ពុជានោះទេ គឺមាននៅលើសកលលោក ដូច្នេះរួមគ្នាដោះស្រាយផងដែរ។ នាឱកាសអនុញ្ញាតជូនលោក Joseph Scheuer អ្នកសម្របសម្រួល នៃអង្គការសហប្រជាជាតិ ប្រចាំកម្ពុជា ទើបតែងតាំងថ្មី ចូលជួបសម្តែងការគួរសម នារសៀលថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ សម្តេចក្រឡាហោម ស ខេង បានថ្លែងថា ពាក់ព័ន្ធទៅនឹងបទល្មើស ជួញដូរមនុស្សនេះជាបទល្មើសមិនប្រពៃណីមួយ ដែលរាជរដ្ឋាភិបាលកម្ពុជា និងសម្តេចផ្ទាល់ ត្រូវទទួលភារកិច្ចដឹកនាំការងារនេះ និងនៅតែបន្តយកចិត្តទុកដាក់អនុវត្តការងារនេះ ព្រោះពុំទាន់មានការបិទបញ្ចប់នោះទេ គឺនៅតែបន្តធ្វើរហូតមកដល់បច្ចុប្បន្ន។

សម្តេច បញ្ជាក់ទៀតថា «បញ្ហានេះជាបញ្ហាមួយដែលស្មុគស្មាញ ហើយមិនមែនតែមាននៅកម្ពុជានោះទេ គឺនៅលើសកលលោកទាំងមូល និងទាមទារឲ្យមានកិច្ចសហប្រតិបត្តិការជាមួយគ្នារវាងអាជ្ញាធរពាក់ព័ន្ធ ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងនឹងបទល្មើសនេះ»។ លើសពីនេះ សម្តេច ឧបនាយករដ្ឋមន្ត្រី បានលើកឡើងអំពីស្ថានភាពបច្ចុប្បន្នភាព នៃបទល្មើសគ្រឿងញៀននៅកម្ពុជា និងក៏បានជម្រាបជូន អំពីការដាក់ចេញនូវគំនិតផ្តួចផ្តើមមួយចំនួន ក្នុងការប្រយុទ្ធប្រឆាំង និងបង្ការបទល្មើសគ្រឿងញៀន ដើម្បីធានាដល់ការសម្រេចបាននូវលទ្ធផលក្នុងរយៈពេលមួយយូរអង្វែង នៅក្នុងបេសកកម្ម នៃការប្រយុទ្ធប្រឆាំងនឹងបង្ក្រាប ក៏ដូចជាបង្ការបទល្មើសគ្រឿងញៀន។

ជាការឆ្លើយតប លោក Joseph Scheuer ក៏បានដឹងអំពីកិច្ចខិតខំប្រឹងប្រែងក្នុងជាយុទ្ធនា ការរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំង ទៅនឹងអំពើជួញដូរមនុស្ស ខណៈនៅក្រោមឆត្ររបស់អង្គការប្រជាជាតិ ក៏មានអង្គការ IOM និងអង្គការ UNDP បានធ្វើការងារនេះជាមួយ នឹងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងមហាផ្ទៃ៕

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ៣ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិហ្វីលីពីន ១០នាក់

http://freshnewsasia.com/index.php/en/localnews/274683-2023-01-18-04-50-56.html 2023-01-18 11:50am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៦ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិហ្វីលីពីន ចំនួន ១០នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៧០៤ករណី មានមនុស្ស ១,៧២០នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៤២សំណើ និងបិទសំណុំរឿង ២៣២សំណើ (រកឃើញមនុស្ស ១,០៦៨នាក់, ឃាត់ខ្លួនជនសង្ស័យ ១២០នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣០ករណី៕

## សមាជិកព្រឹទ្ធសភាហ្វីលីពីនចោទប្រកាន់ក្រុមជួញដូរមនុស្សកំពុងជ្រើសរើសជនជាតិហ្វីលីពីនអោយធ្វើការងារខុសច្បាប់នៅកម្ពុជា

https://www.khmertimeskh.com/501222446// Khmer Times January 19, 2023

ស្រដៀងគ្នាទៅនឹងករណីជួញដូរមនុស្សនៅក្នុងប្រទេសមីយ៉ាន់ម៉ាដែរ សមាជិកព្រឹទ្ធសភា Risa Hontiveros នៅថ្ងៃពុធ ទី១៨ ខែមករា បាននិយាយថា ជនជាតិហ្វីលីពីនមួយចំនួនកំពុងត្រូវបានជ្រើសរើសដោយខុសច្បាប់ ដើម្បីធ្វើការជាអ្នកបោកប្រាស់ក្នុងប្រទេសកម្ពុជា។ Hontiveros បាននិយាយថា ប្រជាជនហ្វីលីពីនកំពុងត្រូវបានជ្រើសរើសដោយខុសច្បាប់ ដើម្បីធ្វើការនៅក្នុងប្រទេសកម្ពុជា ហើយត្រូវបានបង្ខំឱ្យបោកប្រាស់ ដោយទាក់ទាញពលរដ្ឋមកពីប្រទេសដូចជាសហរដ្ឋអាមេរិក និងកាណាដា ឱ្យវិនិយោគលើរូបិយប័ណ្ណគ្រីបតូ។ លោកស្រីបានបន្តថា ពលករហ្វីលីពីននៅក្រៅប្រទេសក៏ត្រូវបានក្រុមជនពាលចិននៅកម្ពុជាបង្ខំឲ្យធ្វើការងារខុសច្បាប់ផងដែរ។

“ប្រជាជនហ្វីលីពីនកំពុងក្លាយជាគោលដៅចម្បងនៃក្រុមជួញដូរមនុស្ស។ បន្ទាប់ពីយើងបានជួយប្រជាជនហ្វីលីពីនមួយចំនួនក្នុងប្រទេសមីយ៉ាន់ម៉ា ដែលត្រូវបានគេរំលោភបំពាន និងបង្ខំឱ្យធ្វើការជាអ្នកបោកប្រាស់រូបិយប័ណ្ណនោះ ឥឡូវនេះ រឿងរ៉ាវបែបនេះក៏មានកើតឡើងនៅកម្ពុជាផងដែរ»។ លោកស្រីបានបន្តថា “ទីតាំងខុសច្បាប់ទាំងនេះត្រូវតែលុបបំបាត់” ។ លោកស្រីបាននិយាយថា ជនរងគ្រោះម្នាក់ឈ្មោះ Miles បានទាក់ទងទៅលោកស្រីដើម្បីស្វែងរកជំនួយ ខណៈដែលមានជនជាតិហ្វីលីពីនផ្សេងទៀតត្រូវការសង្គ្រោះនៅក្នុងប្រទេសកម្ពុជា។

តាមការនិយាយរបស់ Miles ពួកគេត្រូវបានសន្យាថានឹងផ្តល់ការងារបម្រើសេវាកម្មអតិថិជន ឬការងារនៅមជ្ឈមណ្ឌលហៅទូរសព្ទ។ ប៉ុន្តែដូចដែលបានដឹងពីជនរងគ្រោះមកពីប្រទេសមីយ៉ាន់ម៉ា ជនជាតិហ្វីលីពីននៅកម្ពុជា

ក៏ត្រូវបានបង្ខំឱ្យបោកប្រាស់ពលរដ្ឋមកពីប្រទេសដូចជាសហរដ្ឋអាមេរិក និងកាណាដា។ Miles បានរៀបរាប់ជាភាសាហ្វីលីពីននៅក្នុងវីដេអូដែលចែករំលែកដោយការិយាល័យសមាជិកព្រឹទ្ធសភាថា "នៅពេលដែលយើងមិនអាចបំពេញតាមគោលដៅបាន (យើង) ត្រូវបានបង្ខំឱ្យធ្វើការលើសពី១៦ ម៉ោងក្នុងមួយសប្តាហ៍ដោយមិនបានដេក" ។

ស្រដៀងនឹងជនរងគ្រោះក្នុងប្រទេសមីយ៉ាន់ម៉ា Miles បាននិយាយថា នាងត្រូវបានគេជួញដូរចេញពី NAIA ចូលទៅក្នុងប្រទេសថៃ ហើយត្រូវជិះរថយន្តបន្តទៅប្រទេសកម្ពុជា។ ជនរងគ្រោះផ្សេងទៀត បានហោះចេញពីអាកាសយានដ្ឋាន Clark ក្នុងទីក្រុង Pampanga ហើយចូលប្រទេសកម្ពុជា ឬពី Zamboanga ចូលប្រទេសម៉ាឡេស៊ី ឬប្រទេសអាស៊ានផ្សេងទៀត មុនពេលធ្វើដំណើរមកកម្ពុជា។ Miles គឺជាជនរងគ្រោះក្នុងចំណោមជនជាតិហ្វីលីពីនដែលត្រូវបានជួយសង្គ្រោះកាលពីយប់ថ្ងៃច័ន្ទដោយអាជ្ញាធរកម្ពុជា តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់ស្ថានទូតហ្វីលីពីនក្នុងទីក្រុងភ្នំពេញ។

Hontiveros បានស្នើសុំឱ្យក្រសួងការបរទេសធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះអោយបានឆាប់ចាប់តាំងពីយប់ថ្ងៃអង្គារ ពួកគេត្រូវបានឃុំខ្លួននៅប៉ុស្តិ៍នគរបាលដោយគ្មានគ្រែដេក និងសម្ភារៈចាំបាច់នានា។ សមាជិកព្រឹទ្ធសភាបានបន្ថែមថា "ខ្ញុំជឿជាក់ថាក្រសួងការបរទេសរបស់យើងអាចនាំប្រជាពលរដ្ឋយើងមកផ្ទះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ខ្ញុំក៏រំពឹងដែរថា យើងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋសមាជិកអាស៊ាន ដើម្បីកម្ចាត់សកម្មភាពឧក្រិដ្ឋកម្មទាំងនេះ។ វាមិនអាចទទួលយកបានទេដែលបញ្ហានេះនៅតែបន្តកើតមានចំពោះជនរួមជាតិរបស់យើង" លោកស្រីបានលើកឡើងថា"ច្បាស់ណាស់ នេះជាឧស្សាហកម្មដែលមានការចូលរួមពីមនុស្សជាច្រើនមកពីជុំវិញអាស៊ីអាគ្នេយ៍ និងតំបន់ផ្សេងទៀត។ ប្រហែលជាឧក្រិដ្ឋជនដែលរំលោភបំពាន និងកេងចំណេញពីប្រជាជនហ្វីលីពីនដែលគ្រាន់តែចង់ស្វែងរកការងារសមរម្យគឺមានទំនាក់ទំនងជាមួយគ្នា»។ ខ្មែរថាមស៍បានដឹងថា អាជ្ញាធរហ្វីលីពីនប្រហែលមិនបានដឹងថា មានជនជាតិហ្វីលីពីនមួយចំនួនធំដែលកំពុងធ្វើការ និងស្នាក់នៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំមិនមានឯកសារធ្វើការងារត្រឹមត្រូវ៕ *Manila Bulletin/Khmer Times*

## ប៊ុលហ្គារីបើកការ
## បង្ក្រាបទូទាំងប្រទេសទៅលើការធ្វើចំណាកស្រុកខុសច្បាប់ និងអ្នកជួញដូរមនុស្ស

https://www.information.gov.kh/articles/95830 ចេញផ្សាយ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២៣

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃរបស់ប្រទេសប៊ុលហ្គារី លោក អ៊ីវ៉ាន់ ដេមើជហ្សេវ បាននិយាយប្រាប់ប្រព័ន្ធផ្សព្វផ្សាយថា ប្រទេសប៊ុលហ្គារីបានបើកការបង្ក្រាបទូទាំងប្រទេសទៅលើការធ្វើចំណាកស្រុកខុសច្បាប់ ហើយនេះជាយុទ្ធនាការដែលត្រូវបានគ្រោងទុកជាយូរមកហើយ។ លោក ដេមើជហ្សេវ បាននិយាយថា អគ្គនាយកដ្ឋានប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មរៀបចំទុកជាមុន និងមន្ត្រីប៉ូលីសនៅតាមព្រំដែន ធ្លាប់បានរាយការណ៍អំពីសកម្មភាពដ៏ជោគជ័យនៃយុទ្ធនាការនេះកន្លងមករួចហើយ។ លោកបានកត់សម្គាល់ថា «ក្រុមជួញដូរជនចំណាកស្រុកសំខាន់ៗត្រូវបានចាប់ខ្លួន។ ប្រតិបត្តិការនេះនឹងនៅតែបន្តនៅប៉ុន្មានថ្ងៃខាងមុខនេះនៅក្នុងប្រទេសតួកគី ក៏ដូចជាប្រទេសប៊ុលហ្គារី»។

បើយោងតាមលោករដ្ឋមន្ត្រីរូបនេះបានឱ្យដឹងថា សកម្មភាពស្រដៀងគ្នានេះត្រូវបានគ្រោងអនុវត្តផងដែរជាមួយប្រទេសក្រិក។ លោកបានបញ្ជាក់ថា «អន្តរកម្ម គឺជាមធ្យោបាយតែមួយគត់ក្នុងការឆ្លើយតបចំពោះឧក្រិដ្ឋកម្មឆ្លងដែន»។ ស្រដៀងគ្នានេះដែរ អគ្គរដ្ឋអាជ្ញា លោក អ៊ីវ៉ាន់ ហ្គេសហេវ បានសរសេរនៅលើបណ្តាញសង្គមធ្វីតធើរថា «ការធ្វើការងាររួមគ្នា និងភាពជាដៃគូ គឺជាមធ្យោបាយតែមួយគត់ដើម្បីការពារប្រជាជន និងផលប្រយោជន៍របស់ប៊ុលហ្គារី»។ លោក ហ្គេសហេវ បានថ្លែងអំណរគុណដល់រដ្ឋអាជ្ញា និងអ្នកស៊ើបអង្កេតនៅទូទាំងប្រទេសប៊ុលហ្គារី

ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ និងមន្ត្រីប៉ូលីសរាប់រយនាក់សម្រាប់ការងារដ៏ល្អដែលពួកគេបានអនុវត្តក្នុងការរៀបចំយុទ្ធនាការ និងសម្រាប់អន្តរកម្មប្រកបដោយវិជ្ជាជីវៈរបស់ពួកគេកន្លងមក។

តបតាមការបញ្ជារបស់អគ្គរដ្ឋអាជ្ញាក្នុងការឆែកឆេរលំនៅដ្ឋាន និងរឹបអូសយានយន្តរបស់ ជនសង្ស័យបានឱ្យដឹងថា មានការជួញដូរមនុស្សត្រូវបានធ្វើឡើងនៅទូទាំងប្រទេស។ អគ្គស្នងការរងប៉ូលិសជាតិ អគ្គនាយកដ្ឋាននគរបាលព្រំដែន អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានកងរាជអាវុធហត្ថ អគ្គនាយកដ្ឋានកងរាជអាវុធហត្ថ រួមទាំងមន្ត្រីនៃទីភ្នាក់ងាររដ្ឋសម្រាប់សន្តិសុខជាតិបានឱ្យដឹងថា ប្រតិបត្តិការនេះធ្វើឡើងដោយមន្ត្រីនៃអគ្គនាយកដ្ឋានប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មរៀបចំទុកជាមុន៕

## សម្តេច ស ខេង អញ្ជើញផ្សព្វផ្សាយការងារ គ្រប់គ្រងហត្ថពលកម្មបរទេស នៅកម្ពុជា

https://dap-news.com/national/2023/01/20/307041/ ByDR103Posted on January 20, 2023

**ភ្នំពេញ ៖ នាព្រឹកថ្ងៃសុក្រ ទី២០ ខែមករា ឆ្នាំ២០២៣នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីផ្សព្វផ្សាយការងារគ្រប់គ្រង ហត្ថពលកម្មបរទេស នៅព្រះរាជាណាចក្រកម្ពុជា ដែលពិធីនេះប្រារព្ធធ្វើឡើង នៅសណ្ឋាគារសុខាភ្នំពេញ។**

សូមបញ្ជាក់ថា ផែនការអនុវត្តរបស់គណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យការងារអធិការកិច្ច ហត្ថពលកម្មបរទេស បានកសាងឡើងក្នុងគោលបំណង ពង្រឹងការអនុវត្តច្បាប់ ស្តីពីការងារ និងច្បាប់ ស្តីពីអន្តោប្រវេសន៍ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដោយផ្តោតសំខាន់លើការងារ អធិការកិច្ចហត្ថពលកម្មបរទេស ព្រមទាំងលើកកម្ពស់ប្រសិទ្ធិភាព ការងារគ្រប់គ្រងជនបរទេស ដែលកំពុងស្នាក់នៅប្រកបមុខរបរ និងធ្វើការក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការផ្សព្វផ្សាយអំពីគោលការណ៍ វិធានការពាក់ព័ន្ធការងារអធិការកិច្ច ហត្ថពលកម្មបរទេស ដល់ម្ចាស់ ឬនិយោជកសហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់ហត្ថពលករបរទេស ឱ្យបានយល់ជ្រួតជ្រាប និងចូលរួមអនុវត្តឱ្យបានគ្រប់ៗគ្នា។

ជាងនេះទៅទៀត ក្នុងន័យនេះ គឺសំដៅកាត់បន្ថយជាអតិបរិមា និងឈានទៅរកការលុបបំបាត់ នូវរាល់ការប្រើប្រាស់ហត្ថពលករបរទេសមិនស្របច្បាប់ តាមគោលដៅ ឬទីតាំងអាជីវកម្មនានា តែមិនបានធ្វើឱ្យមានការប៉ះពាល់ ឬរំខានដល់មជ្ឈដ្ឋាន ជនបរទេស ដែលកំពុងស្នាក់នៅ ប្រកបមុខរបរ និងធ្វើការស្របច្បាប់ ក្នុងព្រះរាជាណាចក្រកម្ពុជានោះទេ។ លើសពីនេះ ផែនការសកម្មភាពនេះ ក៏មានគោលបំណងចូលរួមចំណែក ក្នុងការគាំទ្រ ដល់ផែនការប្រតិបត្តិការបង្កើន ការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរ មនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ បទល្មើសពាក់ព័ន្ធល្បែងស៊ីសង ខុសច្បាប់ ការឆបោកតាមប្រព័ន្ធអនឡាញ បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ឬបទល្មើសផ្សេងៗទៀត សំដៅចូលរួមថែរក្សាសន្តិសុខ សណ្តាប់ ធ្នាប់សង្គម៕

# ថ្ងៃទី២៣ ខែ មករា ឆ្នាំ២០២៣

## គិតត្រឹមពាក់កណ្តាលខែមករា អាជ្ញាធរទទួលពាក្យបណ្តឹង អំពើជួញដូរមនុស្សគ្រប់ទម្រង់ ៧០៧ករណី ឃាត់ខ្លួនជនសង្ស័យ ១២០នាក់ និងបិទក្រុមហ៊ុនចំនួន៥

https://dap-news.com/national/2023/01/20/307087/ ByKD102Posted on January 20, 2023

**ភ្នំពេញ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានឱ្យដឹងថា គិតមកដល់ពាក់កណ្តាលខែមករា ឆ្នាំ២០២៣ អាជ្ញាធរ ទទួលពាក្យបណ្តឹងអំពើជួញដូរមនុស្ស, ជួញដូរពលកម្ម និងពលកម្មផ្លូវភេទចំនួន ៧០៧ករណី ព្រមទាំងឃាត់ខ្លួនជនសង្ស័យចំនួន ១២០នាក់ និងបិទក្រុមហ៊ុនដែលប្រព្រឹត្តល្មើសចំនួន៥ផងដែរ។**

នាឱកាសអញ្ជើញផ្សព្វផ្សាយការងារ គ្រប់គ្រងហត្ថពលកម្មបរទេស នៅកម្ពុជា នាថ្ងៃទី២០ ខែមករា ឆ្នាំ ២០២៣ សម្តេច ស ខេង បានថ្លែងថា នៅក្នុងឆ្នាំ២០២២ អាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ច កំពុងជាប់ដៃប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងដោះស្រាយវិបត្តិ ដែលបណ្តាលមកពីជំនន់ ទឹកភ្លៀង ប៉ុន្តែពួកឧក្រិដ្ឋជន បានឆ្លៀតឱកាសប្រព្រឹត្តបទល្មើសបោក តាមប្រពន្ធ័អនឡាញ ដើម្បីទាក់ទាញជនបរទេសឱ្យ ប្រព្រឹត្តបទល្មើសខុសច្បាប់ និងទាក់ទាញពលករបរទេស ឱ្យចូលមកធ្វើការនៅកម្ពុជា ក្រោមរូបភាពផ្តល់កម្លាំងពលកម្ម ក្នុងតម្លៃខ្ពស់ជាដើម។

សម្តេច បញ្ជាក់ថា «ប្រឈមមុខនិងហេតុការណ៍នេះ កងកម្លាំងកម្ពុជា បានបើកយុទ្ធនាការប្រយុទ្ធប្រឆាំងនឹង ការជួញដូរមនុស្ស ជួញដូរពលរកម្មមនុស្ស និងពលកម្មផ្លូវភេទ ប្រកបដោយគណនីយភាព និងបើកចំហរដោយអនុញ្ញាតឱ្យប្រជាពលរដ្ឋ ក្រុមគ្រួសារ ក្នុងការផ្តល់ព័ត៌មានមកតាមហ្វេសបុក របស់សម្តេចផ្ទាល់ ឬតាមប្រព័ន្ធទូរសព្ទទាន់ហេតុការណ៍ អគ្គស្នងការនគរបាលជាតិ ឬអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដែលមកដល់ទល់នឹងខែមករា ឆ្នាំ២០២៣នេះ អាជ្ញាធរ បានទទួលបានព័ត៌មាន និងពាក្យបណ្តឹងចំនួន ៧០៧ករណី បានធែកឆេរកឃើញ ៤៤៥ករណី មានជនបរទេសចំនួន ១០៣៥នាក់ បានឃាត់ខ្លួនជនសង្ស័យចំនួន ១២០នាក់ ព្រមទាំងមាន ៤សញ្ជាតិ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់ និងបានបិទក្រុមហ៊ុនដែលប្រព្រឹត្តល្មើស ចំនួន ៥ ព្រមទាំងផ្អាកអាជីវកម្មចំនួន ៤ក្រុមហ៊ុន ក្នុងនោះ អាជ្ញាធរកម្ពុជា ក៏បានបិទសំណុំរឿងចំនួន ២២៩ករណី ផងដែរ»។

សូមរំលឹកថា រាជរដ្ឋាភិបាលកម្ពុជា បានឆ្លើយតបជាបន្ទាន់ តាមវិធានការបោសសម្អាតបទល្មើស យ៉ាងមានប្រសិទ្ធភាពនោះគឺ «ផែនការប្រតិបត្តិ ការបង្កើនការបង្ក្រាបអំពើ ជួញដូរមនុស្សគ្រប់ទម្រង់ និងបទល្មើសពាក់ព័ន្ធ» តាមសេចក្តីសម្រេចរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងបង្កើតក្រុមការងារប្រតិបត្តិការដឹកនាំដោយ អគ្គស្នងការនគរបាលជាតិ និងបើកយុទ្ធនាការនៅទូទាំងប្រទេស រុករកបទល្មើស បណ្តាញជនល្មើស និងសង្គ្រោះជនរងគ្រោះ នៅតាមទីតាំងដែលមាន ការសង្ស័យយ៉ាងសកម្ម ៕

## កម្ពុជា ស្នើបណ្តាប្រទេសនានា រួមគ្នាបង្ក្រាបមេខ្យល់ សំដៅកាត់ផ្តាច់អំពើជួញដូរមនុស្ស

https://dap-news.com/national/2023/01/20/307092/ ByKD102Posted on January 20, 2023

**ភ្នំពេញ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃកម្ពុជា បានស្នើបណ្តាប្រទេសនានា រួមគ្នាស្រាវជ្រាវ និងបង្ក្រាបមេខ្យល់ ដែលប្រព្រឹត្តបទល្មើស អំពើជួញដូរមនុស្សគ្រប់ទម្រង់ សំដៅកាត់ផ្តាច់បទល្មើសនេះ ឱ្យមានប្រសិទ្ធភាព។**

ក្នុងពិធីផ្សព្វផ្សាយការងារគ្រប់គ្រង ហត្ថពលកម្មបរទេសនៅកម្ពុជា នាថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ សម្តេចក្រឡាហោម ស ខេង បានណែនាំដល់អាជ្ញាធររាជធានី-ខេត្ត ត្រូវពង្រឹងការគ្រប់គ្រង និងការធ្វើអធិការកិច្ចហត្ថពលកម្មបរទេស។ អាជ្ញាធរ ហើយកងកម្លាំងមានសមត្ថកិច្ចគ្រប់ប្រភេទ ត្រូវគ្រប់គ្រងជនបរទេសស្របតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្ការទប់ស្កាត់បទល្មើស គ្រប់ប្រភេទសំដៅពង្រឹងសន្តិសុខជាតិ និងសុវត្ថិភាពសង្គម។

សម្តេចក្រឡាហោម បញ្ជាក់ថា «ក្នុងកិច្ចប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹង អំពើរជួញដូរមនុស្សគ្រប់ទម្រង់ ជួញដូរពលកម្ម និងអាជីវកម្ម ផ្លូវភេទ និងការចុះធ្វើហត្ថពលកម្មគ្រប់ប្រភេទ អាជ្ញាធរ និងកងកម្លាំងគ្រប់ប្រភេទ អាជ្ញាធរ នៃព្រះរាជាណាចក្រកម្ពុជា បានរកឃើញ ជនរងគ្រោះ ដែលជនបរទេសត្រូវបានមេខ្យល់នាំមកឱ្យចូលមកធ្វើការ ខុសច្បាប់នៅព្រះរាជាណាចក្រកម្ពុជា អាស្រ័យហេតុនេះ ខ្ញុំ ស្នើជាមួយបណ្តាប្រទេសនានា ដើម្បីរួមគ្នា

ស្រាវជ្រាវបង្ក្រាបបណ្តាញមេខ្យល់ ដែលប្រព្រឹត្តបទល្មើសនេះ សំដៅកាត់ផ្តាច់ បណ្តាញប្រព្រឹត្តបទល្មើស ឱ្យមានប្រសិទ្ធភាព»។

សម្តេចក្រឡាហោម ស ខេង បានបន្ថែមទៀតថា គណៈបញ្ជាការរាជធានី-ខេត្ត ត្រូវណែនាំសហការសម្របសម្រួល ផ្សព្វផ្សាយច្បាប់ និងលិខិតនានា ព្រមទាំងការគ្រប់គ្រង និងការចុះធ្វើអធិការកិច្ចហត្ថពលកម្មបរទេស ដល់កម្មករ និយោគជិត របស់បរទេស និងវិនិយោគជក នៃរោងចក្រ សហគ្រាស និងមូលដ្ឋានអាជីវកម្មនានា ក្នុងរាជធានី-ខេត្ត របស់ខ្លួន ស្របតាមការណែនាំរបស់ គណៈកម្មការអន្តរក្រសួង ៕

## រដ្ឋមន្ត្រីមហាផ្ទៃ អញ្ជើញផ្សព្វផ្សាយ គោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព

https://dap-news.com/national/2023/01/20/307123/ ByKD102Posted on January 20, 2023

**ភ្នំពេញ៖ នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញផ្សព្វផ្សាយអំពីការរៀបចំ និងការប្រព្រឹត្តទៅ នៃលេខាធិការដ្ឋានសម្រាប់គាំទ្រ ការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ដែលពិធីនេះប្រារព្ធធ្វើឡើង នៅសណ្ឋាគារសុខាភ្នំពេញ។**

គួរបញ្ជាក់ថា លេខាធិការដ្ឋានសម្រាប់គាំទ្រ ការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព មានភារកិច្ចដូចជា ៖ សហការរៀបចំផែនការយុទ្ធសាស្ត្រ ស្តីពីការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព, រៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់លេខាធិការដ្ឋាន ស្តីពីការសហការ ការសម្របសម្រួល ការតាមដាន ការត្រួតពិនិត្យ និងការដាស់តឿន ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព។ សហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន រដ្ឋបាលថ្នាក់ក្រោមជាតិ និងគណៈបញ្ជាការឯកភាពគ្រប់ថ្នាក់ ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំ- សង្កាត់មានសុវត្ថិភាព។ សហការ និងផ្តល់អនុសាសន៍ ក្នុងការអនុវត្តលក្ខណសម្បត្តិ នៃគោលនយោបាយភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ព្រមទាំងសហការរៀបចំគោលនយោបាយ សេចក្តីណែនាំនានា និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព។ សហការ ដឹកនាំ និងផ្តល់អនុសាសន៍ក្នុងការ អនុវត្តចលនាប្រលងប្រណាំង អំពីការអនុវត្តគោល នយោបាយភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ព្រមទាំងកៀរគរការចូលរួម និងការគាំទ្រពីដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជននានា ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព៕

## អាជ្ញាធរបើកយុទ្ធនាការ ៦ ខែ លុបបំបាត់ការប្រើប្រាស់ពលករបរទេសខុសច្បាប់នៅកម្ពុជា

https://www.kampucheathmey.com/local-news/450610 ថ្ងៃសុក្រ ២០ មករា ២០២៣ Dy Bunnara

កម្ពុជាបើកយុទ្ធនាការរយៈពេល ៦ ខែ ដើម្បីលុបបំបាត់ការប្រើប្រាស់ហត្ថពលករបរទេសខុសច្បាប់ នៅកម្ពុជាសំដៅចូលរួមថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គមឱ្យកាន់តែប្រសើរឡើង។

ថ្លែងក្នុងពិធីផ្សព្វផ្សាយការងារគ្រប់គ្រងហត្ថពលកម្មបរទេសនៅកម្ពុជា ក្រោមអធិបតីភាពរបស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅព្រឹកថ្ងៃទី២០ មករានេះ លោក បណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស បានមានប្រសាសន៍ថា យុទ្ធនាការប្រតិបត្តិការរយៈពេល ៦ខែនេះបែងចែកជាពីរដំណាក់កាលដោយចាប់ផ្តើមអនុវត្តពីខែមករា ដល់ខែមិថុនា ដោយដំណាក់កាលទី១ចាប់ពីខែមករាដល់ខែមីនាឆ្នាំ២០២៣ជាដំណាក់កាលធ្វើការផ្សព្វផ្សាយដល់សហគ្រាសគ្រឹះស្ថាន ដែលមានប្រើប្រាស់ហត្ថពលកម្ម

បរទេស និងគ្រប់ភាគីពាក់ព័ន្ធ ដើម្បីយល់ជ្រួតជ្រាប និងចូលរួមអនុវត្ត ព្រមទាំងផ្សព្វផ្សាយបន្តនូវគោលការណ៍វិធានការដែលច្បាប់បានកំណត់អំពីការងារអធិការកិច្ចហត្ថពលកម្មបរទេស។

លោក រដ្ឋមន្ត្រីបានបន្តថា ក្នុងដំណាក់កាលផ្សព្វផ្សាយនេះ តម្រូវឱ្យសហគ្រាស គ្រឹះស្ថាន ដែលប្រើប្រាស់ហត្ថពលកម្មបរទេសត្រូវបំពេញរបាយការណ៍ស្វ័យប្រកាស អំពីការប្រើប្រាស់ហត្ថពលកម្មបរទេស ដូចដែលមានគំរូផ្តល់ជូន និងត្រូវបញ្ជូនមកវិញ តាមរយៈការងារអធិការកិច្ចហត្ថពលកម្មបរទេស នៅរាជធានី-ខេត្ត ឱ្យបានមុនថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣។ លោក រដ្ឋមន្ត្រីបានបន្តទៀតថា ចំណែកដំណាក់កាលទី២ អនុវត្តចាប់ពីខែមេសា ដល់បំណាច់ខែមិថុនា ជាដំណាក់កាលចុះអធិការកិច្ចជាក់ស្តែង នៅតាមគ្រប់សហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់ហត្ថពលកម្មបរទេស ដោយផ្អែកតាមស្វ័យរបាយការណ៍ និងប្រតិទិនរបស់ក្រុមការងារ។

លោក រដ្ឋមន្ត្រី បានបន្ថែមទៀតថា រាល់ពេលចុះប្រតិបត្តិការត្រូវមានការសម្របសម្រួលពីស្ថាប័នអយ្យការអមសាលាដំបូង រាជធានី-ភ្នំពេញហើយក្នុងអំឡុងពេលប្រតិបត្តិការ ម្ចាស់ ឬនិយោជក ត្រូវបង្ហាញវត្តមានពលករបរទេសគ្រប់រូប និងឯកសារពាក់ព័ន្ធរបស់ពួកគេម្នាក់ៗ ដល់ក្រុមអធិការកិច្ចហត្ថពលកម្មបរទេស ស្របតាមខ្លឹមសារដែលបានកំណត់ក្នុងប្រកាសអន្តរ រវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការពង្រឹងការងារអធិការកិច្ចហត្ថពលកម្មបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា។ លោករដ្ឋមន្ត្រីបានបញ្ជាក់ថា រាល់ពេលចុះប្រតិបត្តិការត្រួតពិនិត្យ ក្នុងករណីរកឃើញបទល្មើសដទៃទៀត ក្រុមការងារអធិការកិច្ចហត្ថពលកម្មបរទេស ត្រូវរាយការណ៍ជូនអភិបាលរាជធានី-ខេត្ត ដើម្បីសុំគោលការណ៍ចាត់វិធានការស្របតាមនីតិវិធីច្បាប់។

លោករដ្ឋមន្ត្រីបានបន្ថែមថា ចំពោះផែនការសកម្មភាពនេះមានគោលបំណងក្នុងការចូលរួមចំណែកក្នុងការគាំទ្រដល់ផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ បទល្មើសពាក់ព័ន្ធល្បែងស៊ីសងខុសច្បាប់ ការឆបោកតាមប្រព័ន្ធអនឡាញ បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ឬបទល្មើសផ្សេងៗទៀត។ ជាងនេះទៀតដើម្បីសំដៅកាត់បន្ថយជាអតិបរិមា និងឈានទៅរកការលុបបំបាត់នូវការប្រើប្រាស់ហត្ថពលករបរទេសមិនស្របច្បាប់ តាមគោលដៅ ឬទីតាំងអាជីវកម្មនានា តែមិនធ្វើឱ្យមានការប៉ះពាល់ ឬរំខានដល់មជ្ឈដ្ឋានជនបរទេស ដែលកំពុងស្នាក់នៅ ប្រកបមុខរបរ និងធ្វើការស្របច្បាប់ទូទាំងប្រទេសកម្ពុជា៕ អត្ថបទ៖ សំអឿន

## កម្ពុជា គ្រោងបញ្ជូនពលករ ១០ម៉ឺននាក់ ទៅធ្វើការនៅថៃ និង៣ម៉ឺននាក់ទៅកម្មសិក្សានៅជប៉ុន

https://www.kampucheathmey.com/local-news/450637 ថ្ងៃសុក្រ ២០ មករា ២០២៣ Sophal Tuon

នៅក្នុងឆ្នាំ២០២៣នេះ កម្ពុជា បានបញ្ជូនពលករ និងកម្មសិក្សាការីទៅធ្វើការនៅប្រទេសថៃនិងជប៉ុនប្រមាណ១៣ម៉ឺននាក់ កើនឡើងជាងឆ្នាំមុន ប្រមាណជាង២ម៉ឺននាក់។

លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា បានលើកឡើងថា ក្នុងចំណោមពលករ និងកម្មសិក្សាការី១៣ម៉ឺននាក់ ក្នុងនោះបញ្ជូនទៅប្រទេសថៃប្រមាណ១០ម៉ឺននាក់ ដោយទៅធ្វើការនៅតាមបណ្តារោងចក្រចំណីអាហារ និងក្រុមហ៊ុន សំណង់ សេវាកម្ម និងកសិកម្ម។ ចំណែកទៅប្រទេសជប៉ុនប្រមាណ៣ម៉ឺននាក់ ដែលភាគច្រើនជាកម្មសិក្សាការី។ រីឯពលករជំនាញមានប្រមាណ ១០០ទៅ២០០នាក់ ដោយពួកគេទៅធ្វើការលើផ្នែកការវេខ្ចប់សំណង់ ចំណីអាហារ សេវាកម្ម សណ្ឋាគារភោជនីដ្ឋាន កសិកម្មដាំដុះ និងចិញ្ចឹមសត្វ។ លោក បានបញ្ជាក់ថា ការបញ្ជូនពលករ និងកម្មសិក្សាការី ទៅធ្វើការនៅថៃ និងជប៉ុនឆ្នាំ២០២៣នេះ មានការកើនឡើង បើ

ធៀបទៅនឹងឆ្នាំ២០២២កន្លងទៅ ដែលមានប្រមាណជាង១១ម៉ឺននាក់ប៉ុណ្ណោះ ក្នុងនោះ នៅប្រទេសថៃមានប្រមាណ៩ម៉ឺននាក់ និងនៅជប៉ុនមានពលករជំនាញនិងកម្មសិក្សាការីប្រមាណ២៥ ០០០នាក់។

ចំណែកប្រទេសសឹង្ហបុរីនិងហុងកុងដែលមានតម្រូវការក្នុង១ឆ្នាំ១០០ទៅ២០០នាក់ កម្ពុជា មិនបានបញ្ជូនទៅទេ ដោយសារមិនមានពលករចាប់អារម្មណ៍លើការងារថៃទាំផ្ទះ ដែលបណ្ដាលមកពីនៅកម្ពុជាមានការងារសម្បូរច្រើនទទួលបានប្រាក់ឈ្នួលសមរម្យ។ គួរបញ្ជាក់ថា បច្ចុប្បន្ននេះ មានពលករខ្មែរប្រមាណជាង១លាន៣សែននាក់ធ្វើការនៅក្រៅប្រទេស ក្នុងនោះនៅថៃមានច្រើនជាងគេរហូតដល់ទៅ១,២២លាននាក់ នៅកូរ៉េខាងត្បូងមានជាង៤៥០០០នាក់នៅម៉ាឡេស៊ីមាន២៣០២៧នាក់ នៅជប៉ុនមាន១១៤៥៣នាក់ នៅសិង្ហបុរីមាន៨២១នាក់ នៅចិនហុងកុង មាន២០២នាក់ និងអារ៉ាប៊ីសាអូឌីត ៤៣នាក់ ដោយក្នុង១ឆ្នាំៗបានផ្ញើថវិកាមកក្រុមគ្រួសារវិញប្រមាណជាង៣ពាន់លានដុល្លារ៕ សំអឿន

## សមត្ថកិច្ចរកឃើញជនបរទេសមួយចំនួន
## ត្រូវបានមេខ្យល់ នៅក្រៅប្រទេសបោកបញ្ឆោតតាមប្រព័ន្ធអនឡាញ
## ឱ្យចូលមកធ្វើការខុសច្បាប់ នៅតាមទីតាំងល្បែងភ្នាល់អនឡាញខុសច្បាប់នានា

https://cen.com.kh/archives/607620.html Posted ByPen Srey NeatJanuary 20, 2023

ភ្នំពេញៈ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងថា សមត្ថកិច្ចកម្ពុជាបានរកឃើញជនបរទេសមួយចំនួន ត្រូវបានមេខ្យល់ មេខ្លោងនៅក្រៅប្រទេសបោកបញ្ឆោតតាមប្រព័ន្ធអនឡាញ ឱ្យចូលមកធ្វើការខុសច្បាប់ នៅតាមទីតាំងល្បែងភ្នាល់អនឡាញខុសច្បាប់នានា ដែលភាគច្រើននៅខេត្តព្រះសីហនុ ។ សម្ដេចក្រឡាហោម ថ្លែងបែបនេះ ក្នុងឱកាសអញ្ជើញ ជាអធិបតីក្នុងពិធីផ្សព្វផ្សាយការងារ គ្រប់គ្រងហត្ថពលកម្មបរទេស នៅព្រះរាជាណាចក្រកម្ពុជា ប្រារព្ធនៅសណ្ឋាគារសុខាភ្នំពេញ កាលពីព្រឹកថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣នេះ។ សម្ដេចក្រឡាហោម ស ខេង ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាដែលមានសម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីជាប្រមុខ បានសម្ដែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងស្ថាប័ននានា ជាពិសេសអគ្គនាយកដ្ឋានការងារ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អាជ្ញាធរ កងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ដែលបានសហការល្អក្នុងការគ្រប់គ្រងហត្ថពលកម្មបរទេស ដោយមានការគាំទ្រការចូលរួមពីកម្មករនិយោជិតបរទេស និងម្ចាស់រោងចក្រ សហគ្រាស មូលដ្ឋានអាជីវកម្មនានា។

សម្ដេចក្រឡាហោមបន្តថា ក្នុងពេលដែលអាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចកម្ពុជា កំពុងជាប់ដៃក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងការដោះស្រាយវិបត្តិបណ្ដាលមកពីជំនន់ទឹកភ្លៀងនារដូវវស្សាកន្លងមក ពួកឧក្រិដ្ឋជននៅក្រៅប្រទេសមួយចំនួន បានឆ្លៀតឱកាសប្រព្រឹត្តបទល្មើសបោកបញ្ឆោតតាមប្រព័ន្ធអនឡាញ ដើម្បីទាក់ទាញជនបរទេសឱ្យប្រព្រឹត្តបទល្មើស ល្បែងភ្នាល់អនឡាញខុសច្បាប់ និងទាក់ទាញបោកបញ្ឆោត ពលករបរទេសឱ្យចូលមកធ្វើការខុសច្បាប់នៅកម្ពុជា ក្រោមរូបភាពផ្ដល់ប្រាក់ឈ្នួលពលកម្មក្នុងតម្លៃខ្ពស់ជាដើម។ សម្ដេចបានបន្ថែមថា ប្រឈមមុខចំពោះសភាពការណ៍នេះ អាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចកម្ពុជា បានបើកយុទ្ធនាការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ប្រកបដោយតម្លាភាព មានការចូលរួម និងគណនេយ្យភាព ដោយបើកចំហរឱ្យសាមីខ្លួន ក្រុមគ្រួសារ ឬអ្នកពាក់ព័ន្ធនានាដែលអះអាងថា បានរងគ្រោះដោយអំពើជួញដូរមនុស្ស ជួញដូរពលកម្ម ដើម្បីធ្វើការផ្ដល់ព័ត៌មាន ឬប្ដឹងតាមប្រព័ន្ធហ្វេសប៊ុកសម្ដេចផ្ទាល់ ឬតាមប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍របស់អគ្គស្នងការដ្ឋាននគរបាលជាតិ និងប្រព័ន្ធទំនាក់ទំនងនានា នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍។សម្ដេចបានឱ្យដឹងថា មកទល់ពាក់កណ្ដាលខែមករានេះ អាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចកម្ពុជាបានទទួលព័ត៌មាន និងពាក្យបណ្ដឹងនានាចំនួន ៧០៧ករណី បានស្រាវជ្រាវរកឃើញ ៤៤៥ករណី មានជន

បរទេសចំនួន ១.០៤៥នាក់ បានឃាត់ខ្លួនជនសង្ស័យប្រព្រឹត្តបទល្មើសនានាចំនួន ១២០នាក់ មាន ៤សញ្ជាតិ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់ និងបានបិទក្រុមហ៊ុនដែលពាក់ព័ន្ធបទល្មើសចំនួន ០៥ក្រុមហ៊ុន ព្រមទាំងផ្អាកអាជីវកម្ម និងបន្តស្រាវជ្រាវ ៤ក្រុមហ៊ុន ហើយក្នុងចំណោមពាក្យបណ្ដឹងដែលទទួលបាន អាជ្ញាធរកម្ពុជាបានបិទសំណុំរឿង ២២៩ករណី ដោយមូលហេតុរកមិនឃើញទីតាំង និងផ្តល់ព័ត៌មានមិនច្បាស់លាស់។

សម្តេចមានប្រសាសន៍ថា រាជរដ្ឋាភិបាលបានសម្រេចរៀបចំនូវយន្តការ ២ទៀត ដើម្បីជួយគាំទ្រដល់ប្រតិបត្តិការស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ដោយបានបង្កើតនូវក្រុមការងារបង្ក្រាបល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទទូទាំងប្រទេស ដែលដឹកនាំដោយ ឯកឧត្តមសន្តិបណ្ឌិត សុខផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងគណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស ដែលដឹកនាំដោយឯកឧត្តម នៅ លក្ខណា អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ។ ការបង្កើតយន្តការទាំងពីរនេះ ត្រូវបានសម្តេចអះអាងថា ដោយសារឆ្លងតាមប្រតិបត្តិការ ស្រាវជ្រាវបង្ក្រាបបទល្មើសជួញដូរមនុស្ស កងកម្លាំងមានសមត្ថកិច្ចកម្ពុជាបានរកឃើញជនបរទេសមួយចំនួន ត្រូវបានមេខ្យល់ មេខ្លោងនៅក្រៅប្រទេសបោកបញ្ឆោតតាមប្រព័ន្ធអនឡាញឱ្យចូលមកធ្វើការខុសច្បាប់នៅតាមទីតាំងល្បែងភ្នាល់អនឡាញខុសច្បាប់នានា ដែលភាគច្រើននៅខេត្តព្រះសីហនុ និងដោយពិនិត្យឃើញភាពស្មុគស្មាញ នៃល្បែងភ្នាល់អនឡាញខុសច្បាប់ និងការប្រើប្រាស់ពលកម្មបរទេសមិនស្របច្បាប់នៅតាមទីតាំងនានា។

ព្រមជាមួយនេះ សម្តេចបានបន្ថែមថា ក្រសួងមហាផ្ទៃបានសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះធ្វើអធិការកិច្ចហត្ថពលកម្មបរទេសក្នុងកាស៊ីណូ ដែលទទួលបានអាជ្ញាប័ណ្ណប្រកបអាជីវកម្មស្របច្បាប់មួយនៅក្រុងបាវិត ខេត្តស្វាយរៀង ហើយបានរកឃើញជនបរទេសដែលធ្វើការ នៅកាស៊ីណូនេះជាង ៣,៨០០នាក់ ក្នុងនោះមានតែ៤៧០នាក់ប៉ុណ្ណោះ ដែលមានប័ណ្ណការងារ និងសៀវភៅការងារត្រឹមត្រូវស្របច្បាប់។ សម្តេចក្រឡាហោម ស ខេង បានបន្ថែមថា ផ្អែកលើសភាពការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចកែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស ដោយប្រគល់ភារកិច្ចជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើជាប្រធានគណៈកម្មការ សំដៅពង្រីកវិសាលភាពការងារនេះនៅទូទាំងប្រទេស ដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពង្រឹង និងលើកកម្ពស់ការទទួលខុសត្រូវក្នុងការបំពេញការងាររួមគ្នារបស់ក្រសួងស្ថាប័ន អាជ្ញាធរពាក់ព័ន្ធក្នុងការគ្រប់គ្រងហត្ថពលកម្មបរទេសឱ្យត្រឹមត្រូវតាមច្បាប់។

សម្តេចក្រឡាហោម បានសង្កត់ធ្ងន់ថា ផ្អែកលើសភាពការណ៍វិវត្តប្រែប្រួលទាំងនេះ ទាមទារឱ្យមានការពង្រឹងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ទាំងស្ថាប័នរដ្ឋ វិស័យឯកជន សង្គមស៊ីវិល អង្គការអន្តរជាតិ និងប្រទេសនានាដើម្បីសហការគ្នាឱ្យបានជិតស្និទ្ធក្នុងការបង្ការទប់ស្កាត់សកម្មភាពល្មើសច្បាប់ទាំងនេះ និងសហការជួយគាំទ្រគ្នាទៅវិញទៅមក ដើម្បីជំរុញកំណើនសេដ្ឋកិច្ច សំដៅរក្សា និងបង្កើតឱកាសការងារ និងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋនៅតាមប្រទេសនីមួយៗ ដើម្បីរួមគ្នាជំរុញកំណើនសេដ្ឋកិច្ចក្នុងតំបន់ និងសកលលោក។

នាឱកាសនោះដែរ ឯកឧត្តម នៅ លក្ខិណា អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធាលេខាធិការដ្ឋាននៃគណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស, ឯកឧត្តម នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងឯកឧត្តម សេង សក្កដា ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអគ្គនាយកនៃអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអនុប្រធានគណៈកម្មការអន្តរក្រសួង បានអញ្ជើញធ្វើបទបង្ហាញគោរពជូនសម្តេចក្រឡាហោម និងអង្គពិធីផងដែរ។

បន្ទាប់ពីបានស្តាប់របាយការណ៍ និងការធ្វើបទបង្ហាញ សម្តេចក្រឡាហោម ស ខេង បានអញ្ជើញផ្តល់គោលការណ៍ណែនាំ និងជំរុញលើកទឹកចិត្តឱ្យក្រសួងស្ថាប័ន គណៈបញ្ជាការឯកភាពរាជធានី-ខេត្ត និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ សហការរួមគ្នាអនុវត្តផែនការសកម្មភាពនេះប្រកបដោយការទទួលខុសត្រូវខ្ពស់ និងអំពាវនាវដល់កម្មករនយោជិកបរទេស និយោជកនៃរោងចក្រ សហគ្រាស មូលដ្ឋានអាជីវកម្ម និងអ្នកពាក់ព័ន្ធទាំងអស់ផ្តល់ការគាំទ្រ និងចូលរួមអនុវត្តឱ្យបានត្រឹមត្រូវ។ សម្តេចក៏បានណែនាំគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត ត្រូវដឹកនាំ ណែនាំ សហការ សម្របសម្រួល ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធការគ្រប់គ្រង និងចុះធ្វើអធិការកិច្ចហត្ថពលកម្មបរទេសដល់កម្មករនិយោជិកបរទេស និងនិយោជកនៃរោងចក្រសហគ្រាស និងមូលដ្ឋានអាជីវកម្មនានាក្នុងមូលដ្ឋានរាជធានី-ខេត្តរបស់ខ្លួន ហើយតាមដាន ត្រួតពិនិត្យ ដំណើរការអធិការកិច្ចហត្ថពលកម្មបរទេសឱ្យបានម៉ត់ចត់តាមប្រព័ន្ធគោលការណ៍ និងនីតិវិធីកំណត់ដោយតម្លាភាព គណនេយ្យភាព និងត្រូវធានារក្សាឱ្យបានសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងមិនត្រូវធ្វើឱ្យប៉ះពាល់ ឬរំខានដល់ដំណើរការផលិតកម្ម អាជីវកម្មស្របច្បាប់របស់រោងចក្រសហគ្រាស និងមូលដ្ឋានអាជីវកម្មនានានោះឡើយ។

សម្តេចបន្ថែមថា ក្នុងពេលចុះធ្វើអធិការកិច្ច ករណីរកឃើញតម្រុយសង្ស័យបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម អាជីវកម្មផ្លូវភេទ ឬបទល្មើសផ្សេងៗទៀត ក្រុមចម្រុះអធិការកិច្ច ត្រូវរាយការណ៍ជាបន្ទាន់មកគណៈបញ្ជាការឯកភាព រាជធានី-ខេត្ត និងគណៈកម្មការអន្តរក្រសួងដើម្បីចាត់វិធានការស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។ ជាមួយគ្នានេះសម្តេចណែនាំឱ្យគណៈកម្មការអន្តរក្រសួងរៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដំណើរការធ្វើរបាយការណ៍ស្វ័យប្រកាសក្នុងដំណាក់កាលទី១ និងការចុះធ្វើអធិការកិច្ចក្នុងដំណាក់កាលទី២ សំដៅដោះស្រាយបញ្ហាប្រឈម ដោយប្រជុំដកពិសោធន៍ សំដៅជំរុញការអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាពខ្ពស់។ សម្តេចក៏បានណែនាំអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អាជ្ញាធរ កងកម្លាំងមានសមត្ថកិច្ចគ្រប់ថ្នាក់ ត្រូវពង្រឹងការគ្រប់គ្រងជនបរទេសស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្ការ ទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ សំដៅពង្រឹងសន្តិសុខជាតិ និងសុវត្ថិភាពសង្គម។ សម្តេចក៏បានណែនាំឱ្យពង្រឹងកិច្ចហការសម្របសម្រួល ធ្វើសកម្មភាពឱ្យបានព្រមៗគ្នា រវាងយន្តការប្រតិបត្តិការទាំង៣ គឺគណៈបញ្ជាការដឹកនាំការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រុមការងារបង្ក្រាបល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ និងគណៈកម្មការអន្តរក្រសួងដែលបានប្រកាសផ្សព្វផ្សាយនៅថ្ងៃនេះ។

ជាមួយគ្នានោះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា សម្តេចបានស្នើស្ថានទូត ស្ថានតំណាងប្រទេសនានានៅកម្ពុជា ដែលមានពលរដ្ឋកំពុងស្នាក់នៅ និងធ្វើការនៅកម្ពុជា សូមជួយអប់រំអំពីច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធការគ្រប់គ្រងហត្ថពលកម្មបរទេស សំដៅបង្ការទប់ស្កាត់ការមកធ្វើការខុសច្បាប់ និងស្នើសុំកិច្ចសហប្រតិបត្តិការរួមគ្នាស្រាវជ្រាវ បង្ក្រាបបណ្តាញមេខ្យល់ មេក្លោង សំដៅកាត់ផ្តាច់បណ្តាញប្រព្រឹត្តបទល្មើសឱ្យមានប្រសិទ្ធភាព។ សម្តេចបានបង្ហាញក្តីសង្ឃឹមគ្រប់ភាគីពាក់ព័ន្ធនឹងអនុវត្តការងារនេះឱ្យបានល្អប្រសើរ៕ រក្សាសិទ្ធិដោយៈចេស្តារ

# ថ្ងៃទី២៥ ខែ មករា ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ៦ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនបរទេស ១៩នាក់

https://freshnewsasia.com/index.php/en/localnews/275085-2023-01-21-08-14-06.html 2023-01-21 03:14pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៩ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៦ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនបរទេស ចំនួន ១៩នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៧១៥ករណី មានមនុស្ស ១,៧៥០នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៤៦សំណើ និងបិទសំណុំរឿង ២២៩សំណើ (រកឃើញមនុស្ស ១,០៤៨នាក់, ឃាត់ខ្លួនជនសង្ស័យ ១២២នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៤០ករណី៕

## ស្ថានទូតហ្វីលីពីនប្រចាំនៅកម្ពុជា ស្វែងរកជំនួយផ្នែកហិរញ្ញវត្ថុ ដើម្បីធ្វើមាតុភូមិនិវត្តន៍ជនហ្វីលីពីនដែលត្រូវបានជួញដូរ

https://www.khmertimeskh.com/501223433// January 21, 2023

ឥឡូវនេះ ក្រសួងការបរទេសកំពុងធ្វើការលើការធ្វើមាតុភូមិនិវត្តន៍ របស់ជនជាតិហ្វីលីពីនចំនួនប្រាំបីនាក់ដែលត្រូវបានជួញដូរនៅក្នុងប្រទេសកម្ពុជា ជុំវិញគម្រោងរូបិយប័ណ្ណគ្រីបតូ ដែលបានដាក់ក្នុងសវនាការព្រឹទ្ធសភាកាលពីខែវិច្ឆិកា។ ក្រសួងបាននិយាយថា គម្រោងជួញដូរមនុស្សបានដំណើរការជាច្រើនខែមកហើយ។ ជនល្មើសម៉ាហ្វីយ៉ាជនជាតិចិនជ្រើសរើសជនជាតិហ្វីលីពីនសម្រាប់ការដាក់កូដទិន្នន័យ ឬការងារមជ្ឈមណ្ឌលហៅទូរសព្ទ ប៉ុន្តែពួកគេត្រូវបង្ខំចិត្តបោកប្រាស់បុគ្គលផ្សេងទៀត ខណៈដែលមានមូលដ្ឋាននៅទូទាំងប្រទេសកម្ពុជា ឡាវ ថៃ និងមីយ៉ាន់ម៉ា។

លោក Eduardo de Vega អនុរដ្ឋលេខាធិការក្រសួងការបរទេសទទួលបន្ទុកកិច្ចការពលករទេសន្តរប្រវេសន៍បានមានប្រសាសន៍នៅក្នុងបទសម្ភាសន៍តាមទូរទស្សន៍ជាមួយ CNN ហ្វីលីពីន កាលពីថ្ងៃព្រហស្បតិ៍ថា "ស្ថានទូតរបស់យើងនៅភ្នំពេញបានស្នើសុំជាផ្លូវការពីក្រសួងការបរទេសសម្រាប់ការផ្តល់មូលនិធិសម្រាប់ជំនួយហិរញ្ញវត្ថុដល់ប្រជាជនហ្វីលីពីន និងសម្រាប់សំបុត្រយន្តហោះផងដែរ ដើម្បីយើងនឹងផ្តល់មូលនិធិ" ។

ខ្មែរថាមស៍បានដឹងថា អ្នកទាំងប្រាំបីនាក់ដែលកំពុងរង់ចាំការធ្វើមាតុភូមិនិវត្តន៍ និងអ្នកដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍នៅឆ្នាំ២០២១ និង២០២២ នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ ខណៈដែលជនជាតិហ្វីលីពីន និងជនជាតិផ្សេងទៀតត្រូវបានជាប់អន្ទាក់ដោយក្រុមជួញដូរមនុស្សដើម្បីធ្វើការនៅក្នុងកន្លែងcrypto boiler ក្នុងប្រទេសកម្ពុជា និងមជ្ឈមណ្ឌលខុសច្បាប់ផ្សេងទៀតដូចជា ល្បែងអនឡាញ ការជីកយករ៉ែគ្រីបតូ។

ការបោកប្រាស់ផ្សេងទៀតរួមមាន ការបោកប្រាស់ស្នេហា ការបោកប្រាស់តាមទូរស័ព្ទ ដែលអ្នកបោកប្រាស់ព្យាយាមលួចលុយ ឬព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក។ ការបោកប្រាស់អាចកើតឡើងតាមរយៈការហៅទូរសព្ទពីមនុស្សពិត ការហៅពីមនុស្សយន្ត ឬសារជាអក្សរ។

លើសពីនេះ ការបោកប្រាស់ក្នុងការវិនិយោគដែលសន្យាថានឹងទទួលបានផលចំណេញខ្ពស់ ដោយគ្មានហានិភ័យផ្នែកហិរញ្ញវត្ថុ ក៏ស្ថិតនៅជួរមុខនៃសកម្មភាពទាំងនេះ ដែលបានបំផ្លាញជីវិត លើសពីការបោកប្រាស់ដែលបង្ខំឱ្យបោកប្រាស់រាប់លាននាក់ពីមនុស្សដែលមិនបានចាប់អារម្មណ៍ និងលោភលន់ ប៉ុន្តែជីវិតរបស់អ្នកដែលបោកប្រាស់គេ ក៏ត្រូវបានគេបង្ខំដូចគ្នា។ Philstar.com

## ព្រឹទ្ធសមាជិកហ្វីលីពីន៖ ការជួញដូរប្រជាជនហ្វីលីពីនសម្រាប់ធ្វើជាអ្នកបោកប្រាស់នៅកម្ពុជាពាក់ព័ន្ធនឹងមន្ត្រីអន្តោប្រវេសន៍

https://www.khmertimeskh.com/501223451//?p=1223451 January 21, 2023

ព្រឹទ្ធសមាជិក លោកស្រី Risa Hontiverosកាលពីថ្ងៃសុក្របានបង្ហាញការចូលរួមរបស់មន្ត្រីការិយាល័យអន្តោប្រវេសន៍ (BI) មួយចំនួនក្នុងការជួញដូរជនជាតិហ្វីលីពីននៅក្នុងប្រទេសកម្ពុជាដែលបន្ទាប់មកត្រូវបានបង្ខំឱ្យធ្វើការជា "អ្នកបោកប្រាស់គ្រីបតូ" សម្រាប់ម៉ាហ្វីយ៉ាចិន។ លោកស្រី Hontiveros បានលើកឡើងពីសក្ខីកម្មរបស់ជនរងគ្រោះម្នាក់ឈ្មោះ"Miles"ក្នុងចំណោមជនរងគ្រោះដែលបានជួយសង្គ្រោះនៅកម្ពុជា។ Miles បានចែករំលែកថា ជនរងគ្រោះពីការជួញដូរមួយចំនួនជាមួយគាត់ ត្រូវបានណែនាំឱ្យចាកចេញពីប្រទេសពី Clark, Pampanga ខណៈដែលភ្នាក់ងារ ដែលជ្រើសរើសពួកគេមានការទាក់ទងជាមួយមន្ត្រីអន្តោប្រវេសន៍នៅក្នុងព្រលានយន្តហោះនោះ។ យោងតាម Miles អ្នកជ្រើសរើសនឹងបង់ប្រាក់ប្រហែល ៧៥០០០ប៉េសូ (P75,000) ទៅ ១០០,០០០ប៉េសូ (P100,000) ដល់មន្ត្រីអន្តោប្រវេសន៍សម្រាប់រាល់ជនជាតិហ្វីលីពីនដែលពួកគេអនុញ្ញាតឱ្យចាកចេញដោយគ្មានការសួរនាំ។ សមាជិកព្រឹទ្ធសភាបានមានប្រសាសន៍ថា "ប្រសិនបើជាការពិត វាជារឿងអកុសលដែលបុគ្គលិករដ្ឋាភិបាលគឺជាអ្នកដែលបង្កគ្រោះថ្នាក់ដល់ប្រជាជនហ្វីលីពីនរបស់យើង"។

នាយកដ្ឋានពលករចំណាកស្រុកសម្លឹងមើលទៅក្នុងម៉ូឌុលម៉ាហ្វីយ៉ាចិន ដោយប្រើពលករហ្វីលីពីននៅក្រៅប្រទេសជាអ្នកបោកប្រាស់រូបិយប័ណ្ណគ្រីបតូ។ លោកស្រីHontiverosបានមានប្រសាសន៍ថា មន្ត្រីអន្តោប្រវេសន៍ និងអ្នកគ្រប់គ្រងស្ថានីយអាកាសយានដ្ឋាន នឹងត្រូវបានអញ្ជើញឱ្យចូលរួមក្នុងសវនាការនាពេលខាងមុខរបស់គណៈកម្មាធិការព្រឹទ្ធសភាស្តីពីស្ត្រី កុមារ ទំនាក់ទំនងគ្រួសារ និងសមភាពយេនឌ័រ ដើម្បីដោះស្រាយ "ករណីដែលមិនទាន់ចប់នៃការជួញដូរមនុស្សនៅក្រៅប្រទេសនៃប្រជាជនហ្វីលីពីន" ។ ព្រឹទ្ធសមាជិកបានឱ្យដឹងថា អ្នកណាក៏ដោយដែលឃុបឃិតជាមួយអ្នកជ្រើសរើសពលករខុសច្បាប់ និងក្រុមបោកប្រាស់ ដើម្បីបោកបញ្ឆោតប្រជាជនហ្វីលីពីននឹងត្រូវទទួលខុសត្រូវ"។កាលពីឆ្នាំមុន លោកស្រីHontiverosក៏បានបង្ហាញពីការជួញដូរជនជាតិហ្វីលីពីននៅក្នុងប្រទេសមីយ៉ាន់ម៉ា ដើម្បីធ្វើការជា "អ្នកបោកប្រាស់គ្រីបតូ"។ ABS-CBN News

# ស្ត្រីហ្វីលីពីនដែលធ្វើដំណើរទៅកម្ពុជាត្រូវបានឃាត់ ចំណែកមន្ត្រីការិយាល័យអន្តោប្រវេសន៍៤នាក់ស្ថិតក្រោមការស៊ើបអង្កេត

https://www.khmertimeskh.com/501223767// January 22, 2023

ភ្នាក់ងារនៃការិយាល័យអន្តោប្រវេសន៍ (BI) បានទប់ស្កាត់ជនរងគ្រោះពីការជួញដូររូបិយប័ណ្ណគ្រីបតូចំនួនប្រាំមួយនាក់ ដែលត្រូវបានគេសន្មត់ថា នឹងមកកាន់ប្រទេសកម្ពុជាតាមរយៈអាកាសយានដ្ឋានអន្តរជាតិ Clark (CIA) ក្នុងទីក្រុង Pampanga ។ ស្នងការការិយាល័យអន្តោប្រវេសន៍លោក Norman Tansingco បាននិយាយថា ឧបទ្ទវហេតុនេះបានបង្កឱ្យមានការស៊ើបអង្កេតមួយ ខណៈដែលមន្ត្រីរបស់ខ្លួនចំនួន ៤នាក់ ត្រូវបានគេជឿថា មានជាប់ពាក់ព័ន្ធក្នុងសកម្មភាពខុសច្បាប់នេះ។ គាត់បាននិយាយថា តាមពិតទៅ មន្ត្រីអន្តោប្រវេសន៍ម្នាក់ត្រូវបានគេរកឃើញថា បានរត់ការឯកសារអ្នកដំណើរសម្រាប់ការចាកចេញ។

លោក Tansingco បានបន្តថា៖ «មន្ត្រីអន្តោប្រវេសន៍រូបនេះរង់ចាំលទ្ធផលនៃការស៊ើបអង្កេត។ បុគ្គលិកអន្តោប្រវេសន៍បីនាក់ផ្សេងទៀត ត្រូវបានរួមបញ្ចូលនៅក្នុងការស៊ើបអង្កេតសម្រាប់ការជាប់ពាក់ព័ន្ធ ដែលអាចកើតមាននៅក្នុងករណីនេះ។ អ្នកដំណើរទាំងប្រាំមួយនាក់ ហៀបនឹងឡើងយន្តហោះ Jetstar ទៅកាន់ទីក្រុងភ្នំពេញកាលពីសប្តាហ៍មុន នៅពេលដែលពួកគេត្រូវបានហាមឃាត់មិនឱ្យចាកចេញ សម្រាប់គោលបំណង ដែលមានការសង្ស័យនៃការធ្វើដំណើររបស់ពួកគេ។ លោក Tansingco បាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយថា "ពួកគេបានផ្តល់ចម្លើយមិនស៊ីសង្វាក់គ្នាចំពោះសំណួរក្នុងអំឡុងពេលសម្ភាសន៍ ដែលបង្កឱ្យមានការសង្ស័យថា ពួកគេគ្រាន់តែក្លែងធ្វើជាភ្ញៀវទេសចរ ប៉ុន្តែគោលបំណងរបស់ពួកគេគឺ ដើម្បីធ្វើការនៅបរទេស" ។

អ្នកដំណើរបានត្រៀមឡើងយន្តហោះរបស់ពួកគេ បន្ទាប់ពីត្រូវបានរៀបចំឯកសាររួចរាល់នៅបញ្ជរអន្តោប្រវេសន៍ នៅពេលដែលពួកគេត្រូវបានឃាត់ទុក និងនាំទៅសាកសួរដោយមន្ត្រីមកពីអង្គភាពត្រួតពិនិត្យការធ្វើដំណើរ និងអនុវត្តច្បាប់ (TCEU) របស់ការិយាល័យអន្តោប្រវេសន៍។ លោកបានបន្ថែមថា អ្នកដំណើរទាំងនោះធ្វើពុតជាស្គាល់គ្នា ប៉ុន្តែមិនអាចពន្យល់ពីរបៀប ឬពេលដែលពួកគេបានជួបនោះទេ។

ប្រធានអង្គភាពត្រួតពិនិត្យការធ្វើដំណើរ និងអនុវត្តច្បាប់ (TCEU) របស់ការិយាល័យអន្តោប្រវេសន៍លោក Ann Camille Mina បានរាយការណ៍ថា ក្រៅពីការផ្តល់សេចក្តីថ្លែងហេតុមិនស៊ីសង្វាក់គ្នា អ្នកដំណើរក៏បានបង្ហាញសំបុត្រធ្វើដំណើរត្រឡប់មកវិញក្លែងក្លាយផងដែរ។ លោក Mina បាននិយាយថា "នៅទីបំផុតពួកគេបានសារភាពថាពួកគេនឹងធ្វើការនៅក្នុងមជ្ឈមណ្ឌលហៅទូរស័ព្ទក្នុងប្រទេសកម្ពុជា ហើយត្រូវបានជ្រើសរើសតាមរយៈ Facebook" ។ ប្រតិបត្តិការនេះគឺជាផ្នែកមួយនៃការបង្ក្រាបរបស់រដ្ឋាភិបាលប្រឆាំងនឹងក្រុមដែលជ្រើសរើសជនជាតិហ្វីលីពីនឱ្យធ្វើការជាបុគ្គលិកសម្រាប់ក្រុមបោកប្រាស់រូបិយប័ណ្ណគ្រីបតូ ដែលកំពុងប្រតិបត្តិការនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ Manila Bulletin

# ក្រសួងមហាផ្ទៃ និង ក្រសួងការងារ ដាក់ផែនការ ៦ ខែ ដើម្បីប្រឆាំងអំពើជួញដូរមនុស្សនិងជួញដូរពលកម្ម

https://www.postkhmer.com/national/2023-01-22-1735-246167.html ឡុង គីមម៉ារីតា | Publication date 22 January 2023 | 17:35 ICT

**ភ្នំពេញៈ** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងមហាផ្ទៃ ដាក់ចេញផែនការសកម្មភាពរួមគ្នារយៈពេល ៦ខែ ដើម្បីចុះត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស តាមសហគ្រាស គ្រឹះស្ថាន ក្នុងការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម ឬបទល្មើសផ្សេងៗដោយប្រើប្រាស់ជនបរទេសនៅកម្ពុជា។ ការដាក់ចេញផែនការរួមគ្នានេះ បានធ្វើឡើងក្នុងពិធីផ្សព្វផ្សាយការងារគ្រប់គ្រងហត្ថពលកម្មបរទេសនៅ កម្ពុជា កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ បន្ទាប់ពីក្រសួងទាំង ២ បានអនុវត្តតាមច្បាប់ស្តីពីអន្តោប្រវេសន៍ និងច្បាប់ស្តីពីការងារ ដោយបានចុះធ្វើអធិការកិច្ចហត្ថពលកម្មបរទេសតាមសហគ្រាស គ្រឹះស្ថាន ដែលបានចាប់ផ្តើមដំណើរការនៅឆ្នាំ២០០០។

ក្នុងឱកាសនោះ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានថ្លែងថា តាមរយៈការផ្សព្វផ្សាយរបស់ក្រសួងទាំង២គឺម្ចាស់ឬក៏នាយកសហគ្រាសគ្រឹះស្ថានភាគច្រើនបានយល់ដឹង និងចូលរួមអនុវត្តច្បាប់ស្តីពីអន្តោប្រវេសន៍ និងច្បាប់ស្តីពីការងារកាន់តែល្អប្រសើរ។ ទោះជាយ៉ាងណា លោកបានអះអាងថា គណៈកម្មការអន្តរក្រសួងជំរុញនិងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស បានដាក់ចេញនូវយុទ្ធនាការប្រតិបត្តិការដែលមានរយៈពេល៦ខែ ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២៣។ លោកបានបន្តថា ផែនការនេះត្រូវបានបែងចែកជា២ដំណាក់កាលដោយដំណាក់កាលទី១មានរយៈពេល៣ខែ ចាប់ពីខែមករា ដល់ខែមីនា ឆ្នាំ ២០២៣ ជាដំណាក់កាលផ្សព្វផ្សាយបានទូលំទូលាយដល់សហគ្រាស គ្រឹះស្ថានដែលមានប្រើប្រាស់ហត្ថពលកម្មបរទេស និងគ្រប់ភាគីពាក់ព័ន្ធ ដើម្បីយល់ជ្រួតជ្រាប និងចូលរួមអនុវត្ត ព្រមទាំងផ្សព្វផ្សាយបន្តនូវគោលការណ៍វិធានការដែលច្បាប់បានកំណត់អំពីការងារអធិការកិច្ចហត្ថពលកម្មបរទេស។

លោកបានបញ្ជាក់ថា៖«ក្នុងដំណាក់កាលផ្សព្វផ្សាយ តម្រូវឱ្យសហគ្រាស គ្រឹះស្ថាន ដែលប្រើប្រាស់ហត្ថពលកម្មបរទេសបំពេញរបាយការណ៍ស្វ័យប្រកាសអំពីការប្រើប្រាស់ហត្ថពលកម្មបរទេសដូច ដែលមានគំរូផ្តល់ជូន និងត្រូវបញ្ជូនមកវិញតាមរយៈការងារអធិការកិច្ចហត្ថពលកម្មបរទេស នៅរាជធានី-ខេត្ត ឱ្យបានមុនថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២៣។ ចំណែកដំណាក់កាលទី២ លោក អ៊ិត សំហេង បានអះអាងថា គឺមានរយៈពេល ៣ ខែ ចាប់ពីខែមេសា ដល់ដំណាច់ ខែមិថុនា ឆ្នាំ២០២៣ ជាដំណាក់កាលចុះអធិការកិច្ចជាក់ស្តែងនៅតាមគ្រប់សហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់ហត្ថពលកម្មបរទេស ដោយផ្អែកតាមស្វ័យរបាយការណ៍ និងប្រតិទិនរបស់ក្រុមការងារ។

លោកបានបញ្ជាក់ថា៖«ផែនការសកម្មភាពនេះ ក៏មានគោលបំណងក្នុងការចូលរួមចំណែកគាំទ្រដល់ផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ បទល្មើសពាក់ព័ន្ធល្បែងស៊ីសងខុសច្បាប់ ការឆបោកតាមប្រព័ន្ធអនឡាញ បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ឬបទល្មើសផ្សេងៗទៀត សំដៅចូលរួមថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម»។ លោក អ៊ិត សំហេង ប្រកាសដែរថា រាល់ពេលចុះប្រតិបត្តិការគឺត្រូវមានការសម្របសម្រួលពីស្ថាប័នអយ្យការអមសាលាដំបូង រាជធានី-ភ្នំពេញ ។ ក្នុងអំឡុងពេលប្រតិបត្តិការ ម្ចាស់ ឬនិយោជក ត្រូវបង្ហាញវត្តមានពលករបរទេសគ្រប់រូបនិងឯកសារពាក់ព័ន្ធរបស់ពួកគេម្នាក់ៗដល់ក្រុមអធិការកិច្ចហត្ថពលកម្មបរទេស ហើយ ក្នុងករណីរកឃើញបទល្មើសដទៃទៀត ក្រុមការងារអធិការកិច្ចហត្ថពលកម្មបរទេស ត្រូវរាយការណ៍ជូនអភិបាលរាជធានី-ខេត្ត ដើម្បីសុំគោលការណ៍ចាត់វិធានការស្របតាមនីតិវិធី។

តាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឱ្យដឹងថា ការផ្តល់បណ្ណការងារ ឬសៀវភៅការងារដល់ជនបរទេសមានការកើនឡើងពី ៤០០ នាក់ នៅក្នុងឆ្នាំ២០១៣ ដល់ប្រមាណ ២០៧ ៨៨៦នាក់ នៅក្នុងឆ្នាំ២០១៩។ ប៉ុន្តែចំនួននេះ បានថយចុះមកវិញក្នុងអំឡុងជួបវិបត្តិកូវីដ១៩ ដែលមានចំនួន ១៨១ ៦៥៣នាក់ គិតត្រឹមឆ្នាំ ២០២២ ដែលនាំឱ្យក្រសួងការងាររកចំណូលចូលថវិកាជាតិ និង ប្រាក់ពិន័យសរុបប្រមាណ ២២,៨ លានដុល្លារ។

លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានជំរុញឱ្យគណៈកម្មការអន្តរក្រសួងបន្តពង្រឹងនិងលើកកម្ពស់ការទទួលខុសត្រូវក្នុងការបំពេញការងាររួមគ្នារបស់ក្រសួងស្ថាប័ន អាជ្ញាធរពាក់ព័ន្ធក្នុងការគ្រប់គ្រងហត្ថពលកម្មបរទេសឱ្យត្រឹមត្រូវតាមច្បាប់។ បន្ថែមពីនេះ លោកក៏បានអំពាវនាវដល់កម្មករនយោជិតបរទេស និយោជកនៃរោងចក្រសហគ្រាស មូលដ្ឋានអាជីវកម្ម និងអ្នកពាក់ព័ន្ធទាំងអស់ ផ្តល់ការគាំទ្រ និងចូលរួមអនុវត្តឱ្យបានត្រឹមត្រូវ ចៀសវាងទទួលរងនូវទណ្ឌកម្មណាមួយពីមន្ត្រីមានសមត្ថកិច្ច។ លោក ស ខេង បានបញ្ជាក់ថា៖«ក្នុងពេលចុះធ្វើអធិការកិច្ចករណីរកឃើញតម្រុយសង្ស័យបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម អាជីវកម្មផ្លូវភេទ ឬបទល្មើសផ្សេងៗទៀត ក្រុមចម្រុះអធិការកិច្ច ត្រូវរាយការណ៍ជាបន្ទាន់មកគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត និងគណៈកម្មការអន្តរក្រសួងដើម្បីចាត់វិធានការស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន»៕

## ស្ថានទូតហ្វីលីពីន
## បញ្ជូនជួយជនរងគ្រោះ៨នាក់ដែលសង្គ្រោះចេញពីកន្លែងជួញដូរមនុស្សនៅកម្ពុជា

https://www.rfa.org/khmer/news/human-rights/philippine-embassy-prepares-to-repatriate-8-victims-of-human-trafficking-in-cambodia-01222023084808.html ដោយ សេក បណ្ឌិត2023.01.22

ស្ថានទូតហ្វីលីពីនប្រចាំកម្ពុជា (Philippine) ត្រៀមរៀបចំបញ្ជូនពលរដ្ឋហ្វីលីពីនចំនួន៨នាក់ ដែលរងគ្រោះពីការជួញដូរមនុស្សនៅកម្ពុជា។ សារព័ត៌មាន ស៊ី.អ៊ិន.អ៊ិន ហ្វីលីពីន (CNN) ចុះផ្សាយថា ជនរងគ្រោះជាជនជាតិហ្វីលីពីន៨នាក់នេះ ត្រូវបានជនជាតិចិន លួងលោមឲ្យទៅធ្វើការងារនៅកម្ពុជា ហើយបន្ទាប់មកបង្ខាំងនិងបង្ខំពួកគេឲ្យធ្វើការឆបោកតាមប្រព័ន្ធអ៊ីនធឺណិត(Oline)។ វិទ្យុអាស៊ីសេរី មិនអាចសុំការឆ្លើយតបបន្ថែមពីស្ថានទូតហ្វីលីពីនប្រចាំកម្ពុជាបានទេនៅថ្ងៃទី២១ មករា។ទោះជាយ៉ាងណា មន្ត្រីក្រសួងការបរទេសហ្វីលីពីនប្រាប់សារព័ត៌មានស៊ី.អ៊ិន.អ៊ិន ហ្វីលីពីនថា"ស្ថានទូតនៅភ្នំពេញ បានស្នើសុំក្រសួងការបរទេសជួយផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់ធ្វើមាតុភូមិនិវត្តន៍ប្រជាជនហ្វីលីពីនទៅផ្ទះវិញឆាប់ៗនេះ"។

ទាក់ទិនរឿងនេះ នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការលីកាដូ(Licadho) លោក អំ សំអាត មានប្រសាសន៍ថា រដ្ឋាភិបាលគួរតែពិនិត្យមើលលទ្ធភាពបញ្ជូនជនរងគ្រោះទាំងនោះត្រឡប់ទៅវិញ។លោកបន្តថាការជួញដូរមនុស្សនៅកម្ពុជាស្ថិតនៅក្នុងក្តីព្រួយបារម្ភនៅឡើយ ដូច្នេះរដ្ឋាភិបាលគួរពង្រឹងការអនុវត្តច្បាប់ ពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធ ហើយ បើសិនជាមានមន្ត្រីពាក់ព័ន្ធនឹងការជួញដូរមនុស្សគឺត្រូវដាក់ទោសមិនថាមន្ត្រីតាមច្បាប់។ ក្រៅពីនេះលោកជំរុញអាជ្ញាធរកម្ពុជាត្រូវបង្កើនកិច្ចសហប្រតិបត្តិជាមួយប្រទេសជិតខាង ដើម្បីទប់ស្កាត់កុំឱ្យមានលំហូរការជួញដូរមនុស្សពីប្រទេសជិតខាង និងលុបបំបាត់អំពើពុករលួយ។ លោក អំ សំអាត៖ «ផលប៉ះពាល់ទាក់ទងនឹងបញ្ហាសុខភាព សុវត្ថិភាព បញ្ហាសេដ្ឋកិច្ចគ្រួសារបញ្ហាមួយទៀតគឺវាជះឥទ្ធិពលមិនល្អសម្រាប់សង្គមជាតិយើងគឺធ្វើឱ្យកម្ពុជាយើងរងនៅការរិះគន់បន្តទៀតទាក់ទងនឹងការជួញដូរមនុស្សហ្នឹង អ៊ីចឹងកាលណាកម្ពុជាយើងស្ថិតនៅក្នុងបញ្ជីខ្មៅឬការរិះគន់ធ្ងន់ធ្ងរគឺវាប៉ះពាល់តទៅទៀតដូចជាការអភិវឌ្ឍន៍គ្រប់វិស័យ ទេសចរណ៍សន្តិសុខសុវត្ថិភាព ករណីនៃការជួញដូរមនុស្សនៅតែបន្តហើយកើតឡើង»។

កន្លងមកក្រសួងមហាផ្ទៃ បានជួយសង្គ្រោះជនរងគ្រោះរាប់រយនាក់ ចេញពីអគារក្រុមហ៊ុននានានៅក្នុងភ្នំពេញ ខេត្តព្រះសីហនុ និងតាមបណ្តាខេត្តផ្សេងៗទៀត ដែលរងគ្រោះដោយសារតែអំពើជួញដូរមនុស្ស។ជនរងគ្រោះដែលសមត្ថកិច្ចជួយសង្គ្រោះកន្លងមករួមមានជនជាតិឥណ្ឌូណេស៊ី វៀតណាម ថៃ ម៉ាឡេស៊ី ចិន ប៉ាគីស្ថាន ឥណ្ឌា មីយ៉ាន់ម៉ា ហ្វីលីពីនជាដើម ហើយតែងតែបញ្ជូនពួកគេទៅប្រទេសដើមវិញជាបន្តបន្ទាប់។ រដ្ឋាភិបាលនៃប្រទេសទាំងនោះរួមទាំងហ្វីលីពីនផង ក៏ធ្លាប់ស្នើសុំឲ្យរដ្ឋាភិបាលកម្ពុជា ជួយសង្គ្រោះពលរដ្ឋរបស់ខ្លួនចេញពីកន្លែងជួញដូរនោះដែរ។សារព័ត៌មានអន្តរជាតិធំៗរកឃើញថា មេខ្លោងជួញដូរមនុស្សទាំងនោះភាគច្រើនជាជនជាតិចិនដែលឃុបឃិតជាមួយមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលកម្ពុជា និងឧកញ៉ាមួយចំនួនរួមទាំងសាច់ញាតិរបស់លោក ហ៊ុន សែនផងដែរ។

កន្លងមកទោះបីជារដ្ឋាភិបាល លោក ហ៊ុន សែន សម្តែងការបារម្ភអំពើការជួញដូរមនុស្សនេះ ប៉ុន្តែរដ្ឋាភិបាល និងស្ថាប័នអនុវត្តច្បាប់ មិនបានស៊ើបអង្កេតក្រុមឧកញ៉ា និងមន្ត្រីគ្រាក់ៗដែលរងការចោទប្រកាន់ថា ជាមេខ្លោងឈរជើងកាងការពារឱ្យជនជាតិចិនប្រតិបត្តិការចាប់បង្ខាំង និងជួញដូរមនុស្សនៅកម្ពុជានេះនៅឡើយទេ និងថែមទាំងចេញការពារជនសង្ស័យទាំងនោះទៀតផង៕

# ថ្ងៃទី២៦ ខែ មករា ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ២ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិវៀតណាម ០២នាក់

http://freshnewsasia.com/index.php/en/localnews/275246-2023-01-24-04-18-26.html 2023-01-24 11:18am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២២ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិវៀតណាម ចំនួន ០២នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៧១៥ករណី មានមនុស្ស ១,៧៥០នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៤៩សំណើ និងបិទសំណុំរឿង ២២៩សំណើ (រកឃើញមនុស្ស ១,០៥៨នាក់, ឃាត់ខ្លួនជនសង្ស័យ ១២២នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៧ករណី៕

## ពលករចំណាកស្រុកខ្មែរនៅប្រទេសថៃមានពេលរហូតដល់ពាក់កណ្ដាលខែឧសភាដើម្បីទទួលបានបណ្ណការងារ

https://www.khmertimeskh.com/501224954/-4/ Khmer Times January 24, 2023

នាយកដ្ឋានការងាររបស់ប្រទេសថៃ កំពុងពន្យាពេលកំណត់សម្រាប់ពលករចំណាកស្រុកបរទេសចុះឈ្មោះទទួលបានបណ្ណការងារថ្មីរហូតដល់ពាក់កណ្ដាលខែឧសភា។ ពលករជាច្រើនមកពីប្រទេសកម្ពុជា មីយ៉ាន់ម៉ា ឡាវ និងវៀតណាម នៅតែស្ថិតក្នុងដំណើរការបន្តលិខិតឆ្លងដែនរបស់ពួកគេជាមួយអាជ្ញាធរ ហើយទំនងជានឹងមិនអាចធ្វើទាន់ដោយសារថ្ងៃផុតកំណត់គឺនៅថ្ងៃទី ១៣ ខែកុម្ភៈ។

លោកបាននិយាយថា ប្រសិនបើល្បឿនក្នុងការចុះឈ្មោះនាពេលបច្ចុប្បន្ននៅតែបន្ត តិចជាង១៥ ភាគរយនៃពលករចំណាកស្រុកច្រើនជាងពីរនាក់មកពីប្រទេសមីយ៉ាន់ម៉ាដែលត្រូវការបន្តបណ្ណការងាររបស់ពួកគេនឹងអាចដាក់ពាក្យសុំរបស់ពួកគេដោយជោគជ័យ។ ពលករចំណាកស្រុកភាគច្រើននៅតែរង់ចាំទទួលលិខិតឆ្លងដែនថ្មីពីស្ថានទូតរបស់ពួកគេក្នុងប្រទេសថៃ ប៉ុន្តែវាទាមទារពេលវេលា។ អ្នកដែលមានលិខិតឆ្លងដែនជិតផុតកំណត់ក៏តម្រូវឱ្យធ្វើលិខិតឆ្លងដែនថ្មីផងដែរ មុនពេលដែលពួកគេអាចបន្តបណ្ណការងារ។ ពលករចំណាកស្រុកជាច្រើនមកពីប្រទេសកម្ពុជា ឡាវ និងវៀតណាម កំពុងប្រឈមនឹងបញ្ហាស្រដៀងគ្នានេះ។ ពួកគេជាច្រើនរំពឹងថានឹងទទួលបានលិខិតឆ្លងដែនថ្មីនៅចន្លោះចុងខែកុម្ភៈដល់ចុងខែមីនា។ លិខិតឆ្លងដែនរបស់ពលករចំណាកស្រុកទាំងនេះ បានផុតកំណត់ ខណៈដែលពួកគេជាប់គាំងនៅក្នុងប្រទេសថៃ អំឡុងពេលរាតត្បាតជំងឺកូវីដ-១៩ នៅពេលដែលព្រំដែនត្រូវបានបិទ។

ខណៈដែលកំពុងរង់ចាំការយល់ព្រមពីគណៈកម្មាធិការរបស់រដ្ឋាភិបាលស្ដីពីការគ្រប់គ្រងពលករចំណាកស្រុកដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារលោក Suchart Chomklin នាយកដ្ឋានការងារ បានកែសម្រួលបទប្បញ្ញត្តិមួយចំនួនដើម្បីបង្កភាពងាយស្រួលដល់ពលករក្នុងការដាក់ពាក្យសុំម្តងទៀត។ ថ្មីៗនេះ នាយកដ្ឋានបានអនុញ្ញាតឱ្យពលករបង់ប្រាក់សម្រាប់ថ្លៃស្នើសុំបណ្ណការងារនៅសាខា 7-Eleven នៅទូទាំងប្រទេសមុនថ្ងៃទី១៣ ខែកុម្ភៈ ព្រមទាំងអនុញ្ញាតឱ្យពួកគេបញ្ជូនឯកសារដែលត្រូវការសម្រាប់ការបន្តបណ្ណការងារ រួមទាំងលិខិតឆ្លងដែនរបស់ពួកគេនៅពេលក្រោយក្នុងរយៈពេល៩០ ថ្ងៃនៃការដាក់ពាក្យ។ ការទទួលបានការបង់ប្រាក់របស់ពួកគេក្នុងការស្នើសុំបណ្ណការងារនឹងកើនឡើងទ្វេដង ខណៈដែលបណ្ណការងាររហូតដល់ថ្ងៃទី ១៥ ខែឧសភា។ Bangkok Post

## ជនជាតិបង់ក្លាដែសធ្លាក់ខ្លួនជា "ជនរងគ្រោះរបស់ប្រតិបត្តិការអ៊ីនធឺណិតខុសច្បាប់" នៅកម្ពុជា

https://www.khmertimeskh.com/501225055// Khmer Times January 24, 2023

កាសែត The Daily Star ដែលជាកាសែតឈានមុខគេរបស់ប្រទេសបង់ក្លាដែសបានគូសបញ្ជាក់ថា វិស័យឌីជីថលត្រូវបានក្រុមខិលខូចមួយចំនួនប្រើប្រាស់យ៉ាងទូលំទូលាយសម្រាប់ដាក់អន្ទាក់ល្បួង និងបោកប្រាស់ ដែលតម្រូវឱ្យអ្នកប្រើប្រាស់មានការប្រុងប្រយ័ត្នបំផុត។ សំណួរសួថាតើយើងដឹងអ្វីខ្លះពីអ្នកដែលនៅពីក្រោយការឆបោកនេះ? ខណៈដែលអ្នកក្លែងបន្លំតាមប្រព័ន្ធអ៊ីនធឺណិតអាចរក្សាការសម្ងាត់របស់ខ្លួន របាយការណ៍ស៊ើបអង្កេតមួយរបស់ The Daily Star បានបង្ហាញពីរបៀបដែលជនជាតិបង់ក្លាដែសរងគ្រោះពីការជួញដូរនៅកម្ពុជា ដែលប្រតិបត្តិការបោកប្រាស់បានរីករាលដាលក្នុងអំឡុងពេលជំងឺរាតត្បាត ដែលជនរងគ្រោះត្រូវបានបង្ខំឱ្យធ្វើការអោយក្រុមធ

បោកតាមអ៊ីនធឺណិត។ របាយការណ៍នេះបានបង្ហាញពីជនរងគ្រោះជាច្រើននាក់ដែលបានចែករំលែកបទពិសោធរបស់ពួកគេ ខណៈដែលមនុស្សរាប់រយនាក់ទៀតត្រូវគេជឿថាកំពុងត្រូវបានបង្ខាំងដោយក្រុមជនពាលនៅឡើយ។

ជនរងគ្រោះទាំងនេះមកពីប្រទេសអាស៊ីមួយចំនួន រួមទាំងប្រទេសបង់ក្លាដែស ដែលគេហៅថា "ទាសភាពតាមអ៊ីនធឺណិត" ។ ម្នាក់ក្នុងចំនោមពួកគេគឺ Foysal Hossain អាយុ២៥ ឆ្នាំបានមកកម្ពុជានៅដើមឆ្នាំ២០២១ ដោយសង្ឃឹមបានការងារជាអ្នកទទួលភ្ញៀវ ផ្ទុយទៅវិញ យុវជនរូបនេះត្រូវបានលក់ទៅឱ្យក្រុមជនបោកប្រាស់តាមអ៊ីនធឺណិត។ គាត់ត្រូវបានគេឃុំឃាំងនៅក្នុងអគារមួយដែលមានឈ្មោះថា The Crown College ដែលបានបំពាក់ឧបករណ៍ឌីជីថលដើម្បីបោកប្រាស់យកលុយពីពលរដ្ឋអាមេរិក។ ដំបូងឡើយគាត់បានបដិសេធ ប៉ុន្តែដោយខ្លាចការវាយដំ ឆក់ដោយចរន្តអគ្គិសនី និងឃុំនៅក្នុងបន្ទប់ គាត់ក៏យល់ព្រមធ្វើតាមបញ្ជារបស់ក្រុមជនពាលទាំងនោះ។

ជាក់ស្តែង មានទីតាំងជាច្រើនដូចជា The Crown College ដែលត្រូវបានប្រដូចទៅនឹង "ឋាននរក" នៅក្នុងរបាយការណ៍ឆ្នាំ២០២២ ដោយ Vitit Muntarbhorn អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ មនុស្សរាប់ពាន់នាក់ត្រូវបានបង្ខាំងនៅក្នុងបរិវេណដែលមានការឃោមកាមយ៉ាងតឹងរ៉ឹង បន្ទាប់ពីត្រូវបានល្បួងដោយសន្យាផ្តល់ការងារដែលមានប្រាក់ខែខ្ពស់ ហើយបន្ទាប់មកត្រូវបានជួញដូរជាបន្តបន្ទាប់។ ការជំរិតទារប្រាក់ និងអំពើហិង្សា គឺជាវិធីសាស្ត្រនៃការរំលោភបំពានដែលប្រើដោយក្រុមជនពាលចំពោះជនរងគ្រោះណាដែលមិនព្រមធ្វើតាមបញ្ជា។ ចំពោះអ្នកដែលមិនអាចបំពេញការងារតាមគោលការណ៍បានត្រូវបានលក់បន្តជាច្រើនដង ឬស្លាប់ដោយការធ្វើទារុណកម្ម។

កាសែត The Daily Star បាននិយាយថា ខ្លួនបាននិយាយជាមួយជនរងគ្រោះមួយចំនួន ដែលបានចែករំលែកព័ត៌មានដ៏គួរឱ្យរន្ធត់នៃទុក្ខលំបាករបស់ពួកគេ នៅពេលដែលពួកគេបានធ្វើការអោយក្រុមជនពាលក្លែងបន្លំតាមអ៊ីនធឺណិត។ បោកបញ្ឆោត លក់ ធ្វើទារុណកម្ម និងបង្ខំឱ្យបោកប្រាស់ ពួកគេសុទ្ធតែមានរឿងស្រដៀងគ្នា ហើយពួកគេសំណាងដែលបានរួចខ្លួន។ អ្វីដែលពួកគេឈឺចាប់លើសពីនេះគឺ មិនមានការសហការពីស្ថានទូតបង់ក្លាដែសក្នុងប្រទេសថៃដែលជាប្រទេសជិតខាង (បង់ក្លាដែសគ្មានស្ថានទូតនៅកម្ពុជាទេ)។ ជនរងគ្រោះមួយចំនួនបានចោទប្រកាន់ថា ពួកគេត្រូវបង់ប្រាក់សំណូកសម្រាប់ឯកសារ/លិខិតអនុញ្ញាត នឹងមិនត្រូវបានយកចិត្តទុកដាក់នៅពេលពួកគេទៅជួបមន្ត្រីស្ថានទូតដើម្បីសុំជំនួយ។ នៅពេលទាក់ទង តំណាងការិយាល័យធនធានមនុស្សការងារ និងបណ្តុះបណ្តាល (BMET) និងក្រសួងការបរទេសបង់ក្លាដេសបានអះអាងថា ពួកគេមិនបានដឹងអំពីទាសភាពរបស់ជនជាតិបង់ក្លាដែសនៅកម្ពុជា ដែលនេះពិបាកនឹងជឿ។

ច្បាស់ណាស់ អាជ្ញាធរនៅតែបដិសេធ ដែលនេះប៉ះពាល់ខ្លាំងដល់អ្នកដែលនៅជាប់ក្រោមការគ្រប់គ្រងរបស់ក្រុមជនពាល។ សារៈសំខាន់នៃការអន្តរាគមន៍នៅក្នុងបញ្ហានេះគឺមានសារៈសំខាន់ខ្លាំង។ កាសែត The Daily Star ជំរុញឲ្យអាជ្ញាធរថ្នាក់លើបង្កើនសកម្មភាពប្រឆាំងការជួញដូរមនុស្ស។ ពួកគេត្រូវលើកកម្ពស់ការយល់ដឹងក្នុងចំណោមជនចំណាកស្រុក ដោយចាត់វិធានការយ៉ាងម៉ឺងម៉ាត់ប្រឆាំងនឹងភ្នាក់ងារជ្រើសរើសបុគ្គលិក/ឈ្មួញកណ្តាលបោកប្រាស ជាពិសេសអ្នកដែលប្រតិបត្តិការតាមអ៊ីនធឺណិត និងធានាការសង្គ្រោះជនរងគ្រោះឱ្យបានឆាប់រហ័សជាមួយនឹងកិច្ចសហប្រតិបត្តិការពីអាជ្ញាធរនៅក្នុងប្រទេសគោលដៅ រួមទាំងប្រទេសកម្ពុជាផងដែរ។ ប្រទេសបង់ក្លាដែសត្រូវតែបង្កើនការអន្តរាគមន៍របស់ខ្លួនដើម្បីដោះស្រាយការកើនឡើងនៃការជួញដូរ និងទាសភាពតាមអ៊ីនធឺណិត។ មន្ត្រីកម្ពុជាសុំមិនបញ្ចេញឈ្មោះម្នាក់ដែលទទួលបន្ទុកជួយសង្គ្រោះជនបរទេស ដែលត្រូវបានបង្ខាំងដោយក្រុមជនពាលបានប្រាប់ខ្មែរថាមស៍ថា ប្រទេសបង់ក្លាដែសក៏ដូចប្រទេសដទៃទៀតដែលជនរងគ្រោះជាជនបរទេសត្រូវបានចោទប្រកាន់ថាត្រូវបានបង្ខាំងដោយក្រុមចោរបោកតាមអ៊ីនធឺណិតទាំងនេះដែរ ត្រូវចាត់វិធានការរួម និងស៊ីសង្វាក់គ្នា

ដោយសហការជាមួយអាជ្ញាធរកម្ពុជា ដើម្បីទប់ស្កាត់ការរើសពលករនៅប្រទេសបង់ក្លាដែសសម្រាប់អាជីវកម្មខុសច្បាប់នេះ ដែលអាចមានទីតាំងនៅកម្ពុជា ក៏ដូចជានៅតាមបណ្ដាប្រទេសអាស៊ានមួយចំនួនទៀត។

ព័ត៌មានត្រូវតែចែករំលែក ខណៈដែលកំណត់ត្រាបង្ហាញថាការចែករំលែកព័ត៌មាន និងការសហការគ្នាបាននាំទៅដល់ការជួយសង្គ្រោះជនបរទេសរាប់ពាន់នាក់ដែលជាប់នៅក្នុងក្ដាប់ក្រុមទាំងនេះ។ ជុំវិញបញ្ហានេះ មន្ត្រីនគរបាលមកពីប្រទេសមួយចំនួនបានជួបមន្ត្រីនគរបាលកម្ពុជារួចហើយ ទាក់ទងនឹងសកម្មភាពឆបោក និងស្ថានភាពពលករដែលត្រូវបានជ្រើសរើសដោយសន្យាផ្ដល់ប្រាក់ខែខ្ពស់។ មន្ត្រីរូបនេះបានសង្កត់ធ្ងន់ថា "ប្រសិនបើគ្មានការសហការ និងការផ្លាស់ប្ដូរព័ត៌មានទាំងនេះទេ វាពិតជាលំបាកណាស់ក្នុងការតាមដានជនបរទេសដែលត្រូវបានចោទប្រកាន់ថាត្រូវបានបង្ខាំងដោយក្រុមជនពាល"។ *The Daily Star/Khmer Times*

## យោធាកម្ពុជា-ថៃ ប្ដេជ្ញារួមគ្នាទប់ស្កាត់បទល្មើស គ្រប់ប្រភេទតាមព្រំដែន

https://dap-news.com/national/2023/01/25/307780/ BySKK106Posted on January 25, 2023

**ភ្នំពេញ៖ នៅក្នុងជំនួប ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ ទប់ស្កាត់និងបង្ក្រាបបទល្មើសតាមព្រំដែន នៅក្នុងទឹកដីខេត្តបន្ទាយមានជ័យ រវាងយោធា កម្ពុជា-ថៃ ភាគីទាំងពីរ បានប្ដេជ្ញារួមគ្នា ទប់ស្កាត់បទល្មើស គ្រប់ប្រភេទតាមព្រំដែន។**

ជំនួបនេះធ្វើឡើង នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ ដោយភាគីកម្ពុជា ដឹកនាំដោយឧត្ដមសេនីយ៍ទោ សេង ធារិន មេបញ្ជាការរង នាយសេនាធិការ យោធភូមិភាគទី៥ រីឯភាគីថៃ ដឹកនាំដោយឧត្ដមសេនីយ៍ទោ ផាក់ណា ខ្លែវផ្លតធុក មេបញ្ជាការកងទ័ពភូមិភាគទី១ថៃ។ ជំនួបទ្វេភាគីកម្ពុជា-ថៃ ត្រូវបានធ្វើឡើងនៅបរិវេណស្ពានមិត្តភាពកម្ពុជា-ថៃ ច្រកទ្វារព្រំដែនអន្តរជាតិ "ប៉ោយប៉ែត- ខ្លងលឹក"។ គោលបំណងនៃកិច្ចជំនួបនេះ គឺដើម្បីសំណេះសំណាលពិភាក្សាការងារ ក្នុងន័យ រឹតចំណងសម្ព័ន្ធមេត្រីភាព និងកិច្ចសហប្រតិបត្តិការ រវាងកងទ័ពទាំងពីរ យោធភូមិភាគទី៥កម្ពុជា-កងទ័ពភូមិភាគទី១ថៃ រួមមាន:

១-ការដោះស្រាយបញ្ហា តាមតំបន់ព្រំដែនបានកាន់តែល្អប្រសើរ ឡើង។

២-បន្តអនុវត្តន៍យន្តការ នៃជំនួបពិភាក្សា រវាងមេបញ្ជាការ កងទ័ពជើងគោកនៃប្រទេសទាំងពីរ ។

៣-គាំទ្រសកម្មភាពការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ រវាងប្រជាពលរដ្ឋនៃប្រទេសទាំងពីរ។

៤-បន្តកិច្ចសហប្រតិបត្តការទប់ស្កាត់ បញ្ហាគ្រឿងញៀន ចោរកម្មឆ្លងដែន ការកាប់បំផ្លាញព្រៃឈើ បទល្មើសផ្សេងៗ និងទប់ស្កាត់អំពើភេរវកម្ម ឧក្រិដកម្មតាមបណ្ដោយព្រំដែន៕

## ក្រសួងរកឃើញថា ជនបរទេសធ្វើការនៅកាស៊ីណូបាវិត ៩០ ភាគរយគឺខុសច្បាប់

https://www.khmertimeskh.com/501225520// Khmer Times January 25, 2023

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង បានបញ្ជាក់កាលពីថ្ងៃសុក្រសប្ដាហ៍មុនថា កាស៊ីណូស្របច្បាប់មួយចំនួននៅក្រុងបាវិត ខេត្តស្វាយរៀង កំពុងជួលជនបរទេសឲ្យធ្វើការភាគច្រើនដោយខុសច្បាប់។ ក្រសួងរកឃើញថា ជនបរទេសដែលធ្វើការ នៅកាស៊ីណូនេះជាង ៣.៨០០នាក់ ក្នុងនោះមានតែ ៤៧០នាក់ប៉ុណ្ណោះ ដែលមានប័ណ្ណការងារ និងសៀវភៅការងារត្រឹមត្រូវស្របច្បាប់។ ក្រសួងមហាផ្ទៃនឹងសហការជាមួយក្រសួងការងារក្នុងការធ្វើអធិការកិច្ចកំលាំងពលកម្មជនបរទេសនៅខេត្តស្វាយរៀង ដើម្បីបញ្ជាក់ថាតើពួកគេធ្វើការស្របច្បាប់ និងមានប័ណ្ណការងារឬយ៉ាងណា។ លោកបន្ថែមថា ផ្អែកលើសភាពការណ៍នេះ រាជរដ្ឋាភិបាលបានសម្រេចកែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស ដោយប្រគល់ភារកិច្ច

ជូនរដ្ឋមន្ត្រីក្រសួងការងារ ធ្វើជាប្រធានគណៈកម្មការ សំដៅពង្រីកវិសាលភាពការងារនេះនៅទូទាំងប្រទេស ដើម្បីពង្រឹង និងលើកកម្ពស់ការទទួលខុសត្រូវក្នុងការបំពេញការងាររួមគ្នារបស់ក្រសួងស្ថាប័ន អាជ្ញាធរពាក់ព័ន្ធក្នុងការគ្រប់គ្រងហត្ថពលកម្មបរទេសឱ្យត្រឹមត្រូវតាមច្បាប់។

លោកបានមានប្រសាសន៍ថា៖ «ខ្ញុំបានណែនាំគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត ត្រូវដឹកនាំ ណែនាំ សហការ សម្របសម្រួល ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធការគ្រប់គ្រង និងចុះធ្វើអធិការកិច្ចហត្ថពលកម្មបរទេសដល់កម្មករនិយោជិកបរទេស និងនិយោជកនៃរោងចក្រសហគ្រាស និងមូលដ្ឋានអាជីវកម្មនានាក្នុងមូលដ្ឋានរាជធានី-ខេត្តរបស់ខ្លួន ហើយតាមដាន ត្រួតពិនិត្យ ដំណើរការអធិការកិច្ចហត្ថពលកម្មបរទេសឱ្យបានម៉ត់ចត់»។ លោកបន្តថាអាជ្ញាធរត្រូវថែរក្សាឱ្យបានសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងមិនត្រូវធ្វើឱ្យប៉ះពាល់ ឬរំខានដល់ដំណើរការផលិតកម្ម អាជីវកម្មស្របច្បាប់របស់រោងចក្រសហគ្រាស និងមូលដ្ឋានអាជីវកម្មនានានោះឡើយ។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្លាប់មានប្រសាសន៍ថា ជនបរទេសដែលបានធ្វើបណ្ណការងារ និងសៀវភៅការងារ មានការកើនឡើងពី ៤០០នាក់ នៅឆ្នាំ២០១៣ ដល់ ២០៧.៨៨៦ នាក់ នៅឆ្នាំ២០១៩ ខណៈក្រោយវិបត្តិកូវីដ-១៩ មានប្រមាណ ១៨១.៦៥៣នាក់ គិតត្រឹមឆ្នាំ២០២២ ។ លោកបន្តថា ក្រសួងរកចំណូលចូលថវិកាជាតិតាមរយៈការផ្តល់បណ្ណការងារ និងសៀវភៅការងារប្រមាណ ២២,៨លានដុល្លារ ក្នុងនោះតាមរយៈការផ្តល់ទិដ្ឋាការការងារបានប្រមាណ ៦លានដុល្លារ និងតាមរយៈការផាកពិន័យបានប្រមាណ ៧៦ម៉ឺនដុល្លារអាមេរិក។ លោកថា៖ « យើងមានបញ្ហាប្រឈមមួយចំនួន ដូចជា កាស៊ីណូ ក្លឹបកំសាន្ត និងជនបរទេសមួយចំនួនបានលួចលាក់មិនប្រកាសពីចំនួនបុគ្គលិកបរទេស បន្តលាក់បាំងហត្ថពលកម្មបរទេស ការលួចឆ្លងដែនរបស់ជនបរទេសខុសច្បាប់តាមមេខ្យល់ សកម្មភាពល្បែងអនឡាញ ការប្រកាសផ្សព្វផ្សាយការងារបោកប្រាស់ និងចំណុចខ្សោយនៃកិច្ចសហការរវាងអាជ្ញាធរ និងស្ថាប័ន»។ លោកបន្ថែមថា រដ្ឋាភិបាលបានបង្កើតគណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យការងារហត្ថពលកម្មបរទេស ដើម្បីដឹកនាំពង្រឹងការងារនេះឱ្យមានប្រសិទ្ធភាពស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ជំរុញអធិការកិច្ចតាមសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្ត ដើម្បីគាំទ្រការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទជាដើម។

លោក អ៊ូ សុខឿន ប្រធានមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្វាយរៀង មានប្រសាសន៍ថា មានជនបរទេសមួយចំនួនទៀតមិនទាន់បានបំពេញសៀវភៅការងារ ឬប័ណ្ណការងារនៅឡើយទេ ។ ជាសរុប មានជនបរទេសប្រហែល ១.៧៧៧ នាក់បានដាក់ពាក្យស្នើសុំប័ណ្ណការងារនៅក្នុងខេត្ត៕ ប្រែសម្រួលដោយ៖ សុ ជាតា

## ឃាត់ខ្លួនយុវជនម្នាក់សង្ស័យចែកចាយសម្ភារៈអាសអាភាសខុសច្បាប់

https://www.kampucheathmey.com/security/453034 ថ្ងៃពុធ ២៥ មករា ២០២៣ដោយ Sokhom Khon

កម្លាំងនគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានឃាត់ខ្លួនយុវជនម្នាក់យកមកសាកសួរនៅនាយកដ្ឋាននគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃអគ្គស្នងការនគរបាលជាតិ ដោយសង្ស័យថា ជាអ្នកចែកចាយសម្ភារៈអាសអាភាសខុសច្បាប់ជាច្រើនប្រភេទ។ ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ នៅចំណុចផ្ទះលេខ១០៥អឺ១ហ្សិត ផ្លូវលេខ១២២ ភូមិ១៣ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ក្នុងប្រតិបត្តិការឃាត់ខ្លួនជនសង្ស័យខាងលើនេះ ដឹកនាំដោយលោកឧត្តមសេនីយ៍ទោ សារ សុបញ្ញា អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន សហការជាមួយកម្លាំងស្នងការនគរបាលរាជធានីភ្នំពេញ ដោយមានការសម្របសម្រួលដោយលោក ស៊ិត វណ្ណៈ ព្រះរាជអាជ្ញារងអម

សាលាដំបូងរាជធានីភ្នំពេញ។ ជនសង្ស័យត្រូវបានបញ្ជូនទៅសាកសួរបន្តនៅនាយកដ្ឋាននគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃអគ្គស្នងការនគរបាលជាតិ៕ អត្ថបទ៖ សុខុម

## ច្បាប់ JSOC សម្រាប់ទប់ស្កាត់ការប្រព្រឹត្តឧក្រិដ្ឋកម្មផ្លូវភេទ ឬអំពើហិង្សាឡើងវិញរបស់ប្រទេសថៃចូលជាធរមាន

https://www.information.gov.kh/articles/96201 ចេញផ្សាយ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២៣

សេចក្តីព្រាងច្បាប់ JSOC របស់ប្រទេសថៃដែលមានគោលបំណងទប់ស្កាត់ចំពោះបទល្មើសព្រហ្មទណ្ឌដែលត្រូវបានប្រព្រឹត្តឡើងដដែលៗទាក់ទងនឹងឧក្រិដ្ឋកម្មផ្លូវភេទ ឬអំពើហឹង្សា បានចូលជាធរមានហើយ។ បច្ចុប្បន្នមានអ្នកទោសចំនួន ១៧ ៨០៧នាក់ ដែលស្ថិតក្រោមការកំណត់នៃច្បាប់ថ្មីនេះ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ថៃ លោក ស៊ុមស័ក្តិ ទេពស៊ូធីន បានធ្វើសន្និសីទសារព័ត៌មានមួយ ដោយប្រកាសពីការអនុវត្តច្បាប់ JSOC នេះ។ លោកបាននិយាយថា ច្បាប់ថ្មីនេះមានសារៈសំខាន់ខ្លាំងណាស់ក្នុងការពង្រឹងសុវត្ថិភាពក្នុងសង្គម។ តាមរយៈការប្រើប្រាស់ការឃ្លាំមើល និងការត្រួតពិនិត្យទៅលើជនដែលបានប្រព្រឹត្តបទល្មើសផ្លូវភេទ ឬហឹង្សាពីមុនមក ច្បាប់នេះនឹងក្លាយទៅជាឧបករណ៍មួយសម្រាប់ទប់ស្កាត់ឧក្រិដ្ឋកម្ម។ លោក ស៊ុមស័ក្តិ បាននិយាយបន្ថែមថា សង្គមនឹងមានអារម្មណ៍គំរាមកំហែងពីជនមានគ្រោះថ្នាក់តិចជាងមុន។ មានវិធានការធំៗចំនួនពីរដែលត្រូវបានប្រើដោយច្បាប់នេះ ដែលរួមមាននូវការចាត់ចែងផ្នែកវេជ្ជសាស្ត្រដើម្បីព្យាបាលជនល្មើសឧក្រិដ្ឋកម្មខណៈដែលពួកគេស្ថិតនៅក្នុងពន្ធនាគារ និងការឃ្លាំមើលបុគ្គលទាំងនោះបន្ទាប់ពីពួកគេបានបញ្ចប់ការកាត់ទោសរបស់ពួកគេ។

ច្បាប់ JSOC គឺជាអក្សរកាត់សម្រាប់ពាក្យពេញ គឺមជ្ឈមណ្ឌលសង្កេតការណ៍សុវត្ថិភាពយុត្តិធម៌ ដែលត្រូវបានបង្កើតឡើងដោយក្រសួងយុត្តិធម៌ដើម្បីតាមដានអ្នកទោសមួយចំនួនបន្ទាប់ពីការដោះលែងរបស់ពួកគេ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានពន្យល់ថា អ្នកដែលស្ថិតនៅក្រោមការឃ្លាំមើលនៃច្បាប់នេះនឹងមានខ្សែដៃ EM ភ្ជាប់ជាមួយពួកគេសម្រាប់រយៈពេលអតិបរមា ១០ឆ្នាំ។ បុគ្គលទាំងនោះអាចត្រូវបានឃាត់ខ្លួនភ្លាមៗដោយមន្ត្រីនគរបាល ឬមន្ត្រីមួយចំនួនទៀត ប្រសិនបើពួកគេបង្ហាញអាកប្បកិរិយាមិនប្រក្រតីណាមួយ។ ការឃុំឃាំងអាចមានរយៈពេលមិនលើសពី ៤៨ម៉ោង។ តុលាការអាចត្រូវបានស្នើសុំឱ្យអនុម័តរយៈពេលឃុំខ្លួនជាបន្ទាន់ដែលមានរយៈពេលមិនលើសពី ៧ថ្ងៃបន្ថែមទៀត។ ការជាប់ពន្ធនាគារបន្ថែមរយៈពេល ៣ឆ្នាំអាចត្រូវបានពិចារណាសម្រាប់ជនល្មើសមួយចំនួនជំនួសឱ្យការដាក់ពួកគេឱ្យស្ថិតនៅក្រោមការឃ្លាំមើល៕

## ករណីជួញដូរមនុស្ស ៤៤៥ ករណីត្រូវបានស្រាវជ្រាវរកឃើញ

https://www.khmertimeskh.com/501225621// Khmer Times January 25, 2023

ចាប់តាំងពីកម្ពុជាចាប់ផ្តើមយុទ្ធនាការប្រឆាំងនឹងការជួញដូរមនុស្ស ពលកម្មដោយបង្ខំ និងអាជីវកម្មផ្លូវភេទរហូតដល់ខែមករា ឆ្នាំ២០២៣ អាជ្ញាធរមានសមត្ថកិច្ចទទួលបានបណ្តឹងចំនួន ៧០៧ និងបានស្រាវជ្រាវរកឃើញចំនួន ៤៤៥ ករណី។

បច្ចុប្បន្នភាពនេះត្រូវបានចែករំលែកដោយលោក ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃនៅពេលលោកអញ្ជើញជាអធិបតីក្នុងពិធីផ្សព្វផ្សាយការងារគ្រប់គ្រងហត្ថពលកម្មបរទេសនៅកម្ពុជា នៅទីក្រុងភ្នំពេញនាពេលថ្មីៗនេះ។ បើយោងតាមលោកឧបនាយករដ្ឋមន្ត្រី ស ខេង សំណុំរឿងទាំង ៤៤៥ ករណីនេះមានជនបរទេសចំនួន ១.០៤៥ នាក់ ក្នុងនោះ ជនសង្ស័យ ១២០ នាក់ មាន៤សញ្ជាតិ ត្រូវបានចាប់ខ្លួន ដើម្បីចាត់ការតាម

នីតិវិធីច្បាប់។ លោកបានបន្តថា ក្នុងចំណោមបណ្ដឹងចំនួន៧០៧ករណី មាន ២២៩ករណីត្រូវបានបិទ ដោយមូលហេតុរកមិនឃើញទីតាំង និងផ្ដល់ព័ត៌មានមិនច្បាស់លាស់។

លោកបានពន្យល់ថា ខណៈដែល អាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចកម្ពុជា កំពុងជាប់ដៃក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងដោះស្រាយវិបត្តិបណ្ដាលមកពីជំនន់ទឹកភ្លៀងក្នុងឆ្នាំ២០២២ ពួកឧក្រិដ្ឋជននៅក្រៅប្រទេសមួយចំនួន បានឆ្លៀតឱកាសប្រព្រឹត្តបទល្មើសបោកបញ្ឆោតតាមប្រព័ន្ធអនឡាញ ដើម្បីទាក់ទាញជនបរទេសឱ្យប្រព្រឹត្តបទល្មើស ល្បែងភ្នាល់អនឡាញខុសច្បាប់ និងទាក់ទាញបោកបញ្ឆោតពលករបរទេសឱ្យចូលមកធ្វើការខុសច្បាប់នៅកម្ពុជា។ លោកបានបញ្ជាក់ជាថ្មីពីការគាំទ្ររបស់លោកចំពោះការត្រួតពិនិត្យយ៉ាងហ្មត់ចត់លើពលករបរទេសនិងលើកទឹកចិត្តឱ្យអាជ្ញាធរនិងអ្នកពាក់ព័ន្ធធ្វើការរួមគ្នាដើម្បីដោះស្រាយបញ្ហា៕ *AKP-Lim Nary*

## ឯកអគ្គរាជទូតម៉ាឡេស៊ី ជួបពិភាក្សាការងារជាមួយឧត្តមសេនីយ៍ឯក ស ថេត សំដៅពង្រឹងកិច្ចសហប្រតិបត្តិការលើការងារទប់ស្កាត់ និងបង្ក្រាបមុខសញ្ញាជួញដូរមនុស្ស

https://freshnewsasia.com/index.php/en/internationalnews/275371-2023-01-25-08-18-35.html

2023-01-25 03:18pm

**(ភ្នំពេញ)៖** នៅព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣នេះ លោកឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរង និងជាស្នងការនគរបាលរាជធានីភ្នំពេញ បានអនុញ្ញាតឲ្យលោក ដាតុក អែលឌីន ហ៊ូសេនី ម៉ដ ហាហ្ស៊ីម (Datuk Eldeen Husaini Mohd Hashim) ឯកអគ្គរាជទូតប្រទេសម៉ាឡេស៊ី ប្រចាំនៅកម្ពុជា ដឹកនាំគណៈប្រតិភូ ចូលជួបសំដែងការគួរសម និងពិភាក្សាការងារ នៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

ជាកិច្ចចាប់ផ្ដើម លោកឧត្តមសេនីយ៍ឯក ស ថេត បានថ្លែងនូវការស្វាគមន៍យ៉ាងកក់ក្ដៅចំពោះ វត្តមានរបស់ឯកអគ្គរាជទូតម៉ាឡេស៊ី និងគណៈប្រតិភូដែលបានចំណាយពេលវេលាសម្រាប់ការរៀបចំនូវជំនួបនេះ។ ក្នុងនោះលោកឯកអគ្គរាជទូត បានថ្លែងអំណរគុណចំពោះ លោកឧត្តមសេនីយ៍ឯក ស ថេត ដែលបានចំណាយពេលវេលាក្នុងការទទួលជួបទ្វេភាគីនេះ និងបានណែនាំសមាសភាព លោក ដាតូ ស្រ៊ី អែបចាលីល ប៊ីនហាសាន់ (Dato Sri Abd Jalil bin Hassan) ប្រធាននាយកដ្ឋានស៊ើបអង្កេតបទល្មើសឧក្រិដ្ឋ នៃនគរបាលភូមិន្ទម៉ាស៊ីផងដែរ។

កិច្ចប្រជុំនេះផ្ដោតសំខាន់ទៅលើការចូលរួមសហការគ្នារវាងសមត្ថកិច្ចនគរបាលកម្ពុជា និងនគរបាលភូមិន្ទម៉ាឡេស៊ី ជាពិសេសស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងស្ថានទូតម៉ាឡេស៊ីប្រចាំកម្ពុជា ក៏ដូចជានាយកដ្ឋានសេ៊ើបអង្កេតបទល្មេ៊ើសឧក្រិដ្ឋ សហការគ្នាដើម្បីចូលរួមបង្កា ទប់ស្កាត់ និងស្រាវជ្រាវបង្ក្រាបមុខសញ្ញាជួញដូរមនុស្ស ក៏ដូចជាការបង្ខាំងមនុស្សបង្ខំឲ្យធ្វើការដោយខុសច្បាប់។ ភាគីទាំងពីរបានប្រគល់វត្ថុអនុស្សាវរីយ៍ទៅវិញទៅមក ជាពិសេសសម្ដែងនូវការប្ដេជ្ញាចិត្តបន្តជំរុញឲ្យកិច្ចសហប្រតិបត្តិការនេះ កាន់តែល្អប្រសើរឡើងថែមទៀត៕

# ថ្ងៃទី២៧ ខែ មករា ឆ្នាំ២០២៣

## មន្ត្រីអន្តោប្រវេសន៍ហ្វីលីពីនស្ថិតក្រោមការស៊ើបអង្កេតលើបទចោទប្រកាន់ពាក់ព័ន្ធនឹងការជួញដូរមនុស្សមកកម្ពុជា ដោយមនុស្សពីរនាក់ត្រូវបានចាប់ខ្លួន

https://www.khmertimeskh.com/501226772// Khmer Times January 26, 2023

លោក Norman Tansingco នាយការិយាល័យស្នងការអន្តោប្រវេសន៍ហ្វីលីពីន បានផ្លាស់ប្តូរដំណែងមន្ត្រីអន្តោប្រវេសន៍ ពីររូប បន្ទាប់ពីមានរបាយការណ៍អំពីការជាប់ពាក់ព័ន្ធក្នុងសកម្មភាពជួញដូរនៅអាកាសយានដ្ឋានអន្តរជាតិ Clark (CIA) និងអាកាសយានដ្ឋានអន្តរជាតិ Ninoy Aquino (NAIA) ។ Miles បានមានប្រសាសន៍ថា គាត់បានចាកចេញពីប្រទេសតាមរយៈអាកាសយានដ្ឋានអន្តរជាតិ Ninoy Aquino ខណៈដែលប្រជាជនហ្វីលីពីនមួយចំនួនទៀត ដែលគាត់ស្គាល់នៅក្នុងប្រទេសកម្ពុជាបានចាកចេញតាមរយៈអាកាសយានដ្ឋានអន្តរជាតិ Clark។ លោក Tansingco បានមានប្រសាសន៍ថា «យើងបានទទួលព័ត៌មានថា អ្នកទាំងពីរមានទំនាក់ទំនងទៅនឹងក្រុមជួញដូរ យើងកំពុងចាប់ផ្តើមការស៊ើបអង្កេត ដើម្បីផ្ទៀងផ្ទាត់ព័ត៌មាននេះ ហើយប្រសិនបើពិតជាមានភស្តុតាងគ្រប់គ្រាន់ យើងនឹងរៀបចំបញ្ជូនសំណុំរឿងទៅក្រសួងយុត្តិធម៌" ។

ជនរងគ្រោះដែលត្រូវបានជួយសង្គ្រោះ ដែលមានឈ្មោះ Miles បានមានប្រសាសន៍អំពី "ការអមម" ពីមន្ត្រីអន្តោប្រវេសន៍ហ្វីលីពីន ដែលអនុញ្ញាតឱ្យពួកគេមានភាពងាយស្រួលក្នុងការធ្វើដំណើរទៅកាន់គោលដៅការងារដែលគួរឱ្យសង្ស័យ។ ការិយាល័យអន្តោប្រវេសន៍ បានមានប្រសាសន៍ថា ជាវិធានការបង្ការ អ្នកទាំងពីរនឹងត្រូវបានចាត់តាំងជាបណ្តោះអាសន្ន ឱ្យទៅបំពេញការងារនៅការិយាល័យខាងក្រោយ ដោយរង់ចាំការស៊ើបអង្កេត។

អ្នកនាំពាក្យរបស់ការិយាល័យអន្តោប្រវេសន៍ លោក Dana Sandoval បានមានប្រសាសន៍ថា "ការស៊ើបអង្កេតកំពុងបន្ត ហើយយើងក៏នឹងពិនិត្យមើលតួនាទីរបស់អ្នកជ្រើសរើសបុគ្គលិក នៅក្នុងសកម្មភាពជួញដូរមនុស្សទាំងនេះផងដែរ។ ប្រសិនបើមានឈ្មោះអ្នកជ្រើសរើសបុគ្គលិកដែលត្រូវបានរកឃើញពីការស៊ើបអង្កេតនោះ យើងនឹងបញ្ជូនវាទៅទីភ្នាក់ងារស៊ើបអង្កេត ដែលស្ថិតក្រោមក្រុមប្រឹក្សាអន្តរទីភ្នាក់ងារប្រឆាំងនឹងការជួញដូរ"។

ឧបការីយុត្តិធម៌ លោក Jesus Crispin Remula បានគាំទ្រការស៊ើបអង្កេតរបស់ការិយាល័យអន្តោប្រវេសន៍។ លោកបានប្រាប់អ្នកយកព័ត៌មានថា៖ «កិច្ចការនេះ កំពុងស្ថិតក្រោមការស៊ើបអង្កេត ដោយឈ្មោះមួយចំនួនត្រូវបានរកឃើញ»។ លោក Remulla មានប្រសាសន៍ថា "ការស៊ើបអង្កេតរកការពិតអំពីការជួញដូរមនុស្សមកកម្ពុជានេះ កំពុងដំណើរការ។ យើងមិនបានបញ្ឈប់ការព្យាយាមស្វែងរកត្រឹមនេះទេ ហើយយើងកំពុងស្វែងរកឫសគល់នៃការពិត។ យើងត្រូវតែដឹងថាវាចូលទៅជ្រៅកម្រិតណា»។

ព្រឹទ្ធសមាជិក Hontiveros បានមានប្រសាសន៍ថា ជនជាតិហ្វីលីពីនដែលស្ថិតនៅក្នុងក្រុមរបស់ Miles ត្រូវបានជួយសង្គ្រោះដោយនគរបាលកម្ពុជាកាលពីថ្ងៃចន្ទ ទី១៦ ខែមករា ដោយសារមានអន្តរាគមន៍ពីស្ថានទូតហ្វីលីពីនៅក្នុងទីក្រុងភ្នំពេញ។

ទោះយ៉ាងណាក៏ដោយ គិតត្រឹមល្ងាចថ្ងៃអង្គារ ទី១៧ ខែមករា "ពួកគេកំពុងត្រូវបានឃុំខ្លួននៅប៉ុស្តិ៍នគរបាលដោយគ្មានគ្រែ និងសម្ភារៈមូលដ្ឋាន"។ លោកស្រី Hontiveros បានមានប្រសាសន៍ថាគាត់បានសរសេរលិខិតទៅក្រសួងការបរទេស (DFA) ដើម្បីជួយសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍ឱ្យបានយ៉ាងឆាប់រហ័ស។ ក្រសួងការបរទេស កាលពីថ្ងៃព្រហស្បតិ៍បានមានប្រសាសន៍ថា ខ្លួនកំពុងធ្វើការលើការធ្វើមាតុភូមិនិវត្តន៍របស់ពលករហ្វីលីពីននៅបរទេស ដែលបានរងគ្រោះដោយការជួញដូរមនុស្សនៅអាស៊ីអាគ្នេយ៍៕ *Rappler.com*

# សមាជិកព្រឹទ្ធសភាហ្វីលីពីនមើលឃើញពីវិបត្តិដែលកំពុងកើតមាននៅក្នុងប្រតិបត្តិការបោកប្រាស់គ្រីបតូក្នុងប្រទេសកម្ពុជា

https://www.khmertimeskh.com/501226829/-2/ Khmer Times January 26, 2023

សមាជិកព្រឹទ្ធសភាហ្វីលីពីននៅថ្ងៃពុធទី២៥ ខែមករាបាននិយាយថាពួកគេមើលឃើញពីវិបត្តិប្រសិនបើនៅមានជនជាតិហ្វីលីពីនត្រូវបានបោកប្រាស់អោយធ្វើការខុសច្បាប់ក្នុងប្រតិបត្តិការបោកប្រាស់គ្រីបតូ។

សមាជិកព្រឹទ្ធសភា Risa Hontiveros ប្រធានគណៈកម្មាធិការព្រឹទ្ធសភាស្តីពីស្ត្រី កុមារ ទំនាក់ទំនងគ្រួសារ និងសមភាពយេនឌ័រ បានលើកឡើងពីបញ្ហានេះ ក្នុងអំឡុងពេលបន្តការស៊ើបអង្កេតរបស់ខ្លួនអំពីចំនួនប្រជាជនហ្វីលីពីនដែលត្រូវបានគេបោកប្រាស់ និងជួយសង្គ្រោះពីក្រុមជនពាលដែលកំពុងប្រើប្រាស់ពួកគេក្នុងប្រតិបត្តិការបោកប្រាស់នៅកម្ពុជា និងកន្លែងផ្សេងទៀត។ "នេះជាវិបត្តិមនុស្សធម៌ដែលកំពុងកើតឡើងបង្កដោយក្រុមឧក្រិដ្ឋជនទាំងនោះដែលប្រើហិង្សាចាប់ចង និងធក់ដោយចរន្តអគ្គិសនី។ «យើងត្រូវបន្តប្រឹងប្រែងរហូតទាល់តែអ្នកដែលឃុបឃិតជាមួយក្រុមជនពាលទាំងនេះត្រូវបានចាប់ដាក់គុក។ ចំណាត់ការយឺតនឹងនាំឱ្យប្រជាជនហ្វីលីពីនច្រើនទៀតត្រូវបានធ្លាក់ចូលទៅក្នុងអន្ទាក់នៃក្រុមជនពាល»។ ក្នុងអំឡុងពេលសវនាការ សាក្សីម្នាក់បានបង្ហាញថា បុគ្គលិកនៃការិយាល័យអន្តោប្រវេសន៍ (BI) ដែលមានមូលដ្ឋាននៅទីក្រុង Clark, Pampanga បានសម្របសម្រួលការធ្វើដំណើររបស់ជនរងគ្រោះទៅក្រៅប្រទេស។

ព្រឹទ្ធសមាជិក Raffy Tulfo និង Hontiveros បានសាកសួរភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ រួមទាំងមន្ត្រីអាកាសយានដ្ឋាន ថាតើជនរងគ្រោះទាំងនេះអាចចេញពីប្រទេសដោយប្រើឯកសារក្លែងក្លាយយ៉ាងដូចម្តេច។ ក្នុងអំឡុងពេលសវនាការ ជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះដែលត្រូវបានជួញដូរមកកម្ពុជា ដែលត្រូវបានជួយសង្គ្រោះដោយអាជ្ញាធរបានផ្តល់សក្ខីកម្មថា ថៅកែចិនរបស់គាត់បានបង្ខិតបង្ខំគាត់ឱ្យបោកប្រាស់ជនជាតិហ្វីលីពីនផ្សេងទៀតឱ្យធ្វើការក្នុងប្រតិបត្តិការគ្រីបតូខុសច្បាប់។

យោងតាម Ron ប្រធានផ្នែកជ្រើសរើសរបស់ពួកគេគឺ Rachel Almendra Luna មានទំនាក់ទំនងជាមួយមន្ត្រីការិយាល័យអន្តោប្រវេសន៍ (BI) នៅអាកាសយានដ្ឋានអន្តរជាតិ Clark ។ សាក្សីបាននិយាយនៅក្នុងសវនាការថា "Rachel បាននិយាយយ៉ាងច្បាស់ថាពួកគេកំពុងទាក់ទងទៅមន្ត្រីអន្តោប្រវេសន៍ដើម្បីឱ្យជនជាតិហ្វីលីពីនអាចចេញពីប្រទេសបាន ប៉ុន្តែនាងមិនបានប្រាប់ឈ្មោះនៃមន្ត្រីអន្តោប្រវេសន៍នោះទេ" ។ Ron ក៏បាននិយាយផងដែរថា ពួកគេធ្វើការជ្រើសរើសបុគ្គលិករបស់ពួកគេនៅលើFacebook ដោយការបង្ហោះការផ្សាយពាណិជ្ជកម្ម អោយប្រជាជនហ្វីលីពីនឱ្យដាក់ពាក្យសុំមុខតំណែងភ្នាក់ងារបម្រើអតិថិជននៅកម្ពុជា ជាមួយនឹងប្រាក់បៀវត្សរ៍យ៉ាងតិច ៦០០ ដុល្លារក្នុងមួយខែ។ ជាមួយនឹងព័ត៌មាននេះ Hontiveros បាននិយាយថា Facebook "ចាំបាច់ត្រូវដោះស្រាយចំពោះបញ្ហាជួញដូរទាំងនេះ ដែលប្រព្រឹត្តនៅលើបណ្តាញFacebookរបស់ពួកគេ"។ Hontiveros បានបន្តថា "ក្រុមហ៊ុនត្រូវតាមដាននូវរាល់ការបង្ហោះព័ត៌មានទាំងនេះ។ ពួកគេគួរតែលុប ឬបិទគណនីទាំងនេះ ដូច្នេះពួកគេមិនអាចបោកប្រាស់ជនជាតិហ្វីលីពីនបន្ថែមទៀតបានទេ "។

នៅក្នុងសវនាការផងដែរ Ron បានបង្ហើបថា ថៅកែរបស់គាត់បានឱ្យគាត់រៀបចំឯកសាររដ្ឋបាលការងារនៅក្រៅប្រទេសហ្វីលីពីន (POEA) ដោយប្រើឈ្មោះក្រុមហ៊ុនមួយផ្សេងទៀត លិខិតអញ្ជើញក្លែងក្លាយ និងឯកសារផ្សេងទៀត។ គាត់ត្រូវបានផ្តល់វិញ្ញាបនបត្រការងារនៅបរទេស ទោះបីជាគាត់បានដាក់ឯកសារក្លែងក្លាយក៏ដោយ។ Hontiveros បាននិយាយថា វាជារឿងចាំបាច់សម្រាប់អាជ្ញាធរហ្វីលីពីនធ្វើការយ៉ាងជិតស្និទ្ធជាមួយសមភាគីរបស់ពួកគេនៅក្នុងប្រទេសផ្សេងទៀត ដើម្បីលុបបំបាត់ការជួញដូរមនុស្ស។ "Facebook, Telegram, WhatsApp, Linked In, កម្មវិធីណាត់ជួប និងវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម និងគេហទំព័រផ្ញើសារក៏មានចំណែកពាក់ព័ន្ធនៅ

ក្នុងបញ្ហានេះផងដែរ។ នេះគឺជាកន្លែងដែលការជ្រើសរើសបុគ្គលិកក្លែងក្លាយកើតឡើង ហើយការក្លែងបន្លំប្រឆាំងនឹងជនបរទេសក៏កើតឡើងនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមផងដែរ។ គេហទំព័រទាំងនេះបានបង្កអោយមានភាពងាយស្រួលសម្រាប់ក្រុមជួញដូរមនុស្សលោកស្រីបានចង្អុលបង្ហាញថា ដូច្នេះ នេះមិនមែនត្រឹមតែជាបញ្ហារបស់ហ្វីលីពីន ឬប្រទេសអាស៊ានជិតខាងរបស់យើងទេ។ ការជួញដូរមនុស្សគឺជាបញ្ហាអន្តរជាតិ។ វាដល់ពេលដែលយើងត្រូវដោះស្រាយវាអោយបានទូលំទូលាយ" ។

ចំណែក Tulfo បានអំពាវនាវឱ្យភ្នាក់ងារអនុវត្តច្បាប់កំណត់អត្តសញ្ញាណ និងចាប់ខ្លួនក្រុមជួញដូរមនុស្សឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដោយកត់សម្គាល់ពីរបៀបដែលក្រុមទាំងនេះកំពុងប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ Tulfo បានសង្កត់ធ្ងន់ថា "ការជួញដូរមនុស្សរំលោភលើសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះ។ ដូច្នេះ វាគួរតែប្រៀបដូចទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ។ Tulfo ក៏បានលើកទឹកចិត្តសមាជិកនៃក្រុមប្រឹក្សាអន្តរទីភ្នាក់ងារប្រឆាំងនឹងការជួញដូរ (IACAT) ឱ្យរួបរួមគ្នាប្រឆាំងនឹងការជួញដូរមនុស្ស និងធានាថាអ្នកជួញដូរមនុស្សត្រូវបានកាត់ទោស និងផ្តន្ទាទោស ដើម្បីបញ្ចប់ការជួញដូរមនុស្សគ្រប់ទម្រង់នៅក្នុងប្រទេស។ *Manila Bulletin*

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ១ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិជប៉ុន ១៩នាក់

http://freshnewsasia.com/index.php/en/localnews/275521-2023-01-26-07-26-18.html 2023-01-26 02:26pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២៤ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិជប៉ុន ចំនួន ១៩នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៧១៦ករណី មានមនុស្ស ១,៧៥១នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៥៣សំណើ និងបិទសំណុំរឿង ២៣៥សំណើ (រកឃើញមនុស្ស ១,០៦២នាក់, ឃាត់ខ្លួនជនសង្ស័យ ១២២នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ២៨ករណី៕

## សមត្ថកិច្ចស្រាវជ្រាវតាមបណ្តឹងចូលប្រព័ន្ធ Hotline មួយករណីទៀត រកឃើញជនជាតិជប៉ុន ១៩នាក់ នៅខេត្តព្រះសីហនុ

https://freshnewsasia.com/index.php/en/localnews/275543-2023-01-26-09-33-01.html 2023-01-26 04:33pm

**(ព្រះសីហនុ)៖** កម្លាំងស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានចុះត្រួតពិនិត្យទីតាំងសណ្ឋាគារ ម៉ារី ប៊ិច (MARY BEACH Hotel & Resort) នៅក្រុមទី៨ ភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ តាមរយៈបណ្តឹងតាមរយៈ Hotline មួយករណីទៀត ដោយរកឃើញជនជាតិជប៉ុន ចំនួន១៩នាក់។ នេះជាការបញ្ជាក់របស់ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ។

ប្រតិបត្តិការនេះបានធ្វើឡើងបន្ទាប់ពីមានបណ្តឹងចូលប្រព័ន្ធ Hotline ជនបរទេស (លេខ ៨៩). ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ២០២៣ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្តីពីករណីសង្ស័យមានការបង្ខាំង ជនជាតិជប៉ុន ចំនួន ២០រូប (គ្មានសារតា) នៅក្នុងទីតាំងមួយកន្លែងក្នុងខេត្តព្រះសីហនុ។ ភ្លាមៗបន្ទាប់ពីបានឃើញបណ្តឹងតាមរយៈ Hotline ជនបរទេសខាងលើ ស្តីពីករណីសង្ស័យមានការបង្ខាំង កម្លាំងនគរបាលជំនាញផែនការងារអន្តោប្រវេសន៍ នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ សហការជាមួយកម្លាំងចម្រុះ និងគណៈបញ្ជាការឯកភាពក្រុងព្រះសីហនុ ដឹកនាំដោយ លោក នង ឌីណាក់ អភិបាលរងក្រុង និងដោយមានការសម្របសម្រួលនីតិវិធី ពីលោក ពេញ ពិសិដ្ឋ ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ បានចុះមកដល់ទីតាំងសណ្ឋាគារ ម៉ារី ប៊ិច (MARY BEACH Hotel & Resort) ដែលមានទីតាំងស្ថិតនៅក្រុមទី៨ ភូមិ៦ សង្កាត់លេខ៤ ក្រុង-ខេត្តព្រះសីហនុ។ **តាមរយៈរបាយការណ៍ដដែលបានបញ្ជាក់ថា ក្នុងប្រតិបត្តិការនេះកម្លាំងនគរបាលបានធ្វើការត្រួតពិនិត្យនៅតាមបន្ទប់ដូចខាងក្រោម៖**

*បន្ទប់លេខ:B315 មានជនជាតិជប៉ុនចំនួន ០៩នាក់ (ប្រុស)

*បន្ទប់លេខ:B313 មានជនជាតិជប៉ុនចំនួន ០៣នាក់ (ប្រុស)

*បន្ទប់លេខ:B311 មានជនជាតិជប៉ុនចំនួន ០២នាក់ (ប្រុស)

*បន្ទប់លេខ:B211 មានជនជាតិជប៉ុនចំនួន ០២នាក់ (ប្រុស)

*បន្ទប់លេខ:B212 មានជនជាតិជប៉ុនចំនួន ០៣នាក់ (ប្រុស)

តាមរយៈរបាយការណ៍របស់សមត្ថកិច្ច បានគូសបញ្ជាក់ថា ចំពោះករណីនេះពុំមានការបង្ខាំង និងធ្វើទារុណកម្មអ្វីឡើយ។ ក្នុងករណីបណ្តឹងតាមរយៈ Hotline ជនបរទេសខាងលើ កម្លាំងនគរបាលបានអនុញ្ញាតឱ្យជនជាតិជប៉ុនចំនួន ១៩នាក់ ខាងលើស្នាក់នៅទីតាំងសណ្ឋាគារ MARY BEACH ដដែលដោយមានកម្លាំងសមត្ថកិច្ចឃាមការពាររង់ចាំបន្តនីតិវិធី៕

## ថៃរឹតបន្តឹងការធ្វើការខុសច្បាប់របស់ជនបរទេស

https://kbn.news/archives/286509 January 26, 2023

ប្រទេសថៃ ៖ ក្រសួងការងារថៃបានដាស់តឿនដល់និយោជកទាំងឡាយ ដែលជួលកម្មករបរទេសមកធ្វើការដោយគ្មានប័ណ្ណអនុញ្ញាត នឹងត្រូវពិន័យជាប្រាក់ចាប់ពី១ម៉ឺនបាត ដល់១០ម៉ឺនបាតសម្រាប់កម្មករបរទេសម្នាក់ ។ ក្នុងករណីធ្វើខុសម្តងទៀត នឹងជាប់គុកមិនលើសពី១ឆ្នាំ ហើយពិន័យចាប់ពី៥ម៉ឺនបាត ដល់២០ម៉ឺនបាត ឬទាំងជាប់គុក ទាំងពិន័យ ។ កម្មករបរទេសដែលលួចមកធ្វើការខុសច្បាប់នៅប្រទេសថៃ គឺត្រូវពិន័យចាប់ពី៥ពាន់បាតដល់៥ម៉ឺនបាត និងត្រូវបញ្ជូនត្រឡប់ទៅប្រទេសកំណើតវិញ ។

លោក សុធាត ឃុំគ្លីន រដ្ឋមន្ត្រីក្រសួងការងារបង្ហាញថា លោក ប្រាយុទ្ធ ចាន់អូចា នាយករដ្ឋមន្ត្រីថៃ បានជំរុញឱ្យក្រសួងការងារគ្រប់គ្រងលើការងាររបស់កម្មករបរទេស ក្រោយពីការរាតត្បាតនៃជំងឺកូវីដ-១៩ បានធូរស្បើយ ។ កម្លាំងពលកម្មជាកត្តាមិនអាចខ្វះបានក្នុងការងើបឡើងវិញនៃសេដ្ឋកិច្ច ហេតុនេះ ក្រសួងការងារបានកែតម្រូវច្បាប់ ដោយផ្តោតលើនិយោជក គ្រឹះស្ថាននានា និងកម្មករបរទេស ត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី ដែលអនុញ្ញាតឱ្យកម្មករបរទេសស្នាក់នៅ និងធ្វើការជាបណ្តោះអាសន្ន ។

បច្ចុប្បន្ន គេប្រទះឃើញកម្មករបរទេសលួចចូលមកធ្វើការជាបន្តបន្ទាប់ ហេតុនេះ ក្រសួងការងារសហការជាមួយផ្នែកសន្តិសុខដូចជា ទាហាន និងប៉ូលិស បានរៀបចំក្រុមការងារពិសេសចុះត្រួតពិនិត្យ បង្ក្រាប និងចាប់ខ្លួនកម្មករបរទេស និយោជក និងអ្នកពាក់ព័ន្ធនឹងការនាំចូលកម្មករបរទេសខុសច្បាប់មកធ្វើការ ដើម្បីការពារមិនឱ្យធ្វើខុសទៀត និងដាក់ទោសឱ្យចងចាំ ។

លោក សុធាត ឈុំគ្លីន និយាយថា ៖ «សូមដាស់តឿន និងសហការជាមួយនិយោជក ម្ចាស់គ្រឹះស្ថាន មិនត្រូវជួលកម្មករបរទេសខុសច្បាប់ទេ បើចង់ជួលពួកគេ គឺនិយោជកត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ។ បើនិយោជក និងកម្មករបរទេសបានអនុវត្តតាមលក្ខខណ្ឌ និងច្បាប់ត្រឹមត្រូវ ពួកគេនឹងទទួលបានអត្ថប្រយោជន៍ពីសន្តិសុខសង្គម និងទទួលបានការការពារសិទ្ធិតាមច្បាប់ការងារ មិនខុសគ្នាពីពលរដ្ឋថៃ ព្រោះយើងមើលថៃកម្មករបរទេសនិងថៃ ស្មើភាពគ្នាតាមសិទ្ធិមនុស្ស» ។

ចំណែកលោក ផៃរ៉ូច ឈោតិសៈធៀន អគ្គនាយកដ្ឋានការងារ ថ្លែងថា បើអ្នកណាម្នាក់ប្រទះឃើញ ឬសង្ស័យថា មានជនបរទេសលួចចូលមកធ្វើការខុសច្បាប់ក្នុងប្រទេសថៃ គឺអាចផ្តល់ដំណឹងទៅកាន់ការិយាល័យការងារគ្រប់ខេត្ត ការិយាល័យការងារក្រុងបាងកក ឬរាយការណ៍ទៅក្រសួងការងារ ៕

## រដ្ឋបាលខេត្តព្រះសីហនុ និងឯកអគ្គរដ្ឋទូតម៉ាឡេស៊ី ជួបពិភាក្សាគ្នាពីករណីជួញដូរមនុស្ស

http://freshnewsasia.com/index.php/en/localnews/275592-2023-01-26-15-20-01.html 2023-01-26 10:20pm

**(ព្រះសីហនុ)៖** លោក ម៉ាង ស៊ីណេត អភិបាលរងខេត្តព្រះសីហនុ នៅព្រឹកថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣ នេះ បានអនុញ្ញាតឱ្យលោក ដុតុ អិលដេន ហ៊ូសៃនី ម៉ានហាស៊ុន Datuk Eldeen Husaini Mohd Hashim ឯកអគ្គរដ្ឋទូតនៃស្ថានទូតម៉ាឡេស៊ីប្រចាំកម្ពុជា និងលោក ដាតុស្រី អាប់ដុល ចាលីល ប៊ីនហាស់សាន់ (Data's Sri Abb Jalil Bin Hassan) ស្នងការនគរបាលនៃប្រទេសម៉ាឡេស៊ី ចូលជួបពិភាក្សាការងារ ស្តីពីការជួយជូរមនុស្ស នៅសាលាខេត្តព្រះសីហនុ។

លើកឡើងនាឱកាសនោះលោកម៉ាង ស៊ីណេត បានឱ្យដឹងថា ប្រជាពលរដ្ឋម៉ាឡេស៊ីមកធ្វើការស្នាក់នៅខេត្តព្រះសីហនុ គិតត្រឹមថ្ងៃទី២៣ ខែមករា ២០២៣ ស្នាក់នៅរយៈពេលវែងមានចំនួន ៤៦៨នាក់ ស្រី៩៥នាក់ បំរើការងារនៅកាស៊ីណូ សណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួល ខុនដូរ សហគ្រាស រោងចក្រ គ្រឹះស្ថានសិក្សា សហគមន៍ និងប្រកបអាជីវកម្មជាដើម។ ទាក់ទងនឹងការទទួលពាក្យបណ្តឹងតាមរយផេកហ្វេសបុកផ្លូវការរបស់សម្តេចក្រឡាហោម និង Hotline១១៧ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ក៏ដូចតាមរយៈពាក្យបណ្តឹងនានា ចូលមករដ្ឋបាលខេត្ត ជាលទ្ធផលប្រតិបត្តិការចាប់ពីថ្ងៃទី៣ ខែតុលា ២០២២ ដល់ថ្ងៃទី១៧ ខែមករា ២០២៣ ខេត្តបានទទួលពាក្យបណ្តឹង ២៣ តាមរយៈហ្វេសបុកផេកសម្តេចក្រឡាហោម ២១បណ្តឹង តាមរយៈបណ្តឹង Hotline ១១៧ របស់អគ្គស្នងការដ្ឋាននគរបាលជាតិចំនួន ៦បណ្តឹង តាមរយ:Hotline ជនបរទេស ១បណ្តឹង ក្នុងនោះក៏មានបណ្តឹងមកគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តចំនួន៣ករណីផងដែរ។

លោក ដាតុស្រី អាប់ដុលចលីល ប៊ីនហាស់សាន់ បានឱ្យដឹងដែរថា ការជួញដូរមនុស្សជាក្តីកង្វល់ និងធ្វើឱ្យមានការប៉ះពាល់ដល់ពិភពលោក ប្រទេសម៉ាឡេស៊ីបានខិតខំប្រឹងប្រែងប្រឆាំងនឹងការជួញដូរមនុស្ស ដោយផ្អែកនឹងច្បាប់ យើងទទួលបានដំណឹងពីការជួញដូរមនុស្សពីម៉ាឡេស៊ី តាមហេតុផលជនរងគ្រោះបញ្ជាក់ថា មានការជួញដូរដោយស្នើសុំការអន្តរាគមន៍ជួយសង្គ្រោះនៅក្រៅប្រទេស ក្នុងនោះក៏មាននៅកម្ពុជាផងដែរ ព្រោះការជួញដូរមនុស្សមិនមែនជាការទទួលខុសត្រូវរបស់ភ្នាក់ងារណាមួយទេ គឺជាការទទួលខុសត្រូវរបស់យើងទាំងអស់គ្នា ព្រមទាំងមានការសម្របសម្រួលសហការគ្នារវាងភាគីនៃប្រទេសនីមួយៗផងដែរ។

លោក ដាតុស្រី អាប់ដុលចលីល ប៊ីនហាស់សាន់ បានបន្ថែមថា ជាកិត្តិយសណាស់ដែលរដ្ឋបាលខេត្តព្រះសីហនុបានទទួលស្វាគមន៍នាពេលនេះ ក្នុងគោលបំណងស្វែងរកវិធីសាស្ត្រកំណត់ទីតាំងជួយសង្គ្រោះជនរងគ្រោះពីការស្នើសុំកិច្ចសហការពីប្រទេសពាក់ព័ន្ធក្នុងការជួយសង្គ្រោះជនរងគ្រោះ ដើម្បីឈានទៅចាប់ខ្លួនជនឆបោក ហើយម៉ាឡេស៊ីក៏ចង់បានព័ត៌មាន និងបទពិសោធន៍ ដើម្បីចែករំលែកផ្សព្វផ្សាយដល់ប្រជាជនម៉ាឡេស៊ីផងដែរ។

សង្ឃឹមថារដ្ឋាភិបាលម៉ាឡេស៊ី និងរដ្ឋាភិបាលកម្ពុជា តាមកិច្ចពិភាក្សានេះនឹងពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការទៅវិញទៅមកប្រឆាំងនឹងការជួញដូរមនុស្សប្រកបដោយប្រសិទ្ធិភាពនាពេលខាងមុខ។

លោក ដុត អិលដេន ហ៊ូសេនី ម៉ានហាស៊ុន ក៏បានថ្លែងអំណរគុណរដ្ឋបាលខេត្តព្រះ សីហនុ ដែលបានជួយសម្របសម្រួលប្រជាពលរដ្ឋម៉ាឡេស៊ី មកធ្វើការនៅក្នុងខេត្តព្រះសីហនុនាពេលកន្លងមក ទន្ទឹមនោះក៏ចង់ឃើញជនជាតិម៉ាឡេស៊ីមកធ្វើការវិនិយោគ និងទេសចរណ៍នៅខេត្តព្រះសីហនុ។ លោកសន្យាថានៅពេលខាងមុខនឹងនាំអ្នកវិនិយោគ និងអ្នកទេសចេណ៍ចូលជួបពិភាក្សាការងារ ដើម្បីបង្កើនភាពស្និតស្នាលកាន់តែស៊ីជម្រៅ ឈ្វេងយល់សិក្សាលើគម្រោងវិនិយោគនៅខេត្តព្រះសីហនុ និងនាំមកនូវភ្ញៀវទេសចរមកកាន់ខេត្តព្រះសីហនុផងដែរ៕

## កូរ៉េខាងត្បូង
## គ្រោងនាំយកពលករចំណាកស្រុកជាង ១សែននាក់ទៅបម្រើការងារនៅឆ្នាំនេះ

http://freshnewsasia.com/index.php/en/business/275598-2023-01-26-16-04-51.html 2023-01-26 11:04pm

**(ប៉ូជិន)៖** ប្រទេសកូរ៉េខាងត្បូងមានគម្រោងនាំយកពលករចំណាកស្រុកប្រហែល ១១០ ០០០ នាក់នៅឆ្នាំនេះ ដើម្បីធ្វើការនៅតាមកសិដ្ឋាន និងរោងចក្ររបស់ខ្លួន។ នេះបើយោងតាមការចេញផ្សាយរបស់កាសែត Channel News Asia។ កាសែត Channel News Asia បានរាយការណ៍ថា បច្ចុប្បន្នវិស័យទាំងនេះកំពុងប្រឈមមុខនឹងកង្វះកម្លាំងពលកម្ម ដោយសារយុវជនកូរ៉េខាងត្បូងជាច្រើនមិនចង់ធ្វើការងារដែលពួកគេចាត់ទុកថាកខ្វក់ និងគ្រោះថ្នាក់។

នៅក្នុងការស្ទង់មតិថ្មីមួយ ដែលធ្វើឡើងដោយសហព័ន្ធសហគ្រាសកូរ៉េ ដែលជាក្រុមបញ្ចុះបញ្ចូលអាជីវកម្មធំមួយនៅកូរ៉េខាងត្បូង ប្រហែល ៤០ភាគរយនៃសហគ្រាសធុនតូច និងមធ្យម (SMEs) ដែលបានស្ទង់មតិបាននិយាយថា ពួកគេមិនគិតថារដ្ឋាភិបាលបានក្តោបបានពេញលេញនូវបញ្ហាទាំងអស់នេះទេ។ សហគ្រាសទាំងនោះបានឱ្យដឹងថា ពលករបរទេសថ្មីចំនួន១១០០០០នាក់ ដែលនឹងត្រូវនាំទៅធ្វើការក្នុងប្រទេសកូរ៉េខាងត្បូងនៅឆ្នាំនេះនៅ មិនទាន់គ្រប់គ្រាន់ដើម្បីបំពេញសេចក្តីត្រូវការកម្លាំងពលកម្មនោះទេ។ ក្រុមអ្នកសង្កេតការណ៍បាននិយាយថា បើគ្មានកម្មករចំណាកស្រុកទាំងនេះទេកសិដ្ឋាននិងរោងចក្រមួយចំនួនរបស់កូរ៉េខាងត្បូងនឹងគ្មានបុគ្គលិកធ្វើការ។

លោក Kim Jang-yeon ម្ចាស់កសិដ្ឋានមួយកន្លែងនៅទីក្រុងប៉ូជិនដែលស្ថិតនៅចម្ងាយ ៤១គីឡូម៉ែត្រពីទីក្រុងសេអ៊ូល បាននិយាយថា កម្មករបរទេសកំពុងមានតម្រូវការ។ លោកមានប្រសាសន៍ថា៖ «មានតម្រូវការពលករបរទេសយ៉ាងច្រើន។ ខ្ញុំក៏ជួលកម្មករក្នុងស្រុកដែរក្នុងរដូវមមាញឹក។ ពួកគេមានត្រឹមតែប្រហែល ២០ភាគរយនៃកម្មករទាំងអស់នៅកសិដ្ឋានរបស់យើង។ ៨០ ភាគរយទៀតគឺជាកម្មករបរទេស ហើយពួកគេគឺជាអ្នកផលិតផលិតផលកសិកម្ម»៕

# ថ្ងៃទី៣០ ខែ មករា ឆ្នាំ២០២៣

## អាជ្ញាធរកម្ពុជាស្នើសុំព័ត៌មានពីជនរងគ្រោះ
## ពីការឆបោកការងារ ដែលត្រូវបានបញ្ជូនតាមរយៈស្ថានទូតម៉ាឡេស៊ី

https://www.khmertimeskh.com/501228682// January 28, 2023

អាជ្ញាធរកម្ពុជាបានស្នើសុំឱ្យមានព័ត៌មានអំពីជនជាតិម៉ាឡេស៊ី ដែលរងគ្រោះដោយសារក្រុមឆបោកការងារក្នុងប្រទេស ដែលត្រូវបានបញ្ជូនទៅស្ថានទូតម៉ាឡេស៊ីឬនគរបាលភូមិន្ទម៉ាឡេស៊ី (PDRM) ដើម្បីសម្រួលដល់ការងារជួយសង្គ្រោះ។

ប្រធាននាយកដ្ឋានស៊ើបអង្កេតឧក្រិដ្ឋកម្ម Bukit Aman លោក Datuk Seri Abd Jalil Hassan បាននិយាយថា រាល់ព័ត៌មានដែលបញ្ជូនដោយអង្គការមិនមែនរដ្ឋាភិបាល (NGOs) ទៅកាន់អាជ្ញាធរកម្ពុជា នឹងមិនត្រូវបានបង្ហាញចាប់ពីថ្ងៃនេះតទៅ ព្រោះខ្លាចរំខានដល់កិច្ចខិតខំប្រឹងប្រែងជួយសង្គ្រោះ។ លោកថា កិច្ចព្រមព្រៀងនេះត្រូវបានសម្រេចបន្ទាប់ពីមានការពិភាក្សាគ្នារវាងអាជ្ញាធរកម្ពុជា និងគណៈប្រតិភូមកពីនគរបាលភូមិន្ទម៉ាឡេស៊ី និងក្រសួងការបរទេសប្រចាំកម្ពុជាដែលដឹកនាំដោយលោក។ លោកបានមានប្រសាសន៍នៅក្នុងសន្និសីទកាសែតជាមួយជនរងគ្រោះប្រាំនាក់ដែលត្រូវបានជួយសង្គ្រោះនៅអាកាសយានដ្ឋានអន្តរជាតិគូឡាឡាំពួរថា «តាមរយៈការពិភាក្សាជាមួយអាជ្ញាធរកម្ពុជា គេបានរកឃើញថាព័ត៌មានដែលផ្សាយដោយអង្គការក្រៅរដ្ឋាភិបាលបានជ្រៀតជ្រែកក្នុងដំណើរការជួយសង្គ្រោះ ដោយសារ ជនរងគ្រោះត្រូវបាននាំទៅលាក់ខ្លួនដោយក្រុមបោកប្រាស់។

ប្រធានកុងស៊ុលនិងពិធីការរបស់ក្រសួងការបរទេស លោក Mohd Aini Atan ក៏មានវត្តមានផងដែរ។ ទន្ទឹមនឹងនេះលោក Abd Jalil បានមានប្រសាសន៍ថា ការពិភាក្សាជាមួយអាជ្ញាធរកម្ពុជាក៏បានរកឃើញថាការអះអាងមួយចំនួនរបស់អង្គការក្រៅរដ្ឋាភិបាលនៅទីនេះ អំពីស្ថានភាពរបស់ជនរងគ្រោះ គឺគ្មានមូលដ្ឋានច្បាស់លាស់។ លោកបានមានប្រសាសន៍ថា "វីដេអូដែលជនរងគ្រោះនៃការឆបោកត្រូវបានគេធ្វើបាប និងបង្ខំឱ្យហូបសាច់ជ្រូកមិនពាក់ព័ន្ធនឹងជនជាតិម៉ាឡេស៊ីទេ វីដេអូនេះត្រូវបានផ្សព្វផ្សាយដោយចេតនាដោយបក្សពួកក្រុមឆបោក ដើម្បីបំភ័យសាច់ញាតិជនរងគ្រោះឱ្យបង់ប្រាក់ដើម្បីដោះលែងកូន ឬសមាជិកគ្រួសាររបស់ពួកគេ"។ បន្ថែមពីលើនេះ លោកថា មិនមែនបុគ្គលទាំងអស់ដែលត្រូវបានជួយសង្គ្រោះ និងនាំត្រឡប់ទៅប្រទេសម៉ាឡេស៊ី សុទ្ធតែជាជនរងគ្រោះនៃក្រុមឆបោកនោះទេ ព្រោះមានករណីបុគ្គលមានចេតនាអះអាងថាជាជនរងគ្រោះដើម្បីរត់គេចពីជំពាក់បំណុលគេដោយសារល្បែងស៊ីសង ហើយអ្នកខ្លះថែមទាំងបានត្រឡប់មកធ្វើការនៅកម្ពុជាវិញផងដែរបន្ទាប់ពីត្រូវបានជួយសង្គ្រោះ។

លោក Abd Jalil បានណែនាំដល់អង្គការក្រៅរដ្ឋាភិបាលឱ្យប្រយ័ត្នប្រយែងនៅពេលចេញសេចក្តីថ្លែងការណ៍ទាក់ទងនឹងបញ្ហានេះ ដើម្បីជៀសវាងការធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនងរវាងប្រទេសទាំងពីរ។ ទន្ទឹមនឹងនេះ លោក Abd Jalil បានមានប្រសាសន៍ថា គិតត្រឹមថ្ងៃព្រហស្បតិ៍នេះ នគរបាលភូមិន្ទម៉ាឡេស៊ី បានទទួលរបាយការណ៍នគរបាលសរុបចំនួន ២៦២ ដែលពាក់ព័ន្ធនឹងជនរងគ្រោះចំនួន ៣៣០ នាក់នៃក្រុមឆបោកការងារដែលបានជាប់គាំងនៅបរទេស ដោយ២១៨ នាក់ត្រូវបានជួយសង្គ្រោះ ហើយកិច្ចខិតខំប្រឹងប្រែងកំពុងដំណើរការដើម្បីនាំយកអ្នកដែលនៅសល់ត្រឡប់ទៅផ្ទះវិញ។ *Bernama*

## ជនជាតិម៉ាឡេស៊ី៥នាក់ទៀត ដែលគេសង្ស័យថាត្រូវបានចាញ់បោកក្រុមឆបោកគេការងារ អោយធ្វើនៅកម្ពុជា បានត្រឡប់មកប្រទេសវិញហើយ

https://www.khmertimeskh.com/501228676// January 28, 2023

ជនជាតិម៉ាឡេស៊ី ៥នាក់ ដែលត្រូវគេបោកបញ្ឆោតដោយសន្យាផ្តល់ការងារដែលមានប្រាក់ខែខ្ពស់នៅកម្ពុជា ត្រូវបានជួយសង្គ្រោះ និងនាំយកមកផ្ទះវិញដោយសុវត្ថិភាពកាលពីថ្ងៃសុក្រ។ ជាលទ្ធផលនៃប្រតិបត្តិការបង្ក្រាបជាបន្តបន្ទាប់ និងជំនួយពីនគរបាលកម្ពុជា រហូតមកដល់ពេលនេះ ពួកគេបានជួយសង្គ្រោះជនរងគ្រោះចំនួន ២១៨ នាក់ ខណៈ ១១៨ នាក់ផ្សេងទៀតកំពុងត្រូវបានបង្ខាំងនៅបរទេស។ «នៅកម្ពុជា យើងបានទទួលរបាយការណ៍ចំនួន ១១៤ ពាក់ព័ន្ធនឹងជនរងគ្រោះចំនួន ១៤៥ នាក់។ យើងបានបង្កើតបេសកកម្មពិសេសមួយដើម្បីទៅជួបអាជ្ញាធរមូលដ្ឋានដើម្បីសុំជំនួយ។ លោកបន្តថា៖ « រហូតមកដល់ពេលនេះ យើងបានជួយសង្គ្រោះជនជាតិម៉ាឡេស៊ីចំនួន ១១៦ នាក់ពីប្រទេសកម្ពុជា ហើយចំនួន ៦ នាក់ទៀតកំពុងស្ថិតនៅមន្ទីរឃុំឃាំងនៅទីនោះ។

Jalil បាននិយាយនៅឯអាកាសយានដ្ឋានអន្តរជាតិ Kuala Lumpur ថ្ងៃនេះថា "យើងកំពុងព្យាយាមកំណត់ទីតាំងជនរងគ្រោះម៉ាឡេស៊ីចំនួន២៩ នាក់ដែលនៅសេសសល់ ដោយមានជំនួយពីអាជ្ញាធរក្នុងតំបន់" ។ លោកក៏បានដឹកនាំបេសកកម្មមួយ ដែលរួមមានមន្ត្រីនគរបាលមកពីផ្នែក D3 របស់ Bukit Aman (ប្រឆាំងការជួញដូរមនុស្ស និងការរត់ពន្ធជនចំណាកស្រុក) រដ្ឋលេខាធិការក្រសួងការបរទេសទទួលបន្ទុកទំនាក់ទំនង និងការទូតសាធារណៈ Devrin Anak Jeck និងឯកអគ្គរដ្ឋទូតម៉ាឡេស៊ីប្រចាំកម្ពុជា Datuk Eldeen Husaini Mohd Hashim ទៅទៅប្រទេសកម្ពុជា សម្រាប់បេសកកម្មជួយសង្គ្រោះ។ «នេះគឺជាបេសកកម្មពិសេសមួយដែលរៀបចំរួមគ្នាដោយក្រសួងការបរទេស និងអាជ្ញាធរកម្ពុជា ដើម្បីពិភាក្សាអំពីរបៀបដែលយើងអាចសហការ (ក្នុងបេសកកម្មជួយសង្គ្រោះ) និងដោះស្រាយបញ្ហាឆបោកទាំងនេះ។

លោក Jalil បាននិយាយថាបេសកកម្មជួយសង្គ្រោះរយៈពេលបួនថ្ងៃចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែមករា នៅកម្ពុជា យើងបានឃើញអាជ្ញាធរម៉ាឡេស៊ីនិងកម្ពុជាបានពិភាក្សាអំពីបញ្ហាសុវត្ថិភាព និងសន្តិសុខពាក់ព័ន្ធនឹងជនឆបោកដែលផ្តោតលើជនជាតិម៉ាឡេស៊ី។ លោកបានបន្តថា ចំណាត់ការយ៉ាងរហ័សរបស់អាជ្ញាធរកម្ពុជាបានឈានដល់ការជួយសង្គ្រោះជនជាតិម៉ាឡេស៊ី ៥ នាក់អាយុចន្លោះពី ១៦ ទៅ ៤២ ឆ្នាំ។ ជនរងគ្រោះដែលក្មេងជាងគេ ត្រូវបាននាំយកមកវិញផ្ទះវិញ គឺជាក្មេងជំទង់វ័យ អាយុ១៦ ឆ្នាំម្នាក់មកពី Sarawak ។ «ខ្ញុំត្រូវបានគេប្រាប់ថា ភាគច្រើននៃជនជាតិម៉ាឡេស៊ីដែលត្រូវបានបោកបញ្ឆោតមករកការងារធ្វើនៅក្នុងប្រទេសកម្ពុជា បានទាក់ទងទៅអាជ្ញាធរមូលដ្ឋាននៅពេលដែលពួកគេដឹងថាត្រូវបានគេបោកប្រាស់ឱ្យធ្វើការនៅក្នុងកាស៊ីណូ។ "ជនរងគ្រោះទាំងនេះបាននិយាយថា ពួកគេត្រូវបានជួញដូរ និងចាប់ឃុំខ្លួន ប៉ុន្តែតាមពិតពួកគេដឹងពីអ្វីដែលពួកគេកំពុងធ្វើ។ លោកបានបន្តថា "មនុស្សជាច្រើនបានជាប់ពាក់ព័ន្ធក្នុងល្បែងស៊ីសង ដើម្បីខ្ចីប្រាក់គេ ហើយអះអាងថាពួកគេជាជនរងគ្រោះនៃការជួញដូរមនុស្ស ដើម្បីចៀសវាងការសងបំណុលរបស់ពួកគេ"។

លោកបានបន្ថែមថា ដំណើរការធ្វើមាតុភូមិនិវត្តន៍នឹងត្រូវចំណាយពេលប្រហែលមួយខែ ប៉ុន្តែដោយសារកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងល្អរវាងប្រទេសទាំងពីរ វាត្រូវបានបញ្ចប់ក្នុងរយៈពេលប៉ុន្មានថ្ងៃ។ លោកបានបដិសេធថា ជនរងគ្រោះម៉ាឡេស៊ីត្រូវបានធ្វើទារុណកម្ម និងបង្អត់អាហារដោយក្រុមជនពាល។ លោកបានពន្យល់ថា "ជាក់ស្តែង ថៅកែទាំងនោះបានកំណត់គោលដៅឱ្យជនរងគ្រោះបំពេញអោយបាន ប្រសិនបើពួកគេបរាជ័យនោះនឹងត្រូវទទួលរងទណ្ឌកម្ម។ ការអះអាងរបស់ជនរងគ្រោះម៉ាឡេស៊ី ដែលត្រូវបានគេឃុំឃាំង និងដាក់ច្រវាក់ គឺមិនពិតនោះទេ"។

Jalil បាននិយាយថាឪពុកម្តាយដែលកូនរបស់ពួកគេជាប់បង្ខាំងនៅក្រៅប្រទេសម៉ាឡេស៊ីគួរតែជូនដំណឹងដល់នគរបាល និងក្រសួងការបរទេសអំពីបញ្ហានេះ។ «យើងកំពុងព្យាយាមស្វែងរកជនជាតិម៉ាឡេស៊ី ២៤នាក់ផ្សេងទៀត ដែលជាប់គាំងនៅកម្ពុជា ប៉ុន្តែយើងមិនមានព័ត៌មានគ្រប់គ្រាន់អំពីកន្លែងលាក់ខ្លួនរបស់ពួកគេទេ»។ ក្នុងដំណើរបំពេញបេសកកម្មនោះ លោកបានថ្លែងអំណរគុណចំពោះក្រសួងដែលបានសហការ និងផ្តល់ជំនួយ។ Jalil បាននិយាយថា ចាប់ពីពេលនេះតទៅ អាជ្ញាធរកម្ពុជានឹងមិនទទួលយកសំណើណាមួយពីអង្គការក្រៅរដ្ឋាភិបាលដើម្បីបំពេញបេសកកម្មជួយសង្គ្រោះនោះទេ។ Jalil បានបន្ថែមថា "មានរបាយការណ៍មួយចំនួនបានបង្ហាញថា អង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានទាញយកផលប្រយោជន៍ពីស្ថានភាពនេះ ដើម្បីរកប្រាក់ចំណេញ។ នោះហើយជាមូលហេតុដែលយើងបានព្រមព្រៀងរួមគ្នាលើបញ្ហានេះ" ។ *New Straits Times*

## អាជ្ញាធរថៃ ចាប់ខ្លួនជនជាតិខ្មែរដែលក្លែងកាយជាសង្ឃ បោះតង់ក្នុងព្រៃចូលក្នុងដីថៃ

https://www.kampucheathmey.com/local-news/454767 ថ្ងៃអាទិត្យ ២៩ មករា ២០២៣ដោយ vann sokunthea

ព្រះសង្ឃមួយអង្គ ក្នុងចំណោម៤អង្គ ត្រូវបានតម្រួតថៃចុះឃាត់ខ្លួន ក្រោយពីដឹងថា ជាសង្ឃក្លែងក្លាយ និងជាជនជាតិខ្មែរ ដែលលបឆ្លងដែនខុសច្បាប់ចូលក្នុងប្រទេសថៃ។ ការឃាត់ខ្លួននេះធ្វើឡើងកាលពីល្ងាចថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៣ នៅក្នុងព្រៃរបោះមួយកន្លែង ក្នុងខេត្តនគរប៉ាធុំ ប្រទេសថៃ ដែលនៅទីនោះ មានការបោះជំរុំដោយគ្របតង់ និងមានសង្ឃចំនួន៤អង្គ។

សមត្ថកិច្ចថៃបានបញ្ជាក់ឲ្យដឹងថា កិច្ចប្រតិបត្តិការនេះ គឺធ្វើឡើងតាមការប្តឹងពីប្រជាពលរដ្ឋដែលគាត់បានអះអាងថា មានព្រះសង្ឃចំនួន៤អង្គ តែងតែនិមន្តបិណ្ឌបាតតាមភូមិ គឺមានអាការៈចម្លែក ទី១.ព្រះសង្ឃសូត្រធ៌មមិនសូវច្បាស់តាមសំនៀងថៃ ទី២.ព្រះសង្ឃបិណ្ឌបាតយកតែបច្ច័យ មិនព្រមយកចង្ហាន់ ទី៣.ព្រះសង្ឃមិនកោរពុកមាត់ និងចិញ្ចើមឡើយ។ ដោយសារមានការសង្ស័យបែបនេះ ទើបសមត្ថកិច្ចតាមប្រមាញ់រហូតឃើញទីតាំងដែលសង្ឃទាំង៤អង្គ គង់នៅ គឺបោះតង់ក្នុងព្រៃ មានតាំងពីអង្រឹង កន្ទេល មុង ភួយ ជាដើម។ល។ ដើម្បីស្នាក់អាស្រ័យ លុះពេលឃើញសមត្ថកិច្ចទៅដល់ គឺមានសង្ឃចំនួន២អង្គ រត់ចូលព្រៃ និងមួយអង្គទៀត លោតចូលទឹកអូរហែលគេចខ្លួនបាត់នៅសល់តែមួយអង្គ ដែលរត់ដែរ តែត្រូវបន្លាទាក់ស្បង់ជាប់ទើបមិនអាចរត់បាន ។

នៅចំពោះមុខសមត្ថកិច្ចថៃ សង្ឃក្លែងក្លាយអង្គនេះបានសារភាពថា កាលពីពាក់កណ្តាលឆ្នាំ២០២២ ខ្លួនត្រូវបានតម្រួតឃាត់ខ្លួន និងបានបញ្ជូនទៅកម្ពុជាវិញម្តងរួចមកហើយ ពីបទក្លែងខ្លួនជាសង្ឃ លុះថ្មីៗនេះខ្លួនក៏បានបបួលគ្នីគ្នាត្រឡប់មកកន្លែងដើម ដើម្បីក្លែងខ្លួនដើរបិណ្ឌបាតយកបច្ច័យម្តងទៀត ក៏ត្រូវឃាត់ខ្លួនតែម្តង ៕
អត្ថបទ៖ សោ និយមរ័ត្ន

## ក្រសួងយុត្តិធម៌ ចុះអនុស្សរណៈយោគយល់គ្នាជាមួយការិយាល័យច្បាប់សហរដ្ឋអាមេរិក ដើម្បីលើកកម្ពស់ចំណេះដឹងផ្នែកច្បាប់

https://www.khmertimeskh.com/501228813//?p=1228813 January 29, 2023

ក្រសួងយុត្តិធម៌បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រុមហ៊ុន Building Bridge USA (BUSA) ដែលជាការិយាល័យច្បាប់របស់សហរដ្ឋអាមេរិក ក្នុងគោលបំណងលើកកម្ពស់ចំណេះដឹងផ្នែកច្បាប់ និងការប្រើប្រាស់បណ្ណាល័យច្បាប់អេឡិចត្រូនិក។ លោក ជិន ម៉ាលីន រដ្ឋលេខាធិការក្រសួងយុត្តិធម៌ មានវត្តមាននៅក្នុងពិធីជាមួយអតីតចៅក្រមសហរដ្ឋអាមេរិក លោក John C. Coughenour និងអតីតប្រធានគណៈមេធាវី លោក Bill Pickett នៅទីស្តីការក្រសួងកាលពីថ្ងៃសុក្រ។

យោងតាមក្រសួងយុត្តិធម៌ អនុស្សរណៈនៃការយោគយល់គ្នានេះមានគោលបំណងលើកកម្ពស់ចំណេះដឹងផ្នែកច្បាប់ និងការប្រើប្រាស់បណ្ណាល័យច្បាប់អេឡិចត្រូនិកនៅកម្ពុជា។ តាមរយៈកិច្ចសហការនេះ វានឹងផ្តល់ចំណេះដឹង និងជំនាញផ្នែកច្បាប់បន្ថែមទៀតដល់និស្សិត អ្នកប្រាជ្ញ និងមន្ត្រីអនុវត្តច្បាប់កម្ពុជា ដែលនឹងត្រូវបានពង្រឹងបន្ថែមទៀត តាមរយៈការប្រើប្រាស់បណ្ណាល័យច្បាប់អេឡិចត្រូនិករបស់សហរដ្ឋអាមេរិកដោយឥតគិតថ្លៃ កិច្ចប្រជុំ សិក្ខាសាលា ដំណើរទស្សនកិច្ចសិក្សា និងការផ្លាស់ប្តូរ នឹងចែករំលែកចំណេះដឹង និងបទពិសោធន៍ផ្នែកច្បាប់ដល់ចៅក្រម ព្រះរាជអាជ្ញា មេធាវី អ្នកជំនាញច្បាប់ អ្នកប្រាជ្ញ និងនិស្សិតនៃប្រទេសទាំងពីរផងដែរ។

បន្ទាប់ពីការចុះហត្ថលេខាលើ MoU លោក ម៉ាលីន ក៏បានធ្វើបាឋកថាស្តីពី "ទំនាក់ទំនងទំនុកចិត្ត និងសេវាកម្មក្នុងយុគសម័យឌីជីថល" ជាមួយ លោក John C. Coughenour និងលោក Bill Pickett ព្រមទាំងសិស្សចៅក្រម ព្រះរាជអាជ្ញា មេធាវី សាការី និងអាជ្ញាសាលាចំនួន ១៣០នាក់។

## នគរបាលម៉ាឡេស៊ីនិយាយថា ពលរដ្ឋម៉ាឡេស៊ីមួយចំនួនដែលត្រូវបានជួយសង្គ្រោះពីក្រុមឆបោកនៅកម្ពុជាបានត្រឡប់ទៅទីនោះវិញដោយសារទទួលបានប្រាក់ចំណូលច្រើន

https://www.khmertimeskh.com/501228892//?p=1228892 January 29, 2023

ប្រធាននាយកដ្ឋានស៊ើបអង្កេតឧក្រិដ្ឋកម្ម Bukit Aman លោក Datuk Seri Abd Jalil Hassan បាននិយាយនៅថ្ងៃនេះថា ជនជាតិម៉ាឡេស៊ីមួយចំនួនដែលទទួលបានចំណូលច្រើនពីការធ្វើការអោយក្រុមឆបោកនៅកម្ពុជា បានត្រលប់ទៅទីនោះវិញ បើទោះបីជាត្រូវបានជួយសង្គ្រោះក៏ដោយ។ លោកក៏បាននិយាយផងដែរថាបុគ្គលមួយចំនួនមិនចង់អោយជួយសង្គ្រោះទេដោយសារតែពួកគេរកលុយបានច្រើនដោយធ្វើការអោយក្រុមឆបោកបន្ទាប់ពីអាចបំពេញតាមគោលដៅដែលកំណត់ដោយថៅកែរបស់ពួកគេ។

"ជនរងគ្រោះដឹងថាពួកគេនឹងធ្វើការអោយក្រុមឆបោកនៅកម្ពុជា ប៉ុន្តែដោយសារតែពួកគេមិនអាចសម្រេចនូវការងារដែលបានដាក់អោយដោយថៅកែរបស់ពួកគេ ដូចនេះហើយ ពួកគេបានសុំការជួយសង្គ្រោះពីអាជ្ញាធរពាក់ព័ន្ធ។ "ប៉ុន្តែអ្នកខ្លះអាចសម្រេចបាននូវរាល់ការងារដែលបានដាក់អោយ ដូចនេះហើយពួកគេមិនចង់ត្រលប់ទៅផ្ទះវិញទេទោះបីជាយើងចង់ជួយសង្គ្រោះពួកគេក៏ដោយ។ ពួកគេរស់នៅក្នុងប្រណីតភាពដោយសារតែការងាររបស់ពួកគេ។

លោក Abd Jalil បានប្រាប់អ្នកយកព័ត៌មានក្នុងសន្និសីទសារព័ត៌មានដែលធ្វើឡើងនៅអាកាសយានដ្ឋានអន្តរជាតិគូឡាឡាំពួរនៅរសៀលនេះថា "ទោះបីជាយើងយកពួកគេត្រឡប់មកផ្ទះវិញក៏ដោយ ក៏ពួកគេរកវិធីត្រឡប់ទៅកម្ពុជាវិញដែរ" ។ លោកបន្ថែមថា អាជ្ញាធរកម្ពុជាមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីចាប់ខ្លួនពួកគេពីបទឆបោកនៅអំឡុងពេលនោះទេ។ នៅពេលអ្នកសារព័ត៌មានសួរថា តើមានការផាកពិន័យណាមួយសម្រាប់អ្នកដែលត្រឡប់

ទៅកម្ពុជាវិញ ដើម្បីធ្វើការអោយក្រុមឆបោកនោះ លោក Abd Jalil បាននិយាយថា គ្មានអ្វីដែលអាជ្ញាធរអាចធ្វើបានឡើយ យើងមានទំនួលខុសត្រូវរក្សាសុវត្ថិភាពប្រជាជនម៉ាឡេស៊ី។

"ប្រសិនបើជនជាតិម៉ាឡេស៊ីណាម្នាក់មកសុំជំនួយពីយើង យើងមានទំនួលខុសត្រូវក្នុងការជួយពួកគេ។ វាពិបាកក្នុងការកំណត់ថាតើពួកគេជាជនរងគ្រោះ ឬជាអ្នកបោកប្រាស់។ បើយើងមិនជួយគេ តើសាធារណជនយល់ឃើញយ៉ាងណា? ទោះបីជាយើងជួយពួកគេឲ្យអស់ពីសមត្ថភាពក៏ដោយ ការយល់ឃើញរបស់សាធារណជនប្រហែលជាមិនផ្លាស់ប្តូរទេ»។

លោក Abd Jalil ក៏បានបញ្ជាក់ផងដែរថា វីដេអូនៃការរំលោភបំពានណាមួយ ដែលកំពុងត្រូវបានចែកចាយតាមអ៊ីនធឺណិត មិនបានពាក់ព័ន្ធនឹងជនរងគ្រោះជាជនជាតិម៉ាឡេស៊ីនោះទេ។ គិតត្រឹមថ្ងៃទី២៦ ខែមករា ឆ្នាំនេះ មានរបាយការណ៍រហូតដល់២៦២ករណី ពាក់ព័ន្ធនឹងជនរងគ្រោះចំនួន៣៣០ នាក់ដែលកំពុងត្រូវបានជាប់បង្ខាំងនៅបរទេសដោយសារចាញ់បោករកការងារ។ ក្នុងចំណោមជនរងគ្រោះសរុប ជនរងគ្រោះចំនួន ១១៦នាក់ ត្រូវបានជួយសង្គ្រោះដោយជោគជ័យ ក្នុងនោះជនរងគ្រោះចំនួន ២៩នាក់នៅតែជាប់គាំងក្នុងប្រទេសកម្ពុជា។ ក្នុងចំណោមនេះ បច្ចុប្បន្នមានជនរងគ្រោះ៦នាក់ ត្រូវបានអន្តោប្រវេសន៍កម្ពុជាឃាត់ខ្លួនពីបទបំពានច្បាប់អន្តោប្រវេសន៍។